វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ
ADVOCACY AND POLICY INSTITUTE

# វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ



# របាយការណ៍
## ប្រចាំឆ្នាំ ២០២០



ដៃគូផ្តល់ជំនួយ និងដៃគូអនុវត្ត

# មាតិកា


សារ ពីក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការប្រត្តិបត្តិ ........ ៤

១ សេចក្តីសង្ខេបប្រតិបត្តិ ........ ៦

២ វឌ្ឍនភាពតាមគម្រោងចូលរួមចំណែកសម្រេចលទ្ធផលជាយុទ្ធសាស្ត្រ ........ ១០

លទ្ធផលទី១៖ គោលនយោបាយ និងការអនុវត្តមានឥទ្ធិពលដើម្បីការពារសិទ្ធិ និងដោះស្រាយសេចក្តីត្រូវការរបស់ពលរដ្ឋ ........ ១០

គម្រោងទី១៖ សំឡេង និងសកម្មភាពប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅប្រទេសកម្ពុជា ........ ១០

គម្រោងទី២៖ ការជជែកដេញដោលរបស់យុវជនអំពីសិទ្ធិទទួលបានច្បាប់ព័ត៌មាន ........ ១៣

គម្រោងទី៣៖ វិទ្យាស្ថាន API ធ្វើជាលេខាធិការដ្ឋានអង្គការសម្ព័ន្ធភាពដៃគូការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ CPDD ........ ១៦

លទ្ធផលទី២៖ ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលជួបការលំបាកក្នុងការធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាព ........ ១៩

គម្រោងទី៤៖ ការលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យមូលដ្ឋាននៅកម្ពុជា ........ ១៩

គម្រោងទី៥៖ លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការ និងថវិកានៅរដ្ឋបាលឃុំសង្កាត់ ........ ២២

គម្រោងទី៦៖ ច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ (OW4C) ........ ២៥

គម្រោងទី៧៖ ការអភិវឌ្ឍសមត្ថភាពពីការគៀរគរការគាំទ្រដល់អង្គការសង្គមស៊ីវិលកម្ពុជា ........ ៣០

គម្រោងទី៨៖ ជួយសង្គ្រោះបន្ទាន់ដល់ក្រុមគ្រួសារក្រីក្រដោយសារកូវីដ-១៩ ........ ៣៣

គម្រោងទី៩៖ សំឡេង និងសកម្មភាពរបស់ជនមានពិការភាពក្នុងគណនេយ្យភាពសង្គម ........ ៣៦

គម្រោងទី១០៖ សំឡេងពលរដ្ឋក្នុងក្របខណ្ឌគនេយ្យភាពសង្គម ........ ៤២

គម្រោងទី១១៖ គាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយអត្ថន័យតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ........ ៤៧

គម្រោងទី១២៖ ការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា ........ ៥១

# មាតិកា


គម្រោងទី១៣៖ សំឡេង និងសកម្មភាពរបស់ស្ត្រីដឹកនាំវ័យក្មេង និងសហគ្រិន ........ ៥៤

គម្រោងទី១៤៖ ការលើកកម្ពស់សមត្ថភាពស្ថាប័ន និងប្រតិបត្តិការរបស់សមាគមក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន ........ ៥៨

**លទ្ធផលទី៣៖ ធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មានអំពីបញ្ហាសំខាន់ៗក្នុងតំបន់ និងថ្នាក់ជាតិ ........ ៦៣**

គម្រោងទី១៥៖ សិទ្ធិទទួលបានព័ត៌មានសម្រាប់ទាំងអស់គ្នា៖ ការលើកកម្ពស់ការទទួលបានព័ត៌មាននៅកម្ពុជា ........ ៦៦

**៣ ការបោះពុម្ពផ្សាយ និងការផ្សព្វផ្សាយឆ្នាំ២០២០ ........ ៦៩**

**៤ បណ្តាញ និងក្រុមការងាររអង្គការសង្គមស៊ីវិលដៃគូ ........ ៧១**

**លទ្ធផលទី៤៖ បង្កើនសមត្ថភាពអង្គភាព និងភាពរឹងមាំនៃការរៀអង្គាសថវិកា ........ ៧៣**

**៥ របាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ ........ ៧៥**




# សារពីក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការប្រតិបត្តិ

ក្នុងគ្រាលំបាកបំផុតនៃរោគរាតត្បាតកូវីដ-១៩ជាសកលលោក ក្នុងនាមជាក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការប្រតិបត្តិនៃវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ (API) សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នកទទួលផល និងអ្នកគាំទ្រទាំងអស់របស់ API ដែលបានចូលរួម និងគាំទ្រដល់សកម្មភាពនិងបេសកកម្មរបស់យើង។ យើងសូមកោតសរសើរជាពិសេសដល់ពលរដ្ឋសហគមន៍ទូទាំងប្រទេសកម្ពុជាដែល API ធ្វើការជាមួយ និងសូមកោតសរសើរ និងអរគុណដល់ដៃគូផ្តល់មូលនិធិរបស់យើង ភាគីរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ដែលបានចូលរួមក្នុងការសម្រេចគោលដៅដែលយើងបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រទី ៤ របស់យើង។ ការសម្រេចបាននូវសិទ្ធិ និងការលើកកម្ពស់សំឡេងរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជាជាពិសេសសិទ្ធិរបស់ ស្ត្រី យុវជន និងក្រុមងាយរងគ្រោះ ដូចជាពលរដ្ឋក្រីក្រ ជនមានពិការភាព ជនជាតិដើមនិងកុមារក្រៅសាលានៅតែជាអាទិភាពចំបងរបស់យើង។ ការធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាព និងការតស៊ូមតិដើម្បីតម្លាភាព ការកែលម្អអភិបាលកិច្ចមូលដ្ឋានគឺជាគោលដៅសំខាន់របស់យើង។ យើងនឹងមិនអាចសម្រេចបានលទ្ធផលទាំងនេះទេ បើគ្មានអ្នកគាំទ្រជាជំនួយដ៏មានតម្លៃធ្វើឱ្យការងាររបស់យើងអាចធ្វើទៅបានជារៀងរាល់ថ្ងៃ។

យើងក៏សូមថ្លែងអំណរគុណដល់បណ្តាញដៃគូទាំងអស់របស់យើងដែលបានចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់យើងដើម្បីសម្រេចនូវគោលបំណងរួមរបស់យើងរួមមាន៖ ក្រុមហ៊ុន Nickol Global Solutions សមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្តពោធិ៍សាត់ អង្គការ InSTEDD, Aide et Action, Epic Arts, IDEA, អង្គការក្រុមទ្រទ្រង់ភូមិ(VSG) អង្គការកម្ពុជាដើម្បីគាំទ្រស្ត្រី (COWS) សមាជិកនៃសម្ព័ន្ធភាពដើម្បីភាពជាដៃគូក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD), ក្រុមការងារសិទ្ធិទទួលបានព័ត៌មាន (A2IWG), ក្រុមការងារថវិកា (BWG), គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC), វេទិកាអង្គការក្រៅរដ្ឋាភិបាលសម្រាប់កម្ពុជា (NGOF) ។ល។

សូមសសើរនិងអរគុណចំពោះការសហការដ៏ល្អជាមួយសភាទាំងពីររបស់ប្រទេសកម្ពុជាក៏ដូចជាស្ថាប័នរដ្ឋាភិបាលដូចខាងក្រោម៖ សមាគមក្រុមប្រឹក្សាមូលដ្ឋានខេត្តកំពង់ធំ បន្ទាយមានជ័យ កំពង់ស្ពឺ កែបនិង កណ្តាល សម្ព័ន្ធភាពជាតិនៃក្រុមប្រឹក្សាមូលដ្ឋាន គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ ជ អ ប) ក្រសួងមហាផ្ទៃ ក្រសួងអប់រំយុវជននិងកីឡា និងក្រសួងសុខាភិបាល និងអាជ្ញាធរមូលដ្ឋាន និងស្ថាប័នផ្តល់សេវាកម្មទាំងអស់។

យើងសូមថ្លែងអំណរគុណចំពោះដៃគូនិងម្ចាស់ជំនួយរបស់យើងរួមមាន សហភាពអឺរ៉ុប ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត (SIDA) មូលនិធិកុមាររបស់អង្គការសហប្រជាជាតិ (UNICEF) មូលនិធិប្រជាធិបតេយ្យនៃអង្គការសហប្រជាជាតិ (UNDEF) ក្រសួងការបរទេសហូឡង់ផ្តល់ជំនួយកម្មវិធី VOICE; អង្គការ Brot for die Welt (BftW), ជំនួយព្រះវិហាដាណឺមាក (DCA) អង្គការ Oxfam, CARE មូលនិធិ Wilde Ganzen (WG), Pact, សុខភាពគ្រួសារអន្តរជាតិ (FHI360), វិទ្យាស្ថាន EWMI ។ល។




សូមថ្លែងអំណរគុណដល់ក្រុមប្រឹក្សាភិបាល API រួមមាន៖ លោក សឿន ច័ន្ទដារ៉ា លោកស្រី Kasumi Nakagawa លោក Michael Engquist លោក ឃួន ប៊ុនសាង លោក គឹម សុខលាង លោកស្រី ញាន ភួងម៉ាលី និង លោក ថន ប៊ុនធឿន ដែលចំណាយពេលវេលានិងខំប្រឹងប្រែងជួយដោយស្ម័គ្រចិត្តក្នុងការផ្តល់ដំបូន្មានដ៏មានតម្លៃ ដោយផ្អែកលើបទពិសោធន៍និងជំនាញ។ ជាពិសេសយើងសូមថ្លែងអំណរគុណចំពោះបុគ្គលិក និងទីប្រឹក្សា លោក Lars Krause និងលោក បណ្ឌិត រ៉ាយម៉ុនឡូស អ្នកស្ម័គ្រចិត្ត អ្នកដឹកនាំនិងសមាជិកសហគមន៍នៅក្នុងតំបន់គោលដៅ និងអ្នកពាក់ព័ន្ធទាំងអស់របស់យើងដែលបានខិតខំ និងចូលរួមចំណែកក្នុងការធ្វើឱ្យប្រសើរឡើងនូវ៖

- សេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មានជាធាតុផ្សំនៃអភិបាលកិច្ចល្អ
- ការបែងចែកថវិកាថ្នាក់ក្រោមជាតិដែលផ្តោតលើសេវាសង្គម
- សមត្ថភាពសមាជិកក្រុមប្រឹក្សាមូលដ្ឋានជួយឱ្យអនុវត្តតួនាទីថ្មីកាន់តែប្រសើរឡើង
- សិទ្ធិអំណាចដល់ពលរដ្ឋជាពិសេសស្ត្រី យុវជន និងក្រុមដែលងាយរងគ្រោះក្នុងការបញ្ចេញមតិយោបល់របស់ពួកគេ លើកកម្ពស់គណនេយ្យភាពរបស់រដ្ឋាភិបាលក្នុងការសម្រេចចិត្ត និងសកម្មភាពរបស់ខ្លួនក្នុងការផ្តល់សេវាសាធារណៈកាន់តែប្រសើរ
- ការលើកកម្ពស់សិទ្ធិទទួលបានព័ត៌មាន និងការបើកចំហព័ត៌មានសាធារណៈស្តីពីបញ្ហាសំខាន់ៗដូចជាចំណូល ចំណាយ ថវិកាស្រុក និងឃុំ។

វិទ្យាស្ថាន API ប្តេជ្ញាធ្វើការជាមួយស្ថាប័នជាតិ និងអន្តរជាតិដែលចែករំលែកគុណតម្លៃរបស់ខ្លួន៖ ការតស៊ូមតិដើម្បីការផ្លាស់ប្តូរសង្គមប្រកបដោយភាពវិជ្ជមាន និងការលើកកម្ពស់សមត្ថភាព និងកិច្ចសហប្រតិបត្តិការរបស់ប្រជាជនកម្ពុជាទាំងអស់។ API កំពុងកសាងស្ពានរវាងរដ្ឋាភិបាល សភា ប្រជាពលរដ្ឋ អាជីវកម្មខ្នាតតូច រដ្ឋបាលមូលដ្ឋាន និងថ្នាក់ជាតិដែលស្របតាមគោលដៅរបស់ខ្លួនក្នុងការលើកកម្ពស់លំហប្រជាធិបតេយ្យនៅកម្ពុជា។

ធ្វើនៅភ្នំពេញ ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១



**ឡាំ សុជាតិ**
នាយកប្រតិបត្តិ
វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ



**សឿង ចន្ទ័តារា**
ប្រធានក្រុមប្រឹក្សាភិបាល
វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ



## ១. សេចក្តីសង្ខេបប្រតិបត្តិ

ជាមួយនឹងផែនការយុទ្ធសាស្ត្រទី៤របស់វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ(API)សម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ API បន្ត**គោលដៅនៃការធ្វើឱ្យប្រសើរឡើងនូវសិទ្ធិ និងលើកកម្ពស់សំឡេងរបស់ពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា**ដោយផ្តោតលើស្ត្រី យុវជន និងក្រុមដែលងាយរងគ្រោះរួមមានជនក្រីក្រ ជនមានពិការភាព ជនជាតិដើម និងកុមារក្រៅសាលា។

ដើម្បីសម្រេចបានគោលដៅនេះ API នៅតែបន្តខិតខំធ្វើឱ្យប្រសើរឡើងនូវការទទួលបានព័ត៌មានសាធារណៈរបស់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងអភិបាលកិច្ចមូលដ្ឋាន និងការត្រួតពិនិត្យការផ្តល់សេវាសាធារណៈ និងដើម្បីអភិវឌ្ឍសមត្ថភាពសង្គមស៊ីវិល និងចូលរួមក្នុងការតស៊ូមតិ និងឥទ្ធិពលលើគោលនយោបាយ។ API បន្ថែមអភិវឌ្ឍភាពខ្លាំងរបស់ខ្លួនបន្ថែមទៀតដើម្បីកសាងសមត្ថភាពសម្រាប់ការផ្លាស់ប្តូរ និងភ្ជាប់សំឡេងរបស់ពលរដ្ឋសហគមន៍ និងសង្គមស៊ីវិលទៅនឹងការបង្កើតគោលនយោបាយថ្នាក់ជាតិនានា។ API ជួយសហគមន៍ អង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលមូលដ្ឋានឱ្យយល់និងបំពេញនូវសិទ្ធិ និងគោលនយោបាយដើម្បីពលរដ្ឋទទួលបានព័ត៌មានសាធារណៈ ចូលរួមក្នុងអភិបាលកិច្ចមូលដ្ឋាន និងការតស៊ូមតិដើម្បីដោះស្រាយបញ្ហារបស់ពលរដ្ឋគ្រប់ជាន់ថ្នាក់។

នេះជាឆ្នាំទី២នៃរយៈពេលអនុវត្តផែនការយុទ្ធសាស្ត្រ ២០១៩-២០២៣ ភាគច្រើននៃសកម្មភាពគម្រោង និងគោលបំណងសំខាន់ៗត្រូវបានអនុវត្តដោយជោគជ័យទោះបីមានការរីករាលដាលនៃរោគរាតត្បាតកូវីដ-១៩ទូទាំងពិភពលោកក៏ដោយ។ API បានពន្យាពេលនៃសកម្មភាពការងារនៅតាមមូលដ្ឋានជាច្រើនដោយសារតែគោល ការណ៍សុខភាពសាធារណៈដែលរឹតត្បិតការប្រមូលផ្តុំសាធារណៈ និងចំនួនអ្នកចូលរួមអនុញ្ញាតនៅក្នុងព្រឹត្តិការណ៍នីមួយៗដោយសារកូវីដ-១៩។

**API បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវលទ្ធផលជាយុទ្ធសាស្ត្រទី១៖ ជះឥទ្ធិពលដល់លទ្ធផលគោលនយោបាយដើម្បីការពារសិទ្ធិ និងតម្រូវការរបស់ពលរដ្ឋជាពិសេសយុវជនស្ត្រី** និងក្រុមដែលជួបការលំបាក និងការពារលំហប្រជាធិបតេយ្យដែលអនុញ្ញាតឱ្យពួកគេអនុវត្តសិទ្ធិរបស់ពួកគេ។ សមិទ្ធផលដ៏ធំធេងនេះត្រូវបានរួមចំណែកជាចំបងតាមរយៈលទ្ធផលគម្រោងដូចខាងក្រោម៖

- ជះឥទ្ធិពលលើកំណែទម្រង់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការលើការផ្ទេរមុខងារពីថ្នាក់ក្រសួងនានានៅថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាមូលដ្ឋាន អង្គការ សហគមន៍ និងការចូលរួមយ៉ាងសកម្មរបស់ពួកគាត់
- ធ្វើឱ្យប្រសើរឡើងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មានតាមរយៈការជជែកដេញដោលរបស់យុវជនជាមួយតំណាងរដ្ឋាភិបាល តំណាងរាស្ត្រ និងដៃគូអភិវឌ្ឍ
- ធ្វើឱ្យប្រសើរឡើងនូវការធ្វើវិសោធនកម្មច្បាប់អង្គការក្រៅរដ្ឋាភិបាលតាមរយៈការខិតខំតស៊ូមតិរួមគ្នាជាមួយបណ្តាញអង្គការក្រៅរដ្ឋាភិបាល
- រួមបញ្ចូលសំឡេង និងតម្រូវការជនមានពិការភាពក្នុងការអនុវត្តគណនេយ្យភាពសង្គម (ISAF) និងការកែសំរួលសេចក្តីណែនាំនៃការប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិលក្នុងការអនុវត្ត ISAF ដំណាក់កាលទី២ ដែលបានពិនិត្យឡើងវិញនូវពិការភាព និងបរិយាប័ន្នសង្គម។



**API បានសម្រេចលទ្ធផលជាយុទ្ធសាស្ត្រទី២ របស់ខ្លួន៖ ពង្រឹងសិទ្ធិអំណាចពលរដ្ឋដែលជួបការលំបាកក្នុងការលើកឡើង និងដោះស្រាយការព្រួយបារម្ភរបស់ពួកគេ និងធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាពជាមួយពួកគេ។** សមិទ្ធផលនេះត្រូវបានចូលរួមតាមរយៈគម្រោងដូចខាងក្រោម៖

- ពង្រឹងអភិបាលកិច្ចប្រជាធិបតេយ្យមូលដ្ឋាននៅគ្រប់ឃុំ - សង្កាត់ទាំងអស់ក្នុងខេត្តចំនួន ១២ ក្នុងប្រទេសកម្ពុជា ដើម្បីលើកកម្ពស់សេវាសាធារណៈរបស់ឃុំ មណ្ឌលសុខភាព សាលាបឋមសិក្សា និងប៉ុស្តិ៍ប៉ូលីស
- បានពង្រឹងការចូលរួមរបស់តំណាងយុវជនចំនួន៨០នាក់ក្នុងការរៀបចំផែនការនិងថវិកាក្នុងស្រុកសម្រាប់ការអភិវឌ្ឍសេវាសង្គមនៅឃុំចំនួន២០ ក្នុង៤ស្រុក ក្នុង៣ រាជធានីនិងខេត្ត
- ធ្វើឱ្យប្រសើរឡើងនូវតម្លាភាព និងគណនេយ្យភាពនៃសេវាកម្មច្រកចេញចូលតែមួយក្នុងស្រុកចំនួន ៥ នៃខេត្តបាត់ដំបង
- អភិវឌ្ឍសមត្ថភាពដល់ថ្នាក់ដឹកនាំអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកចំនួន៥០ ក្រុមអង្គការសហគមន៍ចំនួន៦០ និងក្រុមយុវជននិងអ្នកស្ម័គ្រចិត្តប្រមាណ៥០០នាក់ (អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ និងមន្ត្រីរដ្ឋាភិបាលចំនួន ៦០០ នាក់ (អ្នកផ្តល់សេវា) និងសមាជិកក្រុមប្រឹក្សាមូលដ្ឋាន
- បានផ្តល់ជំនួយសង្គ្រោះបន្ទាន់ កូវីដ-១៩ ដល់គ្រួសារងាយរងគ្រោះបំផុតចំនួន ៥០០ នៅក្នុងខេត្តកំពង់ធំ និងសែនសុខរាជធានីភ្នំពេញ
- ដាក់បញ្ចូលទាំងសំឡេង តម្រូវការ និងសកម្មភាពរបស់ជនមានពិការភាពចំនួន ៥០០ នាក់ដើម្បីទទួលបាននូវសេវាសាធារណៈប្រសើរជាងមុនលើសេវាសុខាភិបាល សេវាអប់រំ និងឃុំសង្កាត់នៅស្រុកតាំកក់ខេត្តតាកែវ
- បានពង្រឹងសមត្ថភាព និងសកម្មភាព តំណាងយុវជនចំនួន ២០០នាក់ ក្នុងការចូលរួមរបជាមួយរដ្ឋាភិបាលដើម្បីទទួលបានសេវាសាធារណៈនៅតាមខេត្តចំនួន៦
- ធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់ប្រជាពលរដ្ឋប្រហែល៣០០នាក់ជាមួយរដ្ឋាភិបាលនៅរាជធានីភ្នំពេញ និងក្រុងតាខ្មៅ លើការទទួលបានសេវាសុខភាព ការអប់រំនិងសង្កាត់
- លើកកម្ពស់សំឡេង និងសកម្មភាពរបស់អ្នកដឹកនាំស្ត្រីវ័យក្មេងជាសហគ្រិនខ្នាតតូចបំផុតចំនួន ៤០ នាក់ ដើម្បីជជែកជាមួយរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានដើម្បីធ្វើអាជីវកម្មខ្នាតតូចជាលក្ខណៈគ្រួសាររបស់ពួកគេ (អ្នកលក់ដូរតាមដងផ្លូវ) ដើម្បីទទួលបានជីវភាពរស់នៅសមរម្យនៅភ្នំពេញ។

**API បានមសម្រេចលទ្ធផលទី៣៖ ធ្វើឱ្យប្រសើរឡើងនូវសិទ្ធិទទួលបានព័ត៌មាន និងការបើកចំហព័ត៌មានសាធារណៈ**ស្តីពីបញ្ហាសំខាន់ៗក្នុងមូលដ្ឋាន និងថ្នាក់ជាតិជាពិសេសព័ត៌មានពីចំណូល ចំណាយសាធារណតាមរយៈការអនុវត្តគម្រោងទាំងអស់ខាងលើ។

- ពលរដ្ឋ ១១,០០០ នាក់ទទួលបានព័ត៌មាន និងយល់ដឹងពីថវិកាចំណូលចំណាយថ្នាក់ស្រុកតាមរយៈចូលរួមវេទិកាសាធារណៈស្តីពីថវិកាស្រុកក្នុងឃុំគោលដៅចំនួន៨៦ ឃុំ
- ប្រជាជនភាគច្រើននៅក្នុងប្រទេសកម្ពុជាបានទទួលព័ត៌មានពីការការពារខ្លួនពីជំងឺឆ្លងកូវីដ-១៩តាមរយៈសកម្មភាពផ្សព្វផ្សាយរបស់គម្រោង



- ប្រជាជនប្រហែល ៦,០០០ នាក់នៅក្នុង ២៤ ឃុំ សង្កាត់បានទទួលព័ត៌មានដោយផ្ទាល់អំពីសិទ្ធិទទួលព័ត៌មាន ថវិកា និងស្តង់ដារសេវានៅមណ្ឌលសុខភាព សាលាបឋមសិក្សា និងប៉ុស្តិ៍រដ្ឋបាលឃុំ សេវាឃុំសង្កាត់ ហើយប្រជាជនប្រហែល ៣១០,០០០ នាក់ត្រូវបានយល់ពីសិទ្ធិពួកគេស្តីពីគណនេយ្យភាពសង្គមតាមវីដេអូអប់រំខ្លីៗក្នុងបណ្តាញសង្គមរបស់ API។
- ប្រជាជន ៨,០០០ នាក់ទទួលបានព័ត៌មានអំពីសេវា តម្លៃ នីតិវិធីនៃការិយាល័យច្រកចេញចូលតែមួយនៅ ៥ស្រុកនៃខេត្តបាត់ដំបង។

**ការបោះពុម្ពផ្សាយរបាយការណ៍ API** បានបោះពុម្ពផ្សាយរបាយការណ៍ជាច្រើនផលិតនៅឆ្នាំ ២០២០ ដូចជា ១.ការវាយតម្លៃលើការចូលរួមរបស់យុវជនក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តឃុំសង្កាត់ ២.ការស្ទង់មតិអំពីមូលដ្ឋានការិយាល័យច្រកចេញចូលតែមួយឆ្នាំ ២០២០ ៣.របាយការណ៍ពិន្ទុសហគមន៍ OWSO ឆ្នាំ២០២០; ៤.ការស្ទង់មតិតាមអ៊ិនធ័រណែតជាមួយសហគ្រិនខ្នាតតូចបំផុតជានារីលក់ដូរតាមចិញ្ចើមថ្នល់ក្នុងទីក្រុងភ្នំពេញក្នុងអំឡុងពេលកូវីដ-១៩ ៥.ការវាយតម្លៃវាយតម្លៃផ្ទៃក្នុងលើសំឡេងជនមានពិការភាពនៅ ISAF ឆ្នាំ២០២០ នៅស្រុកត្រាំកក់; ៦.យុទ្ធសាស្ត្រពង្រឹងអំណាចអង្គការសងហគមន៍ (CBOs) ឆ្នាំ២០២០ សម្រាប់ឆ្នាំ២០១៩-២០២៣; ៧.កម្មវិធីបណ្តុះបណ្តាលថ្មីស្តីពីថវិកាឃុំនិងស្រុកឆ្នាំ២០២០ ៨.កម្មវិធីបណ្តុះបណ្តាលថ្មីស្តីពីការតស៊ូមតិសម្រាប់អ្នកលក់ដូរតាមដងផ្លូវឆ្នាំ២០២០ និង៩.ឯកសារសង្ខេបស្តីពីគោលនយោបាយស្តីពីអ្នកលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញឆ្នាំ២០២០។ល។

**សមិទ្ធផលនៃការរៃអង្គាសថវិកានៅឆ្នាំ២០២០** API បានរក្សាការគាំទ្រពីម្ចាស់ជំនួយពេញលេញសម្រាប់គម្រោងដែលកំពុងដំណើរការចំនួន ១២ ទោះបីមានបញ្ហាប្រឈមនៃកូវីដ-១៩ ក៏ដោយ។ គោលដៅរៃអង្គាសប្រាក់សម្រាប់ឆ្នាំ២០២០ និង២០២១ នឹងទទួលបានជោគជ័យប្រសិនបើដៃគូផ្តល់មូលនិធិមិនកែប្រែកិច្ចសន្យារបស់ពួកគេ។

**មេរៀនដែលបានរៀនសូត្រ ក្នុងស្ថានភាពកូវីដ-១៩៖** បណ្តាញអ៊ិនធ័រណែតនិងការប្រាស្រ័យទាក់ទងមានសារៈសំខាន់ណាស់សម្រាប់ការទំនាក់ទំនងនិងការអនុវត្តគម្រោងនិងជាវិធីសាស្ត្រល្អសម្រាប់ទាំងអង្គការ និងក្រុមអ្នកទទួលផលក្នុងទិសដៅអនាគត។

**បញ្ហាប្រឈម៖** API បានប្រឈមនឹងបញ្ហាសំខាន់ៗមួយចំនួននៅឆ្នាំ ២០២០ ដូចខាងក្រោម៖

១ ការផ្ទុះឡើង កូវីដ-១៩ បានបង្កឱ្យមានសកម្មភាពសំខាន់ៗដែលទាក់ទងនឹងការជួបប្រជុំគ្នាទល់មុខគ្នា អ្នកចូលរួមជាង ៣០ នាក់ ត្រូវបានពន្យាពេលការណាត់ជួប និងការសន្ទនាមួយចំនួនរវាងអ្នកលក់តាមចិញ្ចើមផ្លូវនិងអាជ្ញាធរមូលដ្ឋាននៅខណ្ឌនិងសង្កាត់ក្នុងរាជធានីភ្នំពេញ និងខេត្តផ្សេងៗមួយចំនួន។

២ ការរឹតត្បិតគម្រោងពីរដែលមិនផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងភ័ស្តុភារដល់អ្នកចូលរួមជាមន្ត្រីរដ្ឋាភិបាល អ្នកផ្តល់សេវា (ផ្នែកផ្គត់ផ្គង់) ជាបញ្ហាប្រឈមមន្ត្រីរដ្ឋាភិបាលឱ្យចូលរួមប្រកបដោយអត្ថន័យដល់សកម្មភាពគម្រោង។



៣ ការយឺតយ៉ាវក្នុងការតែងតាំងមន្ត្រី និងការដាក់ឱ្យដំណើរការជាផ្លូវការ ការកសាងសមត្ថភាពក្រុមការងាររបស់ ISAF ដែលមានសមាសភាពពីតំណាងរដ្ឋាភិបាល និងតំណាងអង្គការសង្គមស៊ីវិលនៅខេត្តគោលដៅថ្មីធ្វើឱ្យ សកម្មភាពគម្រោងមួយចំនួនមិនអាចអនុវត្តសកម្មភាពនៅមូលដ្ឋានសំខាន់ៗដែលបានគ្រោងទុក។

៤ មានគម្រោងមួយ ដំបូងត្រូវបានរៀបចំឡើងសម្រាប់ការអនុវត្តរយៈពេល ២ ឆ្នាំហើយបន្ទាប់មកត្រូវបានកាត់បន្ថយមកត្រឹមមួយឆ្នាំកន្លះ និងថែមវិសាលភាពការងារបន្ថែមទៀត ក្នុងកំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ-១៩ទៀត និងដោយសារការផ្លាស់ប្តូរកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងរដ្ឋាភិបាលស៊ុយអែតនិងកម្ពុជា។

៥ កិច្ចសហប្រតិបត្តិការរវាង API និងនាយកដ្ឋានពាក់ពន្ធ័របស់រដ្ឋាភិបាលដើម្បីគាំទ្រឃុំសង្កាត់គឺជាបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពគម្រោង ជាពិសេសលើការបណ្តុះបណ្តាលសិទ្ធិទទួលព័ត៌មាននិងការតស៊ូមតិដល់ក្រុមយុវជនដែលជាគុណតម្លៃស្នូលនិងជំនាញរបស់ API ដើម្បីចូលរួមក្នុងដំណើរការរៀបចំផែនការឃុំ សង្កាត់ និងថវិកា។ ដូច្នេះក្រុមការងារគម្រោងបានបង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដងក្នុងការដោះស្រាយបញ្ហាកិច្ចសហប្រតិបត្តិការ និងបញ្ហាសម្របសម្រួលកិច្ចព្រមព្រៀងដែលបានកែសម្រួលឡើងវិញជាមួយម្ចាស់ជំនួយ និងជ្រើសរើសបុគ្គលិកបុគ្គលិករយៈពេលខ្លីបន្ថែមទៀតដើម្បីបំពេញសកម្មភាពក្នុង រយៈពេលខ្លី។

៦ គម្រោងកសាងសមត្ថភាពដល់ក្រុមប្រឹក្សាមូលដ្ឋានគឺជាបញ្ហាប្រឈមដោយសារតែអាជ្ញាធរមូលដ្ឋានភាគច្រើនពួកគេមានវ័យចំណាស់មិនប្រើប្រាស់ទូរសព្ទ័ស្មាតហ្វូនទំនើបដោយសារចំណេះដឹងបច្ចេកទេសនៅមានកម្រិត។ ហេតុដូច្នេះហើយការតភ្ជាប់ទៅអ៊ីនធឺណិតនិងកម្មវិធីតាមអ៊ីនធឺណិតមួយចំនួនពិតជាពិបាកណាស់។ ការរៀនតាមឌីជីថលនិងកង្វះការតភ្ជាប់អ៊ីនធឺណិតទៅនឹងសេវាគ្របដណ្តប់សេវាទូរស័ព្ទចល័តនៅតែជាបញ្ហាប្រឈមចម្បងសម្រាប់អ្នករស់នៅតាមជនបទនៃប្រទេសកម្ពុជា។ ក្នុងន័យនេះ ការទទួលបានសម្ភារៈសិក្សាតាមអ៊ីនធឺណិត និងការទទួលបានព័ត៌មានតាមរយៈឧបករណ៍បច្ចេកវិទ្យាសង្គមដែលបង្កើតឡើងដោយគម្រោងនិងវេទិការាយការណ៍របស់ API មានការពិបាក។

នៅឆ្នាំក្រោយឆ្នាំ ២០២១ API នឹងអនុវត្តគម្រោងយ៉ាងហោចណាស់ចំនួន ១៥ ដែលបានរៀបរាប់ខាងលើដើម្បីរួមចំណែកដើម្បីទទួលបានលទ្ធផលនិងគោលដៅយុទ្ធសាស្ត្ររបស់ API ដើម្បីលើកម្ពស់សំឡេង និងសកម្មភាពប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តភាពនៅក្នុងប្រទេសកម្ពុជា។




## ២. វឌ្ឍនភាពតាមគម្រោងចូលរួមចំណែកសម្រេចលទ្ធផលជាយុទ្ធសាស្ត្រ

**លទ្ធផលទី ១៖**

**គោលនយោបាយនិងការអនុវត្តមានឥទ្ធិពលដើម្បីការពារសិទ្ធិនិងដោះស្រាយសេចក្តីត្រូវការរបស់ពលរដ្ឋជាពិសេសយុវជនស្ត្រីនិងក្រុមដែលជួបការលំបាកនិងមានលំហប្រជាធិបតេយ្យដើម្បីអនុវត្តសិទ្ធិរបស់ពួកគេ។**

**គម្រោងទី១៖** **សំឡេង និងសកម្មភាពប្រជាពលរដ្ឋសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៅប្រទេសកម្ពុជាឆ្នាំ២០១៩-២០២២**

**ផែនការយុទ្ធសាស្ត្រ API៖**
ឆ្នាំ២០១៩-២០២៣៖ ដើម្បីលើកកម្ពស់សិទ្ធិ និងសំឡេងប្រជាពលរដ្ឋដើម្បីអភិវឌ្ឍប្រកបដោយនិន្តរភាពនៅប្រទេសកម្ពុជា។

**ថវិកាគម្រោង៖**
៦៤៩,៣០០ អឺរ៉ូ ដោយ BfdW and DCA

**តំបន់គោលដៅ៖**
គម្រោងមានគោលដៅនៅ ខេត្តបន្ទាយមានជ័យ កំពង់ស្ពឺ កំពង់ធំ កណ្តាល កែប ក្រចេះ តាកែវ ពោធិ៍សាត់ និងរាជធានីភ្នំពេញ ជាសរុបមានចំនួន ៤០ស្រុក ក្រុង និង១ខណ្ឌ(ខណ្ឌនៃរាជធានីភ្នំពេញ)





## សកម្មភាព និងលទ្ធផលៈ

១.១ ពង្រឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍស្រុក ក្រុង ឃុំ សង្កាត់ ដើម្បីធានាបាននូវគណនេយ្យភាពចំពោះការផ្តល់សេវា និងការអនុវត្តថវិកាសំរាប់ប្រជាពលរដ្ឋ។ ជាសរុប មានអង្គការសហគមន៍មូលដ្ឋានចំនួន ១៦.២៥% (១៣ នៃ៨០) នៅក្នុងតំបន់គោលដៅបានលើកបញ្ហាសំខាន់របស់ពួកគេធ្វើការតស៊ូមតិទៅរដ្ឋាភិបាលថ្នាក់ជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ ពីការរៀបចំផែនការ និងថវិកានៅកម្រិតមូលដ្ឋានដែលមានក្រុមយុវជននចំនួន២០ឃុំ បានធ្វើការតស៊ូមិតិដើម្បីបង្កើនថវិកាឃុំសង្កាត់លើសេវាសង្គម ក្រុមស្រ្តីវ័យក្មេងលក់ដូរតាមដងផ្លូវនៃរាជធានីភ្នំពេញ និងការតស៊ូមតិដើម្បីអោយមានការបង្កើនការផ្តល់សេវាសាធារណៈលើបួនវិស័យនៅឃុំ សង្កាត់ មណ្ឌលសុខភាព សាលាបឋមសិក្សា និងប៉ុស្តិ៍ប៉ូលីសនៅក្នុង ៤ស្រុក និងច្រកចេញចូលតែមួយនៅក្នុង ៥ស្រុក។

១.២ ធ្វើការរចនាគេហទំព័រឡើងសារជាថ្មី និងមានការផ្សព្វផ្សាយពីការអនុវត្តគម្រោង ករណីសិក្សា និងការអនុវត្តល្អពីអង្គការAPI។ គេហទំព័រថ្មីបានដាក់អោយប្រើប្រាស់នៅខែកក្កដាឆ្នាំ ២០២០ ដោយមានការចូលរួមពីក្រុមប្រឹក្សាភិបាល ម្ចាស់ជំនួយ អ្នកទទួលផល ដៃគូអភិវឌ្ឍន៍ និងមានការកោតសរសើរ ចំពោះគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ API ។

១.៣ បង្កើតសេចក្តីណែនាំពីការពង្រឹងអំណាច និងយុទ្ធសាស្រ្តសំរាប់អង្គការសហគមន៍មូលដ្ឋាន។ អង្គការសហគមន៍មូលដ្ឋានសរុបចំនួន ៦២១ ត្រូវបានកំណត់អត្តសញ្ញាណនៅតាមតំបន់គោលដៅ។ អង្គការសហគមន៍មូលដ្ឋានចំនួន ៦៣ ត្រូវបានគាំទ្រដើម្បីបង្កើតផែនការតស៊ូមតិ។ អង្គការសហគមន៍ចំនួន ១៣ បានធ្វើការតស៊ូមតិដល់រដ្ឋាភិបាលថ្នាក់ជាតិ និងអាជ្ញាធរមូលដ្ឋានលើបញ្ហាៈ ១. សេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន ២. ផែនការឃុំ សង្កាត់ និងថវិកាសម្រាប់សេវាសង្គម ៣. បញ្ហាទាក់ទងនឹងជីវភាពរស់នៅរបស់អាជីវករស្រ្តីអ្នកលក់តាមចិញ្ចើមផ្លូវ ៤.បង្កើនសេវាសង្គម ៥.សេវារបស់ឃុំសង្កាត់ ៦.សេវារបស់មណ្ឌលសុខភាព ៧.សេវារបស់សាលាបឋមសិក្សា ៨.សេវារបស់ប៉ុស្តិ៍រដ្ឋបាលឃុំ ៩. សេវារបស់ការិយាល័យច្រកចេញចូលតែមួយ ១០.ផលប៉ះពាល់នៃ កូវីដ-១៩ សម្រាប់ក្រុមងាយរងគ្រោះនៅតំបន់ជនបទ និងក្នុងទីក្រុងជាពិសេស ជនមានពិការភាព ជនក្រីក្រ និងយុវជន។

## បទពិសោធន៍រៀនសូត្រៈ

១.៤ ក្នុងស្ថានភាព កូវីដ-១៩ ការរៀនសូត្រ និងទំនាក់ទំនងតាមប្រព័ន្ធអ៊ីនធឺណិតពិតជាមានសារៈសំខាន់ និង វិធីសាស្រ្តមួយដែលល្អសំរាប់ការអនុវត្តគម្រោងនៅពេលអនាគត។




## បញ្ហាប្រឈម៖

១.៥ សកម្មភាពភាគច្រើនត្រូវបានពន្យារពេលដោយសារការផ្ទុះឡើងនៃ កូវីដ-១៩ និងទឹកជំនន់។

១.៦ ភាគច្រើននៃអង្គការមូលដ្ឋានសហគមន៍គឺនៅតែមិនមាននិរន្តរភាពផ្នែកហិរញ្ញវត្ថុបាន ដូចនេះការផ្តល់ជំនួយផ្នែកការអភិវឌ្ឍន៍ស្ថាប័នពិតជាមានសារៈសំខាន់សំរាប់ការអនុវត្តគម្រោងនៅពេលអនាគត។

១.៧ សេរីភាពនៃការបញ្ចេញមតិត្រូវបានរឹតត្បិត បញ្ហានយោបាយមិនសូវបើកទូលាយ ដែលធ្វើអោយអង្គការសហគមន៍មូលដ្ឋានមានការភ័យខ្លាចក្នុងការតស៊ូមតិជាមួយរដ្ឋាភិបាល។ អង្គការសហគមន៍មូលដ្ឋានប្រមាណ ៦០ និងសកម្មជននយោបាយត្រូវបានចាប់ខ្លួន និងត្រូវបានរងបណ្តឹងពីរដ្ឋាភិបាល។

## ផែនការឆ្ពោះទៅមុខ៖

១.៨ ការអនុវត្តផែនការយុទ្ធសាស្ត្រឌីជីថល API និងការបង្កើតឧបករណ៍ផ្សេងៗ

១.៩ បង្កើត និងផ្តល់កម្មវិធីអភិវឌ្ឍន៍កសាងសមត្ថភាព (បណ្តុះបណ្តាល និងបង្វឹក)

១.១០ គាំទ្រ និងសម្របសម្រួលគំនិតផ្តួចផ្តើមការចូលរួម ឬការតស៊ូមតិតាមរយៈគម្រោងខ្នាតតូចនូវផែនការសកម្មភាពរបស់អង្គការសហគមន៍មូលដ្ឋានដើម្បីដោះស្រាយបញ្ហាសហគមន៍

១.១១ សម្របសម្រួលភាពជាដៃគូចំរុះ ការវិភាគគោលនយោបាយស្តីពីការផ្ទេរមុខងារក្នុងការអនុវត្ត និងការចូលរួមរបស់ពលរដ្ឋនៅថ្នាក់ស្រុកសម្រាប់ការត្រួតពិនិត្យ និងការចូលរួម។ គាំទ្រអង្គការសហគមន៍មូលដ្ឋានឱ្យចូលរួមនៅក្នុងសិក្ខាសាលាគោលនយោបាយថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីបែងចែកសម្រាប់សិទ្ធិរបស់ពលរដ្ឋ និងការចូលរួមរបស់អង្គការសហគមន៍ក្នុងអភិបាលកិច្ចមូលដ្ឋានជាពិសេសនៅថ្នាក់ស្រុក។

១.១២ យុទ្ធនាការផ្សព្វផ្សាយពីសិទ្ធទទួលព័ត៌ស្តីពីការទទួលបានព័ត៌មានសាធារណៈ

១.១៣ បង្កើតឧបករណ៍វិភាគថវិកា ការបណ្តុះបណ្តាលតាមអនឡាញ លើកកម្ពស់ការយល់ដឹងពីថវិកា និងថវិកាយេនឌ័រ។ វេទិកាសាធារណៈប្រចាំឆ្នាំនៃថវិកាស្រុកធ្វើការវិភាគថវិកា និងការយល់ដឹងជាសាធារណៈស្តីពីការបង្ហាញ និងចំណាយថវិកាជាតិនិងថ្នាក់ក្រោមជាតិ ការបង្ហាញការចំណាយ ការវិនិយោគឯកជន និងការបង្ហាញកិច្ចសន្យា គាំទ្រដល់អង្គការសហគមន៍មូលដ្ឋានសម្រាប់សិទ្ធិទទួលបានព័ត៌មាន និង CPDD សម្រាប់ការតស៊ូមតិលើច្បាប់សិទ្ធិទទួលបានព័ត៌មាន។



គម្រោងទី២៖ **ការជជែកដេញដោលរបស់យុវជនអំពីសិទ្ធិទទួលបានច្បាប់ព័ត៌មាន (២០១៩-២០២១)**

**គោលបំណងនៃគម្រោង៖**
ដើម្បីអភិវឌ្ឍសមត្ថភាពយុវជននិងអ្នកដឹកនាំយុវជនដើម្បីចូលរួមក្នុងការសន្ទនាគោលនយោបាយនិងច្បាប់សិទ្ធិទទួលបានព័ត៌មាន។

**ថវិកាគម្រោង៖**
SDC, DCA និង BftW, ២០២០ ជាមួយ ៨០,០០០ ដុល្លារ។

**ដៃគូអនុវត្ត៖**
មានអង្គការនិងសាកលវិទ្យាល័យជាង ២០ ដែលធ្វើការនិងចូលរួមជាមួយយុវជន

**តំបន់គោលដៅ៖**
ប្រទេសកម្ពុជា





## សកម្មភាព និងលទ្ធផលៈ

២.១ បានបណ្ដុះបណ្ដាលនិងផ្ដល់ការកសាងសមត្ថភាព ការជជែកវែកញែកពីសេចក្ដីព្រាងច្បាប់សិទ្ធិទទួលបានព័ត៌មានដល់តំណាងយុវជនពីគ្រប់រាជធានីខេត្ត។ ក្នុងខែកុម្ភៈមេដឹកនាំវ័យក្មេងប្រមាណ ៥៨ នាក់ត្រូវបានជ្រើសរើស (ស្រី ២៨ នាក់ និង ៧ នាក់ជាជនមានពិការភាពនិងយុវជនជនជាតិដើមភាគតិច ១០ នាក់) ដែលតំណាងឱ្យ ២៥ ខេត្តទូទាំងប្រទេស។ ការបណ្ដុះបណ្ដាលនិងការបង្វឹករយៈពេល ៣ ថ្ងៃលើច្បាប់សិទ្ធិទទួលបានព័ត៌មាន និងសៀវភៅណែនាំនិងខ្លឹមសារនៃការបណ្ដុះបណ្ដាលត្រូវបានរៀបចំឡើងដើម្បីកសាងនិងពង្រឹងសមត្ថភាពរបស់ពួកគេលើវិធីសាស្ត្រតស៊ូមតិនិងយុទ្ធសាស្ត្របញ្ចុះបញ្ចូលនិងយុទ្ធនាការសាធារណៈតាមរយៈវេទិកាប្រព័ន្ធផ្សព្វផ្សាយសង្គម និងការពិភាក្សាគោលនយោបាយជាមួយតំណាងរាស្ត្រនិងតំណាងរដ្ឋាភិបាល។

២.២ សមិទ្ធិផលគួរឱ្យកត់សំគាល់មួយទៀតគឺមេដឹកនាំដែលកំពុងត្រូវបានជ្រើសរើសដែលមានសមត្ថភាពអាចជួប និងមានការសន្ទនាគោលនយោបាយចំនួន ៣ដង ជាមួយស្ថាប័នរដ្ឋាភិបាលនិងស្ថាប័ននីតិប្បញ្ញត្តិមួយចំនួន។ ស្ថាប័នទាំងនោះរួមមានក្រសួងព័ត៌មាន ក្រសួងយុត្តិធម៌ និងមានអ្នកតាក់តែងច្បាប់និងតំណាងរាស្ត្រចំនួន ៤០ នាក់និងតំណាងដៃគូអភិវឌ្ឍន៍៥០ នាក់ ដែលបានចូលរួមក្នុងកិច្ចសន្ទនាគោលនយោបាយ។ ប្រការនេះបានបង្កើតបរិយាកាសអំណោយផលសម្រាប់មេដឹកនាំយុវជនទាំងនោះនិងតំណាងដើម្បីពិភាក្សា និងចែករំលែកការព្រួយបារម្ភរួម។ គួរកត់សម្គាល់ផងដែរថាវេទិកានេះក៏បានអនុញ្ញាតឱ្យយុវជនរបស់យើងធ្វើការអត្ថាធិប្បាយលើមាត្រាមួយចំនួនដូចជាមាត្រា ៩ មាត្រា ១៤ មាត្រា ២០ និងមាត្រា ២៩ នៃផ្នែកទី ២ នៅក្នុងសេចក្ដីព្រាងច្បាប់ស្ដីពីសិទ្ធិទទួលបានព័ត៌មាន។ តាមរយៈវិធីសាស្ត្ររួមនិងចូលរួមនេះយើងក៏ទទួលបានការឆ្លើយតបប្រកបដោយលក្ខណៈស្ថាបនា និងវិជ្ជមានពីសមាជិកសភាដែលបានធានាការប្ដេជ្ញាចិត្តរបស់ពួកគេក្នុងការអនុម័តសេចក្ដីព្រាងច្បាប់នេះសម្រាប់ផលប្រយោជន៍សាធារណៈនិងអភិបាលកិច្ចបើកចំហនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២.៣ API ក៏បានកត់ត្រាការចូលរួមនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមជាមួយនឹងមតិចូលរួមសាធារណៈ។ វីដេអូឃ្លីបរួមបញ្ចូលទាំងសំឡេងរបស់សម្ដេចនាយករដ្ឋមន្ត្រីបានសន្យាថា នឹងអនុម័តច្បាប់សិទ្ធិទទួលបានព័ត៌មាននៅត្រឹមឆ្នាំ ២០២០។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០២០ អ្នកប្រើប្រាស់ហ្វេសប៊ុកជាង ៣២៧,០០០ នាក់បានមើលឃ្លីបវីដេអូនេះហើយជាង ១១០០ នាក់បានចែករំលែកឃ្លីបនោះ។ ក្រៅពីនេះមានអ្នកលេងអ៊ីនធឺណិតច្រើនជាង ៤២៩,០០០ នាក់បានចូលមើលនិងភ្ជាប់ជាមួយទំព័រហ្វេសប៊ុក API និង គេហទំព័រសម្ព័ន្ធ CCIM សំឡេងប្រជាធិបតេយ្យ VoD ដែលបានផ្សាយកម្មវិធីវិទ្យុចំនួន ៩ ដង និងការរាយការណ៍ជាវីដេអូរយៈពេល ៤ នាទី។ អ្នកទាំងនោះនិយាយអំពីសារៈសំខាន់និងសិទ្ធិក្នុងការទទួលបានព័ត៌មានពីបញ្ហាផ្សេងៗគ្នា ហើយពួកគេត្រូវស្វែងរកការគាំទ្រពីសាធារណជនដើម្បីទាមទារឱ្យមានការអនុម័តច្បាប់ស្ដីពីសិទ្ធិទទួលព័ត៌មាន។ កម្មវិធីវិទ្យុនីមួយៗត្រូវបានចូលរួមដោយអ្នកជំនាញ ក្នុងវិស័យជាក់លាក់ និងតំណាងយុវជនដែលបានទទួលការបណ្ដុះបណ្ដាលអំពីសិទ្ធិទទួលបានព័ត៌មាន។



មនុស្សរាប់ពាន់នាក់បានមើលនិងចែករំលែកប្រធានបទនៃសិទ្ធិទទួលព័ត៌មានលើវិស័យនីមួយៗ ដូចជាសិទ្ធិទទួលបានព័ត៌មានលើវិស័យអប់រំ (២៩៩ នាក់បានមើលនិង ៦៥នាក់ បានចែករំលែក) សិទ្ធិទទួលបានព័ត៌មានលើវិស័យសុខភាព (២៦៦នាក់មើលនិង ១១៦នាក់ចែករំលែក) សិទ្ធិទទួលបានព័ត៌មានលើវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ (៦,៩០០នាក់មើលនិង ២៦នាក់ចែករំលែក) សិទ្ធិទទួលបានព័ត៌មានលើវិស័យបរិស្ថាន (៨,២០០នាក់មើលនិង ១៨ ចែករំលែក) សិទ្ធិទទួលបានព័ត៌មានលើវិស័យអភិបាលកិច្ច (៥,៦០០នាក់មើលនិង ១៩នាក់ចែករំលែក) សិទ្ធិទទួលបានព័ត៌មានលើជំងឺ កូវីត១៩ (ការមើលចំនួន ១៣០០០នាក់និង ៣២ចែករំលែក) សិទ្ធិទទួលបានព័ត៌មានលើជនជាតិដើមភាគតិច(៥,៦០០នាក់មើលនិង ២១នាក់ចែករំលែក) សិទ្ធិទទួលបានព័ត៌មានលើវិស័យពិការភាព (៤,៧០០នាក់មើលនិង ១៩ ចែករំលែក) និងស្ថានភាពបច្ចុប្បន្ននៃសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន (៤,៩០០នាក់បានមើលនិង ៤០ ចែករំលែក) ។ API បានដាក់សេចក្តីថ្លែងការណ៍មួយនិងឃ្លីបវីដេអូតស៊ូមតិមួយដែលអំពាវនាវឱ្យមានការអនុមត័ជាបន្ទាន់នូវសេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាន។ បន្ទាប់ពីការផ្សព្វផ្សាយជាសាធារណៈ មានប្រជាជនប្រមាណ ៩៣% នៃអ្នកប្រើប្រាស់ហ្វេសប៊ុកសរុប ១២.៥៧៧នាក់ដែលបានចូលរួមក្នុងការស្ទង់មតិនេះបានចែករំលែកទស្សនៈដូចគ្នាគាំទ្រនិងជំរុញឱ្យមានការអនុម័តច្បាប់នេះ។ សូមបញ្ជាក់ថាតំណាងគណៈកម្មការទាំង ១០ របស់រដ្ឋសភារួមទាំងអគ្គនាយកដ្ឋានស្រាវជ្រាវនៃព្រឹទ្ធសភានិងក្រសួងព័ត៌មានបានទទួលយក និងបង្ហាញការគាំទ្រយ៉ាងខ្លាំងចំពោះអនុសាសន៍ដែលត្រូវបានស្នើដោយតំណាងយុវជនចំនួន ៥៨ នាក់ (ស្រី ២៨ នាក់។ ជនមានពិការភាព ៧ នាក់និងជនជាតិដើមភាគតិច ១០ នាក់) នៅក្នុងការជជែកដេញដោលលើសេចក្តីព្រាងច្បាប់សិទ្ធិទទួលព័ត៌មាននេះ នៅថ្ងៃទី ២០ ខែមេសាឆ្នាំ ២០២០ នៅក្នុងកិច្ចប្រជុំក្រៅផ្លូវការ។

## បញ្ហាប្រឈម៖

២.៤ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០២០ ច្បាប់សិទ្ធិទទួលបានព័ត៌មានមិនទាន់ត្រូវបានអនុម័តនៅឡើយទេ សូម្បីតែសម្តេចនាយករដ្ឋមន្ត្រីហ៊ុនសែនក៏បានជំរុញជាសាធារណៈឱ្យពន្លឿនការអនុមត័ច្បាប់នេះ កាលពីថ្ងៃជួបជុំប្រចាំឆ្នាំជាមួយអ្នកសារព័តមានកាលពីថ្ងៃទី១៤ ខែមករាឆ្នាំ ២០២០ ។

## ផែនការឆ្ពោះទៅមុខ៖

២.៥ APIនឹងបន្តធ្វើការជាមួយយុវជនដើម្បីទទួលការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពដើម្បីធានាថាពួកគេមានសមត្ថភាព និងអាចតាមដានការសម្រេចចិត្តនិងអន្តរាគមន៍របស់រដ្ឋាភិបាលក្នុងការឆ្លើយតបទៅនឹងតម្រូវការនិងអនុសាសន៍របស់ពួកគេ។ សំខាន់ជាងនេះទៀត APIនឹងបង្កើតបរិយាកាស និងវេទិកាពិភាក្សាដែលមានលក្ខណៈអំណោយផលដូចជាការសន្ទនាគោលនយោបាយនិងវេទិកាដែលនឹងនាំមកនូវអ្នកតំណាងយុវជនដែលត្រូវបានជ្រើសរើសនិងសមាជិករដ្ឋាភិបាល និងអ្នកតាក់តែងច្បាប់ដើម្បីពិភាក្សាអំពីច្បាប់សិទ្ធិទទួលបានព័ត៌មាននេះបន្តទៀត។




## គម្រោងទី៣៖ វិទ្យាស្ថាន API ធ្វើជាលេខាធិការដ្ឋានអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ CPDD (២០១៩-២០២២)

វិទ្យាស្ថានAPI ធ្វើជាលេខាធិការដ្ឋានរបស់អង្គការ CPDD អស់រយៈពេល ២ឆ្នាំហើយ គឺចាប់ពីឆ្នាំ២០១៩ និងឆ្នាំ២០២០ ចាប់ពីចុងឆ្នាំ២០២០ សម្ព័ន្ធភាព CPDD ទទួលគម្រោងពី GIZ ដែលធ្វើសិក្សាលើយន្តការចូលរួមរបស់ប្រជាពលរដ្ឋនៅកម្រិតក្រុង/ស្រុក គោលដៅនៅខេត្តបាត់ដំបង។

### គោលបំណងនៃគម្រោង៖

គោលដៅរបស់អង្គការគឺ ដើម្បីលើកកម្ពស់សំឡេងរួម និងការចូលរួមប្រកបដោយអត្ថន័យរបស់សង្គមស៊ីវិលជាមួយរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ ដើម្បីពង្រឹងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ និងចូលរួមចំណែកក្នុងការអនុវត្តប្រកបដោយជោគជ័យនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ នៅក្នុងប្រទេសកម្ពុជា ដែលស្របទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។

### ថវិកាគម្រោង៖

GIZ ផ្តល់ថវិកាចំនួន ៦១,៦២៤ ដុល្លាអាមេរិក ២០២០-២០២១

### ដៃគូអនុវត្ត៖

អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ CPDD និងអង្គការក្រុមទ្រទ្រង់ភូមិ VSG

### តំបន់គោលដៅ៖

ទូទាំងប្រទេសកម្ពុជា





## សកម្មភាព និងលទ្ធផលៈ

៣.១ វិទ្យាស្ថាន API គាំទ្រលេខាធិការដ្ឋាន CPDD ដើម្បីអនុវត្តគម្រោងពង្រឹងយន្តការចូលរួមរបស់ពលរដ្ឋនៅថ្នាក់ស្រុក/ក្រុង ក្នុងខេត្តបាត់ដំបង ចាប់ពីចុងឆ្នាំ២០២០ ដល់ពាក់កណ្តាលឆ្នាំ២០២២ ដែលមានការឧបត្ថម្ភថវិកាដោយ GIZ។

៣.២ អង្គការ CPDD បានសហការជាមួយអង្គការ CCC រៀបចំវេទិកាអង្គការសង្គមស៊ីវិលក្រៅរដ្ឋាភិបាល និងបណ្តាញអង្គការក្រៅរដ្ឋាភិបាល ដើម្បីតស៊ូមតិលើការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីអង្គការក្រៅរដ្ឋាភិបាល។ អង្គការ CPDD បានចូលរួមយុទ្ធនាការតស៊ូមតិស្តីពីវិសោធនកម្មច្បាប់អង្គការសមាគម និងបានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់លើកទី១ ដល់ទី៦ រវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលស្តីពីការធ្វើវិសោធនកម្មច្បាប់សមាគម។ សេចក្តីថ្លែងការណ៍រួមត្រូវបានបង្កើតឡើងដោយអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាល ដែលមានចំណងជើងថា "កិច្ចប្រជុំពិគ្រោះយោបល់លើកទី៦ រវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ស្តីពីវិសោធនកម្មច្បាប់អង្គការសមាគម លើមាត្រាសរុបចំនួន១៧" ហើយវាត្រូវបានចេញផ្សាយដោយអង្គការ CPDD និងអង្គការ CCC ។

៣.៣ អង្គការ CPDD និងវិទ្យាស្ថាន API បានវិភាគលើសេចក្តីព្រាងច្បាប់ស្តីពីថវិកាឆ្នាំ២០២១ផ្តោតលើជំពូកថវិកាថ្នាក់ក្រោមជាតិនិងបានបង្កើតសេចក្តីថ្លែងការណ៍រួមគ្នាជាមួយក្រុមអង្គការសង្គមស៊ីវិលអំពីសេចក្តីព្រាងថវិកាឆ្នាំ២០២១ សំខាន់ជាងនេះ អង្គការ CPDD និង វិទ្យាស្ថាន API ក៏បានវិភាគលើផ្នែកថវិកាថ្នាក់ក្រោមជាតិផងដែរ និងបានបង្ហាញទៅរដ្ឋសភានិងតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣.៤ ជាការឆ្លើយតបទៅនឹង កូវីដ-១៩ អង្គការ CPDD និងអង្គការ CCC បានចេញសេចក្តីថ្លែងការណ៍មួយដើម្បីជម្រុញអង្គការសង្គមស៊ីវិល រដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានឱ្យផ្តល់អាទិភាពលើសុវត្ថិភាពប្រជាពលរដ្ឋជាពិសេសមនុស្សចាស់ កុមារ និងជនងាយរងគ្រោះដទៃទៀតដូចជា អ្នកក្រ និងជនមានពិការភាព។ ប្រជាជននៅឃុំចំនួនជាង៣០០ ត្រូវបានយល់ដឹង អំពីសារ និងវិធីសាស្រ្ត ការពារកូវីដ-១៩ តាមរយៈសកម្មភាពផ្សព្វផ្សាយគម្រោង។

៣.៥ កិច្ចប្រជុំសមាជិកអង្គការ CPDD ចំនួន២ដង និងការប្រជុំរបស់ក្រុមប្រឹក្សាភិបាលរបស់អង្គការ CPDD ចំនួន៥ដង ត្រូវបានរៀបចំឡើងដើម្បីផ្តល់ព័ត៌មានថ្មីៗស្តីពី ការអនុវត្តគម្រោងនានា ក្នុងកំឡុងពេលជំងឺរាតត្បាត កូវីដ-១៩ ហើយបានជ្រើសរើសនាយកប្រតិបត្តិ និងក្រុមប្រឹក្សាភិបាលថ្មី និងពិភាក្សាការដាក់សំណើរទៅ GIZ។

## ការរៀនសូត្រៈ

៣.៦ ការផ្ទុះឡើងនៃជំងឺ កូវីដ-១៩បាននាំមកនូវឱកាសដល់សមាជិកអង្គការCPDD ដើម្បីរៀនអនុវត្ត និងសម្របទម្លាប់ការងារថ្មីរបស់ពួកគេដោយធ្វើការពីចម្ងាយ និងប្រកាន់ខ្ជាប់នូវវិធានការណ៍ប្រុងប្រយ័ត្នជាងមុន។ សមាជិកអង្គការ CPDD មួយចំនួនបានពិនិត្យ និងកែសម្រួលយុទ្ធសាស្រ្តរបស់ពួកគេដើម្បីអនុលោមតាមគោលការណ៍សុវត្ថិភាពរបស់ជំងឺ កូវីដ-១៩ ។



## បញ្ហាប្រឈម៖

៣.៧ ភាគច្រើននៃសមាជិកអង្គការ CPDD ជាង៥០% ក្នុងនោះរួមមានលេខាធិការដ្ឋានរបស់អង្គការ CPDD កំពុងប្រឈមមុខនឹងកង្វះខាតថវិកា ដើម្បីអនុវត្តគម្រោងរៀងៗខ្លួនស្តីពីអភិបាលកិច្ចមូលដ្ឋាន និងកំណែទម្រង់គោលនយោបាយវិមជ្ឈការ ពីព្រោះម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍បានផ្លាស់ប្តូរការផ្តោតការយកចិត្តទុកដាក់របស់ខ្លួនដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតឡើងដោយជំងឺកូវីដ-១៩វិញ។ លេខាធិការដ្ឋានរបស់អង្គការ CPDD មិនមានថវិកាគ្រប់គ្រាន់ក្នុងការដំណើរការមុខងារលេខាធិការដ្ឋានរបស់ខ្លួនបានពេញលេញទេ។

## ផែនការឆ្ពោះទៅមុខ៖

៣.៨ វិទ្យាស្ថាន API ប្តេជ្ញាចិត្តធ្វើការគាំទ្រ និងធ្វើជាលេខាធិការដ្ឋានរបស់អង្គការ CPDD ដើម្បីអនុវត្តគម្រោងពង្រឹងយន្តការចូលរួមរបស់ពលរដ្ឋនៅថ្នាក់ស្រុក/ក្រុងគាំទ្រដោយ GIZ និងគម្រោងសហគ្រិនស្ត្រីវ័យក្មេងគាំទ្រដោយ Pact Cambodia អោយទទួលបានជោគជ័យនឹងបន្តគាំទ្រដល់កិច្ចប្រជុំសមាជិកអង្គការ CPDD តាមរយៈបណ្តាញអ៊ីនធឺណិត ឬជួបផ្ទាល់ ដើម្បីធ្វើឱ្យសមាជិកអង្គការCPDDបានប្រជុំ និងលើកបញ្ហារបស់ពួកគេដើម្បីដោះស្រាយ។ ធ្វើការពិនិត្យ និងគាំទ្រ លើគេហទំព័រ របស់អង្គការCPDD និងរៀបចំឯកសារស្របច្បាប់ដើម្បីទទួលបានការលើកលែងពន្ធ។

៣.៩ លេខាធិការដ្ឋានរបស់អង្គការ CPDD នឹងជួយសម្របសម្រួល និងបន្តចងក្រងករណីសិក្សាដោយផ្អែកលើបទពិសោធន៍របស់សមាជិកអង្គការសហគមន៍មូលដ្ឋាន និងអង្គការសង្គមស៊ីវិលនៃការចូលរួមជាមួយរដ្ឋបាលស្រុក/ក្រុងតាមរយៈយន្តការដែលមានស្រាប់ និងស្របតាមទិន្នន័យ ដែលប្រមូលបានពីការសំភាសន៍ជាមួយអង្គការសហគមន៍មូលដ្ឋាន ពលរដ្ឋនៅខេត្តបាត់ដំបង តាមរយៈគម្រោងពង្រឹងយន្តការចូលរួមរបស់ពលរដ្ឋនៅថ្នាក់ស្រុក/ក្រុង។ អង្គការ CPDD នឹងធ្វើការប្រឹក្សាយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងសមាជិកនៃអង្គការសង្គមស៊ីវិលដើម្បីឆ្លុះបញ្ចាំងពីយន្តការ ចូលរួមរបស់ពលរដ្ឋនៅកម្រិតស្រុក។ អង្គការ CPDD នឹងរៀបចំប្រជុំបណ្តាញ ដែលមានរយៈពេល ២ឆ្នាំម្តងនៅថ្នាក់ជាតិ ក៏ដូចជារៀបចំវេទិកាសង្គមស៊ីវិលវិស័យឯកជននិងវេទិកាភាពជាដៃគូ / ការប្រជុំរដ្ឋាភិបាលនៅខេត្តបាត់ដំបង សៀមរាប និងភ្នំពេញ។

៣.១០ អង្គការ CPDD គាំទ្រអង្គការសង្គមស៊ីវិល អង្គការមូលដ្ឋាន អង្គការសហគមន៍មូលដ្ឋាន ដើម្បីចូលរួមក្នុងអភិបាលកិច្ចល្អ/ ដំណើរការធ្វើសេចក្តីសម្រេចចិត្ត ។



**លទ្ធផលទី ២៖**

## ពង្រឹងសិទ្ធិអំណាចពលរដ្ឋ ដែលជួបការលំបាកក្នុងការបង្ហាញពីកង្វល់របស់ពួកគេ និងធ្វើឱ្យរដ្ឋាភិបាលមានគណនេយ្យភាព (២០១៩-២០២០)

**គម្រោងទី៤៖** **ការលើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យមូលដ្ឋាននៅកម្ពុជា**

### គោលបំណង៖

ការប្រើប្រាស់មតិយោបល់ដែលប្រមូលបានពីពលរដ្ឋតាមរយៈប័ណ្ណពិន្ទុដើម្បីពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងគណនេយ្យភាពសង្គម។ គោលបំណងរួមគឺដើម្បីពង្រឹងការចូលរួមរបស់ពលរដ្ឋ និងគណនេយ្យភាពសង្គមសម្រាប់លទ្ធផលអភិបាលកិច្ចក្នុងមូលដ្ឋាន។

### ថវិកាគម្រោង៖

១៦៥,០០០ ដុល្លារអាមេរិក ដោយ UNDEF

### ដៃគូអនុវត្ត៖

អង្គការទ្រទ្រង់ស្ត្រីខ្មែរខេត្តកំពង់ធំ (COWS) អង្គការទ្រទ្រង់ភូមិ (VSG) និង អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (CPDD)

### តំបន់គោលដៅ៖

ខេត្តបន្ទាយមានជ័យ និងខេត្តកំពង់ធំ





## សកម្មភាព និងលទ្ធផលៈ

៤.១ សមត្ថភាពរបស់ពលរដ្ឋមានការកើនឡើងក្នុងការត្រួតពិនិត្យ និងការដាក់ឥទ្ធិពលក្នុងដំណើរការរៀបចំកសាងផែនការថវិកា។ ៩១.៥%នៃយុវជនត្រូវបានបណ្តុះបណ្តាល (៤៣ នៃ ៤៧ នៃសិក្ខាកាម ៦៧.៤៤% ជាស្រ្តី) ពលរដ្ឋដែលបានចូលរួមដាក់ពិន្ទុវាយតម្លៃសេវាសាធារណៈទទួលបានជោគជ័យនូវការលើកឡើងពីតម្រូវការ និងក្តីបារម្ភហើយទទួលបានការឆ្លើយតបស្តែងនូវការទាមទារទាក់ទងនឹងការផ្តល់សេវាសាធារណៈក្នុងមូលដ្ឋាន។

៤.២ ផ្អែកលើលទ្ធផលនៃការស្ទង់មតិជាមួយអ្នកចូលរួមគម្រោងចំនួន ២១០នាក់ មាន៨៥% (៨២%ជាស្រ្តី) អ្នកឆ្លើយសំណួរទាំង អស់បានលើកឡើង ថាពួកគេបានយល់ពីដំណើរការដាក់ពិន្ទុ និងសារៈសំខាន់ពីតួនាទី និងទំនួលខុសត្រូវរបស់ពលរដ្ឋ អាជ្ញាធរមូលដ្ឋាន តួនាទីពលរដ្ឋចូលរួមត្រួតពិនិត្យក្នុងដំណើរការអភិវឌ្ឍន៍ និងប័ណ្ណដាក់ពិន្ទុពលរដ្ឋ និងការផ្តល់សេវាសាធារណៈ។ អ្នកចូលរួមសម្ភាសន៍បានលើកឡើងថាពួកគេបានទទួលព័ត៌មានសំខាន់ៗ យល់ដឹងពីឃុំ ការយកចិត្តទុកដាក់ ការចូលរួមជាងមុន បន្ថែមជាងនេះពួកគេសង្កេតឃើញថាឃុំមានការបើកចំហព័ត៌មាន និងគណនេយ្យភាព និងតម្លាភាពជាងមុន។

៤.៣ សមត្ថភាពអាជ្ញាធរមូលដ្ឋានក្នុងការផ្តល់សេវាសាធារណៈ និងឆ្លើយតបតម្រូវការរបស់ប្រជាពលរដ្ឋ។ ប្រមាណ ៩៥% នៃ៤៦នាក់ (ស្រី១៣នាក់) នៃមន្ត្រីមូលដ្ឋានដែលបានទទួលការបណ្តុះបណ្តាលដែលបានចូលរួមក្នុងដំណើរការអនុវត្ត ផែនការសកម្មភាពនៃប័ណ្ណពិន្ទុបានបង្ហាញពីភាពប្រសើរឡើងនៃឥរិយាបថក្នុងការផ្តល់សេវាសាធារណៈ។

៤.៤ សរុបចំនួន ៧៧%(ស្រី២៣នាក់) នៃក្រុមប្រឹក្សាជាស្រ្តីដែលបានទទួលការបណ្តុះបណ្តាល និងសមាជិកគណកម្មការស្រ្តីនិងកុមារ (អ្នកចូលរួម ៣៥ នាក់ក្នុងចំណោម ៤៥ នាក់) បានចូលរួមយ៉ាងសកម្មក្នុងដំណើរការអនុវត្ត ផែនការសកម្មភាពនៃប័ណ្ណពិន្ទុបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរការផ្តល់សេវានៅក្នុងតំបន់។





៤.៥ ភាពជាដៃគូរវាងរដ្ឋាភិបាល និងសង្គមស៊ីវិលក្នុងការឆ្លើយតបទៅនឹងតម្រូវការ និងការព្រួយបារម្ភជាសាធារណៈត្រូវបានពង្រឹង។ វាត្រូវបានគេរាយការណ៍ថា ៥០% នៃអ្នកឆ្លើយសំណួរបានកើនឡើង។ ក្នុងឆ្នាំ ២០១៨ មានតែ ៤០%នៃការឆ្លើយតប ១០១៩នាក់ (ស្រី ៥៩៩នាក់) បានពេញចិត្តនឹងការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋានចំពោះតម្រូវការ និងកង្វល់ជាសាធារណៈ។ ប៉ុន្តែនៅឆ្នាំ ២០១៩ ផ្អែកលើរបាការណ៍ពិន្ទុទី១ និងទី២ ឆ្នាំ ២០១៩ បានធ្វើឱ្យប្រសើរឡើងដល់ ៦០%នៃអ្នកឆ្លើយតប ១២១១ នាក់ (ស្រី ៦៩៥ នាក់)។

៤.៦ ១០០%សកម្មភាពអាទិភាពទាំង១៦ ដែលបានកំណត់នៅក្នុងផែនការសកម្មភាពថ្នាក់ឃុំ/សង្កាត់ទាំងបួនត្រូវបានអនុវត្តដើម្បីប្រមូលមូលនិធិក្នុងស្រុកដើម្បីគាំទ្រដល់ការអនុវត្តដោយជោគជ័យដោយមានការចូលរួមវិភាគទានចំនួន ៤២៥៧,៣៣$ ពីវិស័យឯកជន អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក អាជ្ញាធរមូលដ្ឋាន និងអង្គការសហគមន៍ និងចំនួន ៨,០០០$ពីអង្គការ UNDEF ។

៤.៧ ជោគជ័យ និងមេរៀនបទពិសោធន៍រៀនសូត្រ ជាពិសេសរបាយការណ៍ពលរដ្ឋដាក់ពិន្ទុវាយតម្លៃការផ្តល់សេវាសាធារណៈនៅមូលដ្ឋានត្រូវបានចែករំលែកនៅក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពី "ការរៀនពីគណនេយ្យភាពសង្គមនៅកម្ពុជា" ដោយមានអ្នកចូលរួមសរុបចំនួន ៦៤ នាក់ (ស្រី ២០ នាក់) ជាសមាជិក CPDD និងអ្នកពាក់ព័ន្ធសំខាន់ៗរបស់គម្រោង ISAF និងISAC ក្នុងការអនុវត្តគម្រោង។





**គម្រោងទី៥៖** លើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការ និងថវិកានៅរដ្ឋបាលឃុំសង្កាត់ (២០១៩-២០២១)

### គោលបំណង៖

ដើម្បីលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើររៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ជាពិសេសការឆ្លើយតបតម្រូវការរបស់យុវជនស្ត្រី កុមារ ជនមានពិការភាព និងជនងាយរងគ្រោះ។

រដ្ឋបាលឃុំ និងសង្កាត់ទទួលយកបញ្ហារបស់យុវជនដាក់ចូលក្នុងផែនការឃុំ និងបង្កើនធនធានបន្ថែមសំរាប់សេវាសង្គមដើម្បីបង្កើនសុខមាលភាពរបស់ប្រជាពលរដ្ឋ។

### ថវិកាគម្រោង៖

៦១,៦២៤ ដុល្លារអាមេរិក គាំទ្រដោយ SIDA/UNICEF

### ដៃគូអនុវត្ត៖

អង្គការ UNICEF

### តំបន់គោលដៅ៖

រាជធានីភ្នំពេញ ខេត្តកណ្តាល និង ក្រចេះ





## សកម្មភាព និងលទ្ធផលៈ

៥.១ អ្នកដឹកនាំអង្គការសហគមន៍មូលដ្ឋាន(CBOs) និងតំណាង កើនសមត្ថភាពលើការវិភាគថវិកាផែនការនៅតាមស្រុកគោលដៅ។ ការអនុវត្តគម្រោងនាពេលកន្លងមកបានទទួលលទ្ធផលគួរឱ្យកត់សម្គាល់ មានតំណាងយុវជនចំនួន ៨២នាក់ (ស្ត្រី៥៣) បានទទួលវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពពីគម្រោង។ នៅចុងឆ្នាំ២០២០ **គម្រោងបានសម្រេចគោលដៅ ១០១% ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលកសាងសមត្ថភាព** ដល់តំណាងយុវជន និងពួកគេបានចូលរួមជាមួយដំណើរការរៀបចំ និងកសាងអភិវឌ្ឍន៍ឃុំ សង្កាត់។

សកម្មភាពបានចាប់ផ្តើមជាមួយការប្រជុំផ្សព្វផ្សាយគម្រោងនៅតំបន់គោលដៅទាំងបួន ដោយមានអជ្ញាធរ ១៤៤រូប (ស្ត្រី៥៣) និងមន្ត្រីក្រសួងមហាផ្ទៃ។ ពួកគេក៏បានចូលរួមក្នុងការពិភាក្សាពីសារៈសំខាន់ពីការចូលរួមរបស់យុវជន ក្នុងដំណើរការរៀបចំ និងកសាងអភិវឌ្ឍន៍ឃុំ សង្កាត់ដើម្បីការអភិវឌ្ឍន៍សហគមន៍របស់ពួកគេ។ អាជ្ញាធរមូលដ្ឋានក៏ផ្តល់សារៈសំខាន់នៃការចូលរួមរបស់យុវជនផងដែរ។ ហើយក៏មានការប្រជុំដើម្បីជ្រើសរើសតំណាងយុវជន ដែលមានយុវជន ៩៧នាក់ (ស្ត្រី៦១) ត្រូវបានជ្រើសរើសជាតំណាងយុវជនតាមឃុំ។ មានយុវជន ប្រហែលជា២៥% នៃតំណាងយុវជនបានចូលរួមប្រជុំប្រចាំខែជាមួយក្រុមប្រឹក្សាឃុំ និងមានយុវជន ១២.៥% ក្នុងចំណោមយុវជន៨២នាក់ត្រូវបានដាក់ចូលជាតំណាងយុវជនក្នុងសមាសភាពគណកម្មការផែនការ និងថវិកា។ គម្រោងបានផ្តល់វគ្គបណ្តុះបណ្តាល និងបង្កើតឯកសារបង្រៀនជោគជ័យ១០០%។ វគ្គបណ្តុះបណ្តាលមានរយៈពេល៣ថ្ងៃពីដំណើរការរៀបចំ និងកសាងអភិវឌ្ឍន៍ឃុំ សង្កាត់ ការវិភាគថវិកា និងការអនុវត្តសេវាសង្គម និងជំនាញទន់ដល់តំណាងយុវជន ៨២នាក់ (ស្ត្រី៥០)។

៥.២ ឧបករណ៍វិភាគថវិកា ការកំណត់បញ្ហា និងយុទ្ធសាស្ត្រសំរាប់ស្វែងការការគាំទ្រមតិដើម្បីឱ្យយុវជនចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍ និងថវិកា និងអនុវត្ត។ ផែនការតស៊ូមតិរបស់ក្រុមយុវជនចំនួន២០ បានបង្កើតឡើងដោយក្រុមយុវជន៖ អនុសាសន៍របស់យុវជនត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ដើម្បីបង្កើនការផ្តល់សេវាសង្គមនៅមូលដ្ឋាន។ យើងមិនត្រឹមតែផ្តល់វគ្គបណ្តុះបណ្តាលដល់តំណាងយុវជន យើងក៏បានផ្តល់ការបង្ហាត់បង្ហាញដល់តំណាងយុវជនពីការប្រើប្រាស់បណ្តាញសង្គមសំរាប់ការទំនាក់ទំនងក្នុងក្រុម ដោយមានការបង្កើតក្រុមក្នុងបណ្តាញសង្គម (គ្រុបតេឡេក្រាម២ក្រុម និង ហ្វេសប៊ុកគ្រុប២គ្រុប) ដើម្បីការទំនាក់ទំនងក្នុងក្រុម និងចែករំលែកបទពិសោធន៍ពីការចូលរួមអភិវឌ្ឍន៍នៅមូលដ្ឋាន។

៥.៣ កម្រិតថ្នាក់ជាតិ៖ ដោយមានការសម្របសម្រួលពីអង្គការ UNICEF ក្នុងបង្កើតទម្រង់ថវិកាសម្រាប់ពលរដ្ឋ ដើម្បីចូលរួមដំណើរការរៀបចំផែនការថវិកា ជាពិសេសលើកកម្ពស់ការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការ និងថវិកា។ អង្គការ API បានរៀបចំការពិគ្រោះទម្រង់ថវិកាប្រជាពលរដ្ឋជាមួយអាជ្ញាធរ យុវជន និងពលរដ្ឋតាមរយៈការពិគ្រោះយោបល់ជាមួយអជ្ញាធរមូលដ្ឋាន និងយុវជន៨០ (ស្ត្រី៤៥)។ ហើយទម្រង់ថវិកាត្រូវបានការកែប្រែ បន្ទាប់ពីការពិគ្រោះយោបល់ និងបានផ្សព្វផ្សាយជាផ្លូវការដោយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅចុងឆ្នាំ២០២០ ដោយសាកល្បងអនុវត្តនៅស្រុកគោលដៅទាំង៤ មាន ២០ឃុំ។



## បញ្ហាប្រឈម៖

៥.៤ វាមានសារៈសំខាន់ក្នុងការសហការជាមួយអាជ្ញាធរថ្នាក់ជាតិ និងក្រោមជាតិ និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីងាយស្រួលក្នុងការសហការជាមួយយុវជន ជាពិសេសជាមួយសិស្សអនុវិទ្យាល័យ។

៥.៥ គម្រោងបង្កើតឡើងសំរាប់រយៈពេលពីរឆ្នាំ តែត្រូវផ្លាស់ប្តូរមកត្រឹម១ឆ្នាំកន្លះ ដោយត្រូវបញ្ចប់ពាក់កណ្តាលឆ្នាំ២០២១ ដោយសារបរិបទនយោបាយ ដែលប្រទេសស៊ុយអែតជាម្ចាស់ជំនួយបញ្ចប់ជំនួយនៅកម្ពុជាជាមួយរដ្ឋាភិបាលនាពេលដ៏ខ្លីខាងមុខនេះ។ ដូច្នេះគម្រោងត្រូវអនុវត្តសកម្មភាពទាំងអស់មុនគម្រោងចប់ពាក់កណ្តាលឆ្នាំ២០២១។

៥.៦ ពេលវេលារបស់យុវជនធ្វើសកម្មភាព និងក្រុមប្រឹក្សាឃុំមិនស្របគ្នា។ យុវជនមានពេលទំនេរតែពេលចុងសប្តាហ៍ដែល កត្តាពិបាកក្នុងការចូលរួមរបស់យុវជនក្នុងការងារឃុំក្នុងថ្ងៃធ្វើការ។និងយុវជនមួយចំនួននៅតែមិនមានទំនុកចិត្តក្នុងចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន។

## ផែនការឆ្ពោះទៅមុខ៖

៥.៧ បង្កើនជំនាញ និងចំនេះដឹងដល់តំណាងយុវជននៅតាមឃុំគោលដៅ

៥.៨ គាំទ្រ និងលើកទឹកចិត្តអ្នកតំណាងយុវជនឱ្យចូលរួមនិងតាមដានដំណើរការរៀបចំផែនការនិងថវិកាក្នុងមូលដ្ឋាន

៥.៩ គាំទ្រដំណើរការក្រុមហ្វេសប៊ុកយុវជន (Youth Facebook Group) ក្នុងការទំនាក់ទំនងជាមួយសមាជិករបស់ពួកគេលើដំណើរការរៀបចំផែនការកាលវិភាគនិងព័ត៌មានសាធារណៈលើបញ្ហាថវិកានិងសេវាសង្គមរបស់ឃុំ

៥.១០ បង្កើនការសហការរវាងអាជ្ញាធរមូលដ្ឋានថ្នាក់ក្រោមជាតិ។




**គម្រោងទី៦៖** **គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ (OW4C) (២០១៩-២០២២)**

អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ជាដៃគូជាមួយក្រុមហ៊ុន Nickol Global Solution (NGS) និងអង្គការ InSTEDD នឹងកំណត់ ផលិត និងផ្សព្វផ្សាយប្រព័ន្ធបច្ចេកវិទ្យាដែលនឹងលើកកម្ពស់ការយល់ដឹងជាសាធារណៈកាន់តែទូលំទូលាយ អំពីសេវារបស់ការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យពលរដ្ឋ។ អង្គការវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API) ក៏នឹងបង្កើតឧបករណ៍ត្រួតពិនិត្យនានា ដែលពលរដ្ឋ និងវិស័យឯកជនអាចដាក់ពិន្ទុ និងរាយការណ៍អំពីប្រសិទ្ធភាព និងការពេញចិត្តនៃការផ្តល់សេវាសាធារណៈនៅក្នុងសហគមន៍របស់ពួកគេ។ លទ្ធផលនៃការដាក់ពិន្ទុនេះ នឹងជួយអាជ្ញាធរ និងមន្ត្រីរដ្ឋាភិបាលក្នុងការវាស់វែងប្រសិទ្ធភាព និងវឌ្ឍនភាពនៃការផ្តល់សេវា និងការឆ្លើយតបចំពោះតម្រូវការសេវាសាធារណៈ។

### គោលបំណង៖

បង្កើនសមត្ថភាពសង្គមស៊ីវិលដើម្បីធ្វើឱ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចូលរួមដំណើរការនីតិវិធីគោលនយោបាយតាមរយៈការធ្វើកិច្ចអន្តរាគមន៍សាកល្បងជាបន្តបន្ទាប់រួមទាំងការរចនា និងការអនុវត្តនូវឧបករណ៍បច្ចេកវិទ្យាព័ត៌មានការផ្សព្វផ្សាយ និងសកម្មភាពចូលរួមផងដែរ។

### ថវិកាគម្រោង៖

API ទទួលបានថវិកាចំនួន ៤៦១,៨១៩ ដុល្លាពីទីភ្នាក់ងារ USAID សម្រាប់អនុវត្តសកម្មភាពពីខែតុលាឆ្នាំ ២០១៩ ដល់ខែកញ្ញាឆ្នាំ ២០២២ ។

### ដៃគូអនុវត្ត៖

API និង InSTEDD (អង្គការទាំងពីរគឺជាដៃគូដែលដឹកនាំដោយក្រុមហ៊ុន Nickol Global Solutions)។

### តំបន់គោលដៅ៖

ការិយាល័យច្រកចេញចូលតែមួយនៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យនិងខេត្តកំពង់ឆ្នាំង។




## សកម្មភាព និងលទ្ធផល៖

៦.១ គម្រោងបានធ្វើការផ្សព្វផ្សាយទៅអ្នកទទួលផលលើសពីផែនការដែលបានគ្រោង តាមរយៈការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យា ដោយផ្អែកលើលទ្ធផលនៃការចូលរួមរបស់សង្គមស៊ីវិល។ ក្រុមអ្នកទទួលផលដែលបានគ្រោងមានចំនួនសរុបចំនួន ២៥៩៣នាក់ (ស្មើ ៥០ភាគរយជាស្ត្រី) ប៉ុន្តែជាក់ស្តែង គឺមានអ្នកចូលរួមចំនួន ៣០៣៩ នាក់ (១១៧ ភាគរយ) ដែលមានស្ត្រីចូលរួមចំនួន១៧៣៧ នាក់។

៦.២ គម្រោងបានធ្វើការជ្រើសរើសក្រុមយុវជនដើម្បីកសាងសមត្ថភាព និងទទួលបានលទ្ធផលគួរឱ្យកត់សម្គាល់។ យុវជនប្រហែលពីរទៅបីរយនាក់បានដាក់ពាក្យតាមរយៈប្រព័ន្ធបណ្តាញសង្គម និងប្រព័ន្ធអេឡិចត្រូនិចដើម្បីចូលរួមកក្នុងការសិក្សារៀនសូត្រជាមួយគម្រោង។ ជាលទ្ធផលក្រុមយុវជនសរុបចំនួន ៤៧ នាក់ ក្នុងនោះស្រីចំនួន ២៧នាក់ ត្រូវបានជ្រើសរើសជាក្រុមយុវជនអ្នកស្ម័គ្រចិត្ត និងទទួលបានការបណ្តុះបណ្តាលពីគម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ។ ក្រុមយុវជនដែលបានជ្រើសរើសទទួលបានការបណ្តុះបណ្តាល និងបង្ហាត់បង្ហាញ ជាច្រើនប្រធានបទទាក់ទងទៅនឹងមុខងាររបស់ការិយាល័យច្រកចេញចូលតែមួយ តួនាទី និងការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋ ការប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យា IVR និង Facebook Chatbot (ប្រព័ន្ធឆ្លើយតបសារជាសំឡេង និងប្រព័ន្ធឆ្លើយតបសារជាអក្សរ ទាក់ទងនឹងសេវាច្រកចេញចូលតែមួយ) ក្រៅពីនោះក្រុមយុវជនក៏ទទួលបានការបណ្តុះបណ្តាលផងដែរ អំពីរបៀបនៃការសម្ភាសន៍ និងការចុះប្រមូលទិន្នន័យតាមប្រព័ន្ធអេឡិចត្រូនិច របៀបចុះផ្សព្វផ្សាយតាមខ្នងផ្ទះ និងការអនុវត្តយុទ្ធនាការចុះផ្សព្វផ្សាយតាមខ្នងផ្ទះពីផ្ទះមួយទៅផ្ទះមួយស្តីពីសេវាច្រកចេញចូលតែមួយ។ ផ្អែកលើលទ្ធផលនៃការវាយតម្លៃខ្លួនឯងក្រោយវគ្គបណ្តុះបណ្តាល អ្នកចូលរួមមានការយល់ដឹងពី ៧០ភាគរយ ទៅ ១០០ ភាគរយទៅតាមប្រធានបទផ្សេងៗគ្នា។ បន្ទាប់ពីវគ្គបណ្តុះបណ្តាលត្រូវបានបញ្ចប់ រួមទាំងការអនុវត្តផ្ទាល់នៅសហគមន៍ក្រុមយុវជនក៏ទទួលបានវិញ្ញាបនបត្របញ្ជាក់ការសិក្សាពីគម្រោងផងដែរ។ ផ្អែកលើលទ្ធផលនៃការធ្វើតេស្តសាកល្បងក្រោយវគ្គបានបង្ហាញថាអ្នកចូលរួមមានការយល់ដឹងខ្ពស់គឺ ៩១.៩៤ ភាគរយ។

៦.៣ **លើកកំពស់ការយល់ដឹង និងគណនេយ្យភាពនៅការិយាល័យច្រកចេញចូលតែមួយ៖** គម្រោងបានធ្វើការស្ទង់មតិដោយចុះប្រមូលទិន្នន័យដើមគ្រា ផ្អែកលើផែនការគម្រោងដែលបានរៀបចំដើម្បីបានជាទន្នន័យមូលដ្ឋានមុនការអនុវត្តគម្រោង។ ការធ្វើសំណួរស្ទង់មតិទៅលើប្រជាពលរដ្ឋចំនួន ៤៩៩ នាក់ ក្នុងស្រុកគោលដៅជាលទ្ធផលដែលបានមកពីស្ទង់មតិបានបង្ហាញថាអ្នកទទួលផលមានតែ ២៦ ភាគរយប៉ុណ្ណោះ (គោលដៅគឺ ៥០ ភាគរយ) ដែលបានស្គាល់ពីសេវាដែលមាននៅការិយាល័យច្រកចេញចូលតែមួយយ៉ាងហោចណាស់បីសេវា។ ការវិភាគ និងការរក្សាទិន្នន័យអាចរកបានតាមរយៈដំណោះស្រាយបច្ចេកវិទ្យាដែលគាំទ្រថវិកាដោយសហរដ្ឋអាមេរិក ដែលជាផ្នែកមួយនៃសកម្មភាពរបស់គម្រោង។

៦.៤ លើសពីនេះទៀត ការកើនឡើងនូវការយល់ដឹងអំពីសេវាច្រកចេញចូលតែមួយនឹងត្រូវបានរាយការណ៍ ហើយរបៀបនៃការផ្តល់យោបល់ត្រឡប់អំពីការផ្តល់សេវានឹងត្រូវបានកត់ត្រាទុក។ ការវាយតម្លៃត្រូវបានធ្វើឡើងលើអ្នកចូលរួមសរុបចំនួន ៤៤០ នាក់ (ស្រី ២១២ នាក់)។ វេទិកាសាធារណៈចំនួន២៦វេទិកា ដែលបានរៀបចំក្នុង២៦ ឃុំសង្កាត់ផ្សេងៗគ្នា អ្នកចូលរួមទទួលបានការផ្សព្វផ្សាយពីប្រព័ន្ធបច្ចេកវិទ្យាតាមរយៈ IVR និង



Facebook Chatbot (ប្រព័ន្ធឆ្លើយតបសារជាសំឡេង និងប្រព័ន្ធឆ្លើយតបសារជាអក្សរ ទាក់ទងនឹងសេវាច្រកចេញចូលតែមួយ)។ សំណួរសរុបចំនួន៩៩សំណួរដែលបានលើកឡើងដោយអ្នកចូលរួមក្នុងកំឡុងពេលធ្វើវេទិកាសាធារណៈ ហើយក្នុងនោះ៨៨សំណួរត្រូវបានឆ្លើយតបដោយតំណាងការិយាល័យច្រកចេញចូលតែមួយ។ សំណួរទាំងអស់នោះភាគច្រើនពាក់ព័ន្ធនឹងការដាក់ពាក្យសុំធ្វើស្លាកម៉ូតូ ឡាន នីតិវិធីនៃការបើកអាជីវកម្មការបញ្ជាក់លើសញ្ញាប័ត្រ សៀវភៅគ្រួសារ និងការផ្ទេរកម្មសិទ្ធិដីធ្លីជាដើម។

៦.៥ ក្រុមការងារគម្រោងបានធ្វើការតាមដានចំពោះសំណួរ និងមតិយោបល់ដែលបានលើកឡើងដោយប្រជាពលរដ្ឋដែលធ្លាប់ប្រើប្រាស់សេវាការិយាល័យច្រកចេញចូលតែមួយ។ លទ្ធផលបានបង្ហាញថាប្រមាណ ៧៩% (សកម្មភាពនិងអនុសាសន៍ចំនួន ៥០ ក្នុងចំណោម ៦៣) ត្រូវបានចែករំលែក និងបង្ហាញនៅក្នុងកិច្ចប្រជុំក្រុមការងារគណនេយ្យភាព ច្រកចេញចូលតែមួយចំនួន ៦ប្រជុំ នៅក្នុង៤ស្រុក និង១ក្រុង ហើយជាលទ្ធផលអ្នកផ្តល់សេវាមានការផ្លាស់ប្តូរឥរិយាបថផងដែរ។

៦.៦ គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ បានបង្កើតនូវឧបករណ៍បច្ចេកវិទ្យាដើម្បីលើកកម្ពស់ការយល់ដឹងនិងគណនេយ្យភាពលើការិយាល័យច្រកចេញចូលតែមួយនៅខេត្តបាត់ដំបង។ កាបង្កើតនូវឧបករណ៍បច្ចេកវិទ្យា IVR និង Facebook Chatbot (ប្រព័ន្ធឆ្លើយតបសារជាសំឡេង និងប្រព័ន្ធឆ្លើយតបសារជាអក្សរទាក់ទងនឹងសេវាច្រកចេញចូលតែមួយ) ដើម្បីទទួលបាននូវតម្លាភាពកាន់តែប្រសើរឡើងសម្រាប់ពលរដ្ឋលើព័ត៌មានដែលទាក់ទងទៅនឹងសេវាកម្មដែលផ្តល់នៅការិយាល័យច្រកចេញចូលតែមួយ។ ឧបករណ៍បច្ចេកវិទ្យាការឆ្លើយតបសារជាសំឡេង (IVR) មានខ្សែទូរស័ព្ទចំនួនពីរប្រព័ន្ធ៖ ០៩៥ ៨៨៨ ១៥៩ និង ០៨៨ ៩៨ ៨៨ ១៥៩ និង ទំព័រហ្វេកប៊ុកដោយគ្រាន់តែសរសេរពាក្យ **pidor@OW4Cbot** ឬ **ពិដោរអ្នកភូមិឆ្លាតវៃ** ដែលប្រព័ន្ធនេះអាចផ្តល់ព័ត៌មានដល់ប្រជាជនយ៉ាងឆាប់រហ័សចំពោះព័ត៌មានដែលចង់ស្វែងរក។ លើសពីនេះទៀតឧបករណ៍ទាំងនេះក៏អនុញ្ញាតឱ្យពលរដ្ឋផ្តល់មតិយោបល់អនាមិកលើគុណភាពនៃការផ្តល់សេវា ដែលពួកគេបានទទួលនិងកំណត់ពីតំបន់ដែលចង់កែលំអ។ ការបើកដំណើរការឧបករណ៍បច្ចេកវិទ្យានៅថ្ងៃទី ២៧ ខែសីហាឆ្នាំ ២០២០ រហូតមកដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០នេះ ចំនួនអ្នកប្រើប្រាស់បានកើនឡើងចំនួន ៣៦២០ នាក់ ក្នុងនោះ៥២% នៃអ្នកប្រើប្រាស់គឺជាស្រី។ គិតចាប់ពីកាលបរិច្ឆេទនៃការរាយការណ៍មក ពលរដ្ឋកម្ពុជាចំនួន ៧៨៦ នាក់បានប្រើប្រាស់ប្រព័ន្ធសារជាសំឡេង និង២៨៣៤នាក់ បានប្រើប្រាស់នូវប្រព័ន្ធហ្វេកប៊ុកឆាតប៊ិត ចាប់តាំងពីការបើកដំណើរការនៅថ្ងៃទី ២៧ ខែសីហាឆ្នាំ ២០២០។ ឧបករណ៍ទាំងពីរនេះអាចផ្តល់នូវសេវាសំខាន់ៗបី ទី១គឺការផ្តល់ព័ត៌មានពីការបំពេញពាក្យស្នើរសុំតម្លៃសេវា និងរយៈពេលនៃការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ ទីពីរគឺការតាមដានឯកសារ (មានតែស្រុកកំរៀងតែប៉ុណ្ណោះ) និងទីបីគឺការផ្តល់មតិយោបល់ត្រឡប់របស់ប្រជាពលរដ្ឋលើការផ្តល់សេវារបស់ការិយាល័យច្រកចេញចូលតែមួយ។ សេវាដែលទទួលបានការពេញនិយម និងស្នើសុំច្រើនជាងគេនោះគឺការសាកសួរព័ត៌មានអំពីសេវាការិយាល័យច្រកចេញចូលតែមួយ (៧១%) បន្ទាប់មកគឺការផ្តល់មតិយោបល់ត្រឡប់របស់អ្នកប្រើប្រាស់សេវា (១៧%) និងការតាមដានឯកសារ (១២%)។ សេវាការតាមដានសំបុត្រគឺមានការពេញនិយមដោយមានអ្នកប្រើប្រាស់ចំនួន២៨២នាក់ មកពីខាងស្រុកកំរៀងបានប្រើប្រាស់សេវានេះ។



៦.៧ ទោះបីជាយ៉ាងណាក៏ដោយ មានពាក្យបណ្តឹងតិចតួចដែលត្រូវបានកត់ត្រាចូលទៅកាន់តំណាងការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ។ យោងតាមរបាយការណ៍មានពាក្យបណ្តឹង និងមតិយោបល់ត្រឡប់ចំនួន ៨៦ ត្រូវបានកត់ត្រាទុកនៅការិយាល័យប្រជាពលរដ្ឋនៅក្នុងឆ្នាំ ២០២០ (របាយការណ៍ការិយាល័យប្រជាពលរដ្ឋ ឆ្នាំ ២០២០)។

៦.៨ កាលពីពេលថ្មីៗនេះឆ្នាំ(២០១៨-២០១៩) គម្រោងបានធ្វើការស្ទង់មតិរបស់អ្នកប្រើការិយាល័យច្រកចេញចូលតែមួយតាមរយៈការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចលើការបំពេញការងាររបស់ ការិយាល័យច្រកចេញចូលតែមួយ។ យុវជនដែលទទួលបានការបណ្តុះបណ្តាល បានសម្ភាសន៏ពលរដ្ឋចំនួន ១៥៩ នាក់ (ស្រី ៨១ នាក់) ដោយសួរសំណួរតាមរយៈប្រព័ន្ធអេឡិចត្រូនិចបានសម្ភាសន៍ ប្រជាពលរដ្ឋម្តងម្នាក់ៗ រយៈពេល ១០ នាទីសម្រាប់អ្នកចូលរួមម្នាក់ៗក្នុងកំឡុងពេលប្រជុំធ្វើប័ណ្ណដាក់ពិន្ទុស្តីពីសេវាច្រកចេញចូលតែមួយ។ លទ្ធផលសំខាន់ៗដែលទទួលបានគឺ៖ ២១% រង់ចាំយូរ ការបំពេញឯកសារមានភាពស្មុគស្មាញ ម៉ោងបំពេញការងាររបស់មន្ត្រីច្រកចេញចូលតែមួយ ៥២% អាចទទួលយកបាននិង ៨% ពេញចិត្តណាស់។ ៤៩% ថ្លៃសេវាអាចទទួលយកបាននិង ១២% ពេញចិត្តបំផុត។ ឥរិយាបថរបស់មន្ត្រីការិយាល័យច្រកចេញចូលតែមួយ៖ ៤៦% អាចទទួលយកបាន ១៥% ពេញចិត្តណាស់។ ការផ្តល់ព័ត៌មានអំពីសេវាការិយាល័យច្រកចេញចូលតែមួយ៖ ៤៩ ភាគរយអាចទទួលយកបាននិង ១៥ ភាគរយពេញចិត្តបំផុត។ ចន្លោះពី ៦០ ទៅ ៧០ ភាគរយនៃអ្នកប្រើប្រាស់សេវាការិយាល័យច្រកចេញចូលតែមួយបានបញ្ជាក់ថាសេវាការិយាល័យច្រកចេញចូលតែមួយអាចទទួលយកបាននិងពេញចិត្តខ្លាំងណាស់ ហើយប្រមាណ ៣០ ទៅ ៤០ ភាគរយបានបញ្ជាក់ថាមិនសូវពេញចិត្ត។

៦.៩ **ការប្រជុំធ្វើបណ្ណដាក់ពិន្ទុសហគមន៍**ចំនួន១០ ឃុំសង្កាត់ក្នុងខេត្តបាត់ដំបងដែលមានអ្នកចូលរួមសរុប២៩៤ នាក់ (ស្រី១៣១នាក់) រួមមានក្រុមយុវជន និស្សិត ព្រះសង្ឃ និងវិស័យឯកជន។ ការធ្វើប័ណ្ណដាក់ពិន្ទុសហគមន៍បានវាយតំលៃពីការផ្តល់សេវានៅការិយាល័យច្រកចេញចូលតែមួយ និងបានស្នើឡើងសកម្មភាពទៅការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋដើម្បីដោះស្រាយ និងផ្តល់ជូនសេវាអោយកាន់តែប្រសើរឡើង។ ការផ្តល់យោបល់ និងអនុសាសន៍នេះគឺជាលទ្ធផលដែលបានមកពីការធ្វើប័ណ្ណដាក់ពិន្ទុ នឹងត្រូវបានបង្ហាញនៅក្នុងកិច្ចប្រជុំក្រុមការងារគណនេយ្យភាពសេវាច្រកចេញចូលតែមួយនៅថ្នាក់ក្រុងស្រុក។

៦.១០ **ក្រុមការងារគណនេយ្យភាពសេវាច្រកចេញចូលតែមួយ (DOWG)៖** គម្រោងនេះបានចូលរួមជាមួយក្រុមការងារការិយាល័យប្រជាពលរដ្ឋនៅក្នុងក្រុងស្រុកទាំង ៥ និងក្រុមការងារថ្នាក់ខេត្តក៏បានចូលរួមផងដែរដើម្បីជួយសម្រួលដល់ការអនុវត្តនូវការកែលម្អសកម្មភាព ដែលបានស្នើឡើង ដែលទទួល បានពីការធ្វើប័ណ្ណដាក់ពិន្ទុសហគមន៍ និងមតិយោបល់ត្រឡប់ដែលប្រមូលបានមកពីប្រព័ន្ធបច្ចេកវិទ្យា (IVR និង Facebook Chatbot) រួមជាមួយសកម្មភាពផ្សេងទៀតដូចជាវេទិការសាធារណៈនិងកិច្ចប្រជុំពិគ្រោះយោបល់។ ក្រុមការងារគណនេយ្យភាពសេវាច្រកចេញចូលតែមួយមានសមាសភាពដូចជាអភិបាលរងខេត្ត ឬក្រុងស្រុក ប្រធានការិយាល័យ ក្រុមប្រឹក្សា និងអ្នកតំណាងមកពីអង្គការសង្គមស៊ីវិល និងវិស័យឯកជន។



## បញ្ហាប្រឈម៖

៦.១១ ទោះគម្រោងមិនមានការគាំទ្រផ្នែកសម្ភារៈ និងថវិកាដល់មន្ត្រីរដ្ឋាភិបាលតែយ៉ាងណាក៏មានការគាំទ្រ និងជ្រោមជ្រែងពីរដ្ឋបាលខេត្ត និងក្រុង ស្រុក និងមន្ត្រីរដ្ឋាភិបាលថ្នាក់ជាតិផងដែរ។

៦.១២ អ្នកចូលរួមនៅក្នុងតំបន់ទីក្រុងបានបង្ហាញចំណាប់អារម្មណ៍តិចតួច ក្នុងការចូលរួមធ្វើប័ណ្ណដាក់ពិន្ទុវាយតម្លៃស្តីពីសេវាច្រកចេញចូលតែមួយដោយហេតុផលមិនសូវស្គាល់ និងពុំធ្លាប់មានទំនាក់ទំនង ជាមួយសកម្មភាពគម្រោងពីមុនមក។

៦.១៣ គម្រោងច្រកចេញចូលតែមួយសម្រាប់ពលរដ្ឋ បានផ្តល់នូវឧបករណ៍ប្រព័ន្ធបច្ចេកវិទ្យា ប្រព័ន្ធឆ្លើយតបសារជាសំឡេង និងប្រព័ន្ធឆ្លើយតបសារជាអក្សរ ដើម្បីអោយប្រជាពលរដ្ឋប្រើប្រាស់ ប៉ុន្តែប្រជាពលរដ្ឋភាគច្រើនមានចំណេះដឹងតិចតួចផ្នែកបច្ចេកវិទ្យា ដែលជាហេតុនាំឱ្យមានការលំបាកក្នុងការប្រើប្រាស់ទូរស័ព្ទទំនើប។

## ផែនការឆ្ពោះទៅមុខ៖

៦.១៤ គម្រោងនឹងពង្រីកបន្តទៅកាន់ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង រួមជាមួយនឹងសកម្មភាពដូចគ្នាដូចជា៖ ការធ្វើវេទិការសាធារណៈ សកម្មភាពផ្សព្វផ្សាយ ការប្រជុំក្រុមការងារគណនេយ្យភាពសេវាច្រកចេញចូលតែមួយ និងការបណ្តុះបណ្តាលដល់ក្រុមយុវជន ស្តីពីការតស៊ូមតិ ។ ក្រៅពីនេះ ក៏មានវគ្គបណ្តុះបណ្តាលស្តីពីការិយាល័យច្រកចេញចូលតែមួយ ប្រព័ន្ធបច្ចេកវិទ្យា និងតួនាទីនិងការទទួលខុសត្រូវរបស់ការិយាល័យប្រជាពលរដ្ឋ ទៅដល់ក្រុមអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ប្រជុំពិភាក្សានៅថ្នាក់ជាតិ និងថ្នាក់ខេត្តតាមរយៈសិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍ដាក់ពិន្ទុរបស់ប្រជាពលរដ្ឋ និងសកម្មភាពដែលត្រូវបានកែលម្អ។





**គម្រោងទី៧៖** **ការអភិវឌ្ឍសមត្ថភាពស្តីពីការតៀរគរការគាំទ្រដល់អង្គការសង្គមស៊ីវិលនៅកម្ពុជា (២០២០-២០២១)**

**គោលបំណង៖**
ដើម្បីធានានូវធនធានសម្រាប់អង្គការសង្គមស៊ីវិលដើម្បីឱ្យពួកគេអាចទ្រទ្រង់ប្រតិបត្តិការរបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។

**ថវិកាគម្រោង៖**
Stitching Wilde Ganzen បានបរិច្ចាគប្រាក់ ៣៩,៧៩៤ អឺរ៉ូ និងវិភាគទានពីអ្នកចូលរួមអង្គការសង្គមស៊ីវិលចំនួន ២,៧៦០ សហរដ្ឋអាមេរិក។

**តំបន់គោលដៅ៖**
ទូទាំងប្រទេស។





## សកម្មភាព និងលទ្ធផល៖

៧.១ **ខ្លឹមសារនៃមេរៀននិងវីដេអូនៃវគ្គបណ្តុះបណ្តាលតាមអ៊ិនធ័រណែតស្តីពីការតៀរគរការគាំទ្រ (ការតស៊ូមតិ) ត្រូវបានរៀបចំនិងបានបកប្រែជាភាសាខ្មែរ។** API បានធ្វើយុទ្ធនាការទីផ្សារតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម គេហទំព័ររបស់ API និងតាមបណ្តាញការងារអង្គការក្រៅរដ្ឋាភិបាលជាដៃគូ។ ជាលទ្ធផលអង្គការចំនួន១៥ បានចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាលក្នុងឆ្នាំ២០២០។ សិក្ខាសាលាឆ្លុះបញ្ចាំងរយៈពេលមួយថ្ងៃបានរៀបចំធ្វើឡើងក្នុងគោលបំណងឆ្លុះបញ្ចាំងលើការបណ្តុះបណ្តាល ការបង្វឹកបន្ថែមលើផែនការតស៊ូមតិ មានអ្នកចូលរួមចំនួន១១ នាក់ (ស្រី ២ នាក់) ដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្នុងឆ្នាំ ២០១៩ ។

៧.២ **សិក្ខាសាលាឆ្លុះបញ្ចាំងរំលឹកឡើងវិញ មួយថ្ងៃ ស្តីពីការតស៊ូមតិ**បានធ្វើការជាមួយអ្នកចូលរួម ដែលបានចូលរួមវគ្គបណ្តុះបណ្តាលក្នុងឆ្នាំ ២០១៩ ដែលមានសិក្ខាកាម ១១ នាក់ (២ នាក់ស្រី) ។ សិក្ខាសាលាបានឆ្លុះបញ្ចាំង និងបង្ហាញពីលទ្ធផលវឌ្ឍនភាពនៃផែនការ និងបន្តកែលម្អការអនុវត្តផែនការតស៊ូមតិក៏ដូចជាធាតុចូលពីអ្នកចូលរួមដើម្បីធ្វើឱ្យប្រសើរឡើងនូវសម្ភារៈបណ្តុះបណ្តាលក្នុងពេលមានជំងឺកូវីដ-១៩។ ជាលទ្ធផលផែនការតស៊ូមតិចំនួន ៦ ក្នុងចំណោមអ្នកចូលរួមចំនួន ៧ ទទួលបានលទ្ធផលវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ត្រូវបានគេមើលឃើញនៅក្នុងរបាយការណ៍សកម្មភាពលម្អិតនៅក្នុងឯកសារឧបសម្ព័ន្ធ។

៧.៣ **វគ្គបណ្តុះបណ្តាលស្តីពីតស៊ូមតិបំប៉នបន្ថែម**រយៈពេល ២ ថ្ងៃសម្រាប់គ្រូបណ្តុះបណ្តាលរបស់ API ចាស់និងថ្មីចំនួន ១០ នាក់ (ស្រី ៤ នាក់) នៅខែសីហាឆ្នាំ ២០២០។ គោលបំណងនៃការបណ្តុះបណ្តាលគឺដើម្បីពិនិត្យឡើងវិញនិងធ្វើឱ្យស្របបរិបទការស៊ូមតិនៅកម្ពុជា សម្ភារៈសម្រាប់ឆ្នាំ ២០២០ និង សាកល្បងដំណើរការវគ្គនិងការសម្របសម្រួលជាក់ស្តែង ទិដ្ឋភាពទូទៅដែលមានរចនាសម្ព័ននៃការបណ្តុះបណ្តាលចាំបាច់។ វាក៏បានផ្តល់នូវឱកាសដើម្បីអនុវត្តជំនាញគ្រូបង្វឹកដែលត្រូវការនៅក្នុងបទបង្ហាញ ការសម្របសម្រួល ផ្តល់នូវមតិយោបល់និងការគ្រប់គ្រង ជាមួយគ្រូបង្វឹកដែលមានបទពិសោធន៍។ វគ្គនេះបានផ្តល់នូវចំណេះដឹង ជំនាញនិងបទពិសោធន៍មានប្រយោជន៍ដែលនឹងមានប្រយោជន៍ក្នុងការងារគ្រូឧទ្ទេសក៏ដូចជាជាទូទៅសម្រាប់ ការអភិវឌ្ឍសមត្ថភាពផ្ទាល់ខ្លួនរបស់បុគ្គលិក API។ ឥឡូវនេះ API មានអ្នកបណ្តុះបណ្តាលដែលអាចជួយសម្រួលបានវគ្គសិក្សាឬវគ្គនីមួយៗ នៅក្នុងវគ្គតស៊ូមតិដែលពង្រីកវិសាលភាពនៃការបណ្តុះបណ្តាលបន្ថែម។

៧.៤ ការបណ្តុះបណ្តាលជំនាញតស៊ូមតិ នៅចន្លោះខែកក្កដានិងខែធ្នូ API បានធ្វើការបណ្តុះបណ្តាលរយៈពេលមួយថ្ងៃសម្រាប់អ្នកដឹកនាំ និងបានបណ្តុះបណ្តាលជំនាញតស៊ូមតិ រយៈពេល ៥ ថ្ងៃ, ការបណ្តុះបណ្តាលជំនាញតស៊ូមតិរយៈពេល ៣ ថ្ងៃនិងការបង្វឹកផ្ទាល់ចំនួន ២ដង សម្រាប់អ្នកចូលរួម ២២ នាក់ (ស្រី ៨ នាក់) មកពីអង្គការចំនួន ១៣ ។ ការបណ្តុះបណ្តាលរយៈពេល ២ ថ្ងៃចុងក្រោយត្រូវបានពន្យាពេលដល់ឆ្នាំ ២០២១ ដោយសារតែការផ្ទុះជំងឺកូវីដ-១៩នៅសហគមន៍នៅក្នុងប្រទេសកម្ពុជា។ ជាលទ្ធផលផែនការតស៊ូមតិចំនួន ១៣ របស់អង្គការចំនួន ១៣ ត្រូវបានព្រាងពិភាក្សាពិភាក្សាធ្វើបច្ចុប្បន្នភាពនិងពិគ្រោះយោបល់ដោយផ្ទាល់និងតាមអ៊ិនធ័រណែត។ ផែនការតស៊ូមតិភាគច្រើនកំពុងត្រូវបានអនុវត្ត អ្នកខ្លះពន្យាពេលហើយ មិនទាន់មានលទ្ធផលគួរឱ្យកត់សម្គាល់ដោយសារតែការរីករាលដាលជំងឺកូវីដ១៩ នៅសហគមន៍ ។



## មេរៀនរៀនសូត្រ៖

៧.៥ ការបណ្តុះបណ្តាល បានពន្យាពេលក្នុងត្រីមាសទី ១ ដោយសារវិបត្តិកូវីដ-១៩ ។ ទោះយ៉ាងណា API អាចប្រើពេលវេលានេះដើម្បីធ្វើការបកប្រែនិងពិនិត្យខ្លឹមសារមេរៀនឡើងវិញ។ យើងត្រូវការពេលវេលាច្រើនដើម្បីស្វែងរកទីកន្លែងដើម្បីរៀបចំសិក្ខាសាលាបណ្តុះបណ្តាលនិងវគ្គសិក្សាក្នុងកំឡុងពេលនៃការផ្ទុះឡើងនៃកូវីដ-១៩ពីព្រោះសណ្ឋាគារជាច្រើនមិនបានបើកធ្វើអាជីវកម្មហើយថ្លៃជួលនៅសណ្ឋាគារដែលរំពឹងទុកផ្សេងទៀតគឺថ្លៃណាស់។

៧.៦ ការប្រជុំគ្រូបង្វឹកតាមអ៊ិនធរណេតជាមួយអ្នកចូលរួមមានប្រសិទ្ធិភាពក្នុងកំឡុងពេលនៃការផ្ទុះឡើងនៃកូវីដ-១៩ វាគួរត្រូវបានអនុវត្តនាពេលអនាគតផងដែរ។

## បញ្ហាប្រឈម៖

៧.៧ ការរីករាលដាលនៃជម្ងឺកូវីដ-១៩ ប៉ះពាល់ដល់ពេលវេលានៃការបណ្តុះបណ្តាល ការបង្វឹកនិងការអនុវត្តន៍ផែនការ។

៧.៨ ការប្រើប្រាស់វិធីសាស្រ្តដែលអាចបត់បែនបាននិងថ្មីដូចជាគំរូតាមអ៊ិនធឺណេតបានកើតឡើងដោយមានតម្រូវការក្នុងការកសាងសមត្ថភាពបន្ថែមទៀត និងបែងចែកធនធានសម្រាប់បង្កើតប្រព័ន្ធអនឡាញ។

៧.៩ គម្រោងនេះទាមទារការចូលរួមវិភាគទានហិរញ្ញវត្ថុ ១០ ភាគរយពីសមាជិកនៃអង្គការសង្គមស៊ីវិល ប៉ុន្តែមានអង្គការមិនមែនរដ្ឋាភិបាលនិងអង្គការសហគមន៍ជាច្រើនមិនមានខ្ទង់ថវិកាណាមួយសម្រាប់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។

## ផែនការឆ្ពោះទៅមុខ៖

៧.១០ API នឹងផ្តល់វគ្គបណ្តុះបណ្តាលបន្ត និងពិនិត្យឡើងវិញលើកម្មវិធីសិក្សាជាខ្មែរ និងរចនាគេហទំព័រភាសារខ្មែររបស់ CtGA។

៧.១១ រៀបចំសិក្ខាសាលាបំប៉នបន្ថែមរយៈពេល ២ ថ្ងៃសម្រាប់គ្រូបង្គោលនិងគ្រូបង្គោលសក្តានុពលរបស់API ។

៧.១២ បើកសិក្ខាសាលាបំប៉នបន្ថែម រយៈពេល ១ ថ្ងៃសម្រាប់អ្នកចូលរួមក្នុងឆ្នាំ២០២០ និងជ្រើសរើសអ្នកចូលរួម និងរៀបចំវគ្គបណ្តុះបណ្តាល២០២១ ។

៧.១៣ កែលំអកម្មវិធីបណ្តុះបណ្តាលគៀងគរមូលនិធិមូលដ្ឋាន (LFR) និងសាកល្បងវគ្គសិក្សានេះសម្រាប់អង្គការសហគមន៍មូលដ្ឋាន (CBOs) ។




**គម្រោងទី៨៖** **គម្រោងជួយសង្គ្រោះបន្ទាន់ដល់ក្រុមគ្រួសារក្រីក្រដោយសារកូវីដ-១៩ (២០២០)**

**គោលបំណង៖**
ផ្តល់ជំនួយបន្ទាន់ដល់ក្រុមងាយរងគ្រោះបំផុតដោយសារកូវីដ-១៩

**ថវិកាគម្រោង៖**
Stitching Wilde Ganzen ឧបត្ថម្ភថវិកា ១៦,២៤០ USD និងបដិភាគពីសហគមន៍

**ដៃគូអនុវត្តន៍៖**
អាជ្ញាធរមូលដ្ឋានខេត្តកំពង់ធំ អង្គការអប់រំសុខភាព និងបរិស្ថាន(EHE)

**តំបន់គោលដៅ៖**
រាជធានីភ្នំពេញ (ខណ្ឌសែនសុខ) និងខេត្តកំពង់ធំ





### សកម្មភាព និងលទ្ធផល៖

៨.១ គម្រោងជួយសង្គ្រោះបន្ទាន់ដល់ក្រុមគ្រួសារដែលងាយរងគ្រោះបំផុតដោយសារកូវីដ១៩ បានជួយដល់គ្រួសារងាយរងគ្រោះបំផុត ៥៥០ គ្រួសារនៅក្នុង៣ ស្រុក/ខណ្ឌក្នុងគោលបំណងលើកកម្ពស់សន្តិសុខស្បៀងអាហាររបស់អ្នកដែលប្រឈមនឹងហានិភ័យនៃវិបត្តិសេដ្ឋកិច្ច និងដើម្បីបង្កើនការយល់ដឹងរបស់ប្រជាជននៅតាមភូមិគោលដៅនៃការការពារការរីករាលដាលនៃ កូវីដ-១៩ គម្រោងនេះត្រូវបានអនុវត្តបានជោគជ័យដោយ API ជាមួយអង្គការ EHE និងអាជ្ញាធរមូលដ្ឋានក្នុងតំបន់គោលដៅ។ ភាគច្រើនអ្នកក្រីក្រក្នុងទីក្រុងគឺពួកគេធ្វើការក្នុងវិស័យក្រៅប្រព័ន្ធដោយមានលក្ខខណ្ឌការងារទាប និងប្រាក់ឈ្នួលទាបហើយអ្នកខ្លះអត់ការងារធ្វើ។ គ្រួសារក្រីក្រនៅខណ្ឌសែនសុខ ៨៥.៣% បានរាយការណ៍ថាប្រាក់ចំណូល របស់ពួកគេមានការថយចុះគួរឱ្យកត់សម្គាល់ក្នុង កំឡុងពេលផ្ទុះជំងឺ កូវីដ-១៩។

៨.២ គម្រោងនេះសម្រេចបាននូវគោលបំណងរបស់ខ្លួនតាមរយៈការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធរួមមានអាជ្ញាធរមូលដ្ឋានអង្គការសង្គមស៊ីវិល ដៃគូ និងអ្នកដែលបានបាត់បង់ឱកាស និងជនងាយរងគ្រោះ។ គម្រោងនេះដំណើរការបានល្អទោះបីជាចំនួនគ្រួសារងាយរងគ្រោះតិចជាងផែនការក៏ដោយ ដោយសារមានថវិកាតិចតួចសម្រាប់ការចូលរួមវិភាគទាន។ រដ្ឋបាលមូលដ្ឋានបានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ម្ចាស់ជំនួយ និងអង្គការដៃគូដែលបានបរិច្ចាគធនធានរបស់ពួកគេដើម្បីជួយប្រជាជនក្រីក្របំផុតនៅក្នុងទឹកដីរបស់គាត់។ ទន្ទឹមនឹងនេះអាជ្ញាធរមូលដ្ឋានបានចូលរួមចំណែកក្នុងគម្រោងនេះដោយមានថវិកា និងស្បៀងអាហារ និងផ្តល់សក្ខីកម្មក្នុងព្រឹត្តិការណ៍សប្បុរសធម៌នេះ។ ៥៥០គ្រួសារនៃក្រុមងាយរងគ្រោះបំផុតបានទទួល ជំនួយ ដំបូងពីគម្រោងនេះ។ ពួកគេភាគច្រើនជាជនមានពិការភាពមេម៉ាយជនជាតិភាគតិចនិងគ្រួសារក្រីក្រនៅទីក្រុង។ ជំនួយសង្គ្រោះបន្ទាន់នេះបានចូលរួមចំណែកយ៉ាងសំខាន់ដល់ជីវភាពរស់នៅរបស់ប្រជាជនចំនួន ៥៥០ គ្រួសារដែលមានអ្នកទទួលផលផ្ទាល់ជាង ២០០០ នាក់។






៨.៣ គម្រោងនេះទទួលបានការចូលរួមវិភាគទានពីមូលនិធិ Wilde Ganzen ចំនួន ១៦,២៤០ USD និងអាជ្ញាធរមូលដ្ឋាន ឃុំដងកាំបិត៣៦៣ USD, ឃុំមានរិទ្ធិមានចំនួន ៥០០ USD, ឃុំសណ្ដាន់ ៥០០ USD, ឃុំសុចិត្រ ២៥០ USD, សមាគមក្រុមប្រឹក្សាខេត្តកំពង់ធំ ២៥០ USD, ស្រុកសណ្ដាន់គាំទ្រ អង្ករ ១ តោន អង្គការ EHE ចំនួន ៥០០USD រដ្ឋបាលខណ្ឌសែនសុខឧបត្ថម្ភអង្ករ ៣ តោន មី ១៥០កេស ត្រីខ ១៥០កំប៉ុង និងទឹកស៊ីអ៊ីវ ១៥០ដប។ ដើម្បីគាំទ្រដល់ដំណើរការនេះក្រុមការងារគម្រោងបានអនុវត្តការការពារកូវីដ-១៩ យ៉ាងហ្មត់ចត់តាមរយៈការរក្សាគម្លាតសង្គម ការប្រើប្រាស់ម៉ាស និងអាល់កុល ការត្រួតពិនិត្យសីតុណ្ហភាព និងការអនុវត្តអនាម័យជាប្រចាំ។

៨.៤ នៅក្នុងខែតុលាឆ្នាំ២០២០ យើងបានសម្ភាសជាមួយគ្រួសារងាយរងគ្រោះចំនួន ១០២ ក្នុងចំណោម ១០៥ គ្រួសារក្នុងខណ្ឌសែនសុខបង្ហាញថា ៩៣,១% នៃគ្រួសារទាំងនោះបានទទួលជំនួយជាសាច់ប្រាក់របស់កូវីដ-១៩ ពីគម្រោងនៅខែកក្កដាឆ្នាំ ២០២០។ បន្ទាប់ពីទទួលបានជំនួយពួកគេបានប្រើជំនួយជាសាច់ប្រាក់ដើម្បីបង្កើតអាជីវកម្មខ្នាតតូចពង្រឹង និងពង្រីកអាជីវកម្មខ្នាតតូចរបស់ពួកគេទិញអាហារ និងថ្នាំពេទ្យជាដើម។ លើសពីនេះទៀត ពួកគេបានអំពាវនាវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតលើការ ផ្គត់ផ្គង់ទឹក ការផ្គត់ផ្គង់វេជ្ជសាស្ត្រ កម្មវិធីភាសាអង់គ្លេស យុទ្ធនាការផ្សព្វផ្សាយអំពីការការពារជំងឺគ្រុនឈាម និងជំនួយដល់ជនមានពិការភាព។ តួលេខពីបទសម្ភាសន៍បង្ហាញថា ២៦.៥% នៃអ្នកស្រុកនៅទីនោះដែលបើកហាងលក់រាយបានឱ្យដឹងថា ១៩.៦% ចំណាយលើបំណុល និងថែទាំសុខភាពហើយ ៥៣.៩% ទៀតចំណាយសម្រាប់ការប្រើប្រាស់អាហារប្រចាំថ្ងៃ។





## គម្រោងទី៩៖ សំឡេង និងសកម្មភាពរបស់ជនមានពិការភាពក្នុងគណនេយ្យភាពសង្គម (២០១៩-២០២០)

### គោលបំណង៖

បង្កើនសំឡេងរបស់ជនមានពិការភាពឱ្យកាន់តែប្រសើរដើម្បីទទួលបានសេវាសាធារណៈប្រកបដោយគុណភាព និងសមធម៌នៅក្នុងស្រុកគោលដៅ។

### ថវិកាគម្រោង៖

កម្មវិធីសំឡេងរបស់អង្គការ អុិកស្វាម (The Voice Programme of Oxfam) នៅប្រទេសកម្ពុជាបានផ្តល់ថវិកាចំនួន ១៥៦,៨៥៨ ដុល្លារ ឆ្នាំ២០១៩ដល់២០២១

### ដៃគូអនុវត្ត៖

អង្គការ អេពិកអាត (Epic Arts)

### តំបន់គោលដៅ៖

ឃុំចំនួន៧ នៅស្រុកត្រាំកក់ ខេត្តតាកែវ

### លទ្ធផលសង្ខេបរបស់គម្រោង៖

1. ធ្វើឱ្យប្រសើរឡើងនូវភាពជាតំណាង និងឱកាសដល់ជនមានពិការភាពមានសំឡេងនៅគ្រប់កំរិតនៃគម្រោង I-SAF
2. បង្កើនការឆ្លើយតបចំពោះបញ្ហានិងការទាមទាររបស់ជនមានពិការភាព
3. ការទាមទាររបស់ជនមានពិការភាពមានឥទ្ធិពលក្នុងកំរិតគោលនយោបាយថ្នាក់ជាតិ I-SAF និងការអនុវត្តនានា

គម្រោងនេះបានបញ្ចប់របាយការណ៍ស្ទង់មតិតាមបែបបាល់ព្រិល(snow ball) ឆ្នាំ២០១៩ សិក្ខាសាលាស្តីពីចងក្រងឯកសារនិងការរៀនសូត្រ ផលិតបានជាករណីសិក្សា សិក្ខាសាលាពង្រឹងភាពម្ចាស់ការទៅដល់បុគ្គលដែលមានពិការភាពក្នុងឃុំទាំង៧ កិច្ចប្រជុំដាក់ពិន្ទុជាមួយបុគ្គលដែលមានពិការភាពម្នាក់ក្នុងឃុំនីមួយៗ ស្តីពីការដាក់ពិន្ទុ (scorecard meetings)ជាមួយជនមានពិការភាពនៅក្នុងឃុំទាំង៧។ កិច្ចប្រជុំទាំងនោះបានបង្កើតចេញជាផែនការសកម្មភាព គណនេយ្យភាពរួមគ្នា (JAAP) ដើម្បីធ្វើឱ្យសេវាសម្រាប់ជនដែលមានពិការភាពមានភាពប្រសើរឡើង ហើយគម្រោងបានធ្វើបច្ចុប្បន្នភាពគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិ (I-SAF) ពីខែមករាឆ្នាំ ២០២១។



## សកម្មភាព និងលទ្ធផល៖

៩.១ យើងសម្រេចបាន ១២២% (៥១៤) ស្ត្រី បុរស និងកុមារ ដែលមានពិការភាពខុសៗគ្នា និងក្រុមអាយុផ្សេងៗគ្នាដែលបានកំណត់តាមរបាយការណ៍ស្ទង់មតិនៅក្នុងឃុំគោលដៅទាំងអស់។ យើងគៀងគរបានជនមានពិការភាពចំនួន១៨៥នាក់ ដែលទទួលបានចំនួន ៨៨% ក្នុងចំណោម(១៨៥នាក់) ដែលមានក្រុម ស្ត្រី និងក្រុមបុរសដែលមានភាពពិការខុសៗគ្នា និងក្រុមអាយុផ្សេងៗគ្នាដែលបានចូលរួមសិក្ខាសាលាពង្រឹងសិទ្ធិអំណាចដល់ជនមានពិការភាព និងការប្រជុំស្តីពីការដាក់ពិន្ទុជាមួយជនមានពិការភាព។ យ៉ាងហោចណាស់ ៥០% នៃអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍នៅតាមស្រុកគោលដៅទទួលបានការបណ្តុះបណ្តាលស្តីពីការដាក់បញ្ចូលបញ្ហាជនដែលមានពិការភាពក្នុងគម្រោង I-SAF ក្នុងឃុំគោលដៅទាំង៧ ឱ្យបាន (១០០%)។

៩.២ **កិច្ចប្រជុំប្រចាំខែរបស់ឃុំ មណ្ឌលសុខភាព និងសាលាបឋមសិក្សាក្នុងឃុំគោលដៅបានដាក់ឱ្យមានតំណាងជនមានពិការភាពចូលរួមប្រជុំជាទៀងទាត់។** អ្នកផ្តល់សេវាក្នុងឃុំគោលដៅទាំងអស់បានគាំទ្រ និងបំពាក់ឧបករណ៍សម្រាប់អ្នកមានពិការភាព (រទេះរុញ វ៉ែនតា) ទីជំរាលនៅស្ថាប័នសាធារណៈមួយចំនួន សម្ភារសិក្សា និងអាហាររូបករណ៍សម្រាប់កុមារដែលមានពិការភាព។ ជនមានពិការភាពបានទទួលនូវវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសចិញ្ចឹមសត្វ ការផ្គត់ផ្គង់ថ្នាំដែលមានគុណភាព។ បុគ្គលិកមណ្ឌលសុខភាព បានបង្កើនបុគ្គលិកពេទ្យ និងផ្តល់សេវាកាន់តែប្រសើរដល់ប្រជាពលរដ្ឋទូទៅ និងជនដែលមានពិការភាព ។

៩.៣ **អាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាឃុំបានដោះស្រាយបញ្ហាចំនួន ៦១ (៥០.៤%) ក្នុងចំណោមបញ្ហាចំនួន ១២១ ដែលបានលើកឡើងដោយជនមានពិការភាព** ដែលមាននៅក្នុងផែនការសកម្មភាពគណនេយ្យភាពរួមគ្នាទាំង៧ នៅឃុំទាំង៧។ ពួកគេបានទទួលយកបញ្ហារបស់ជនមានពិការភាពដែលមាននៅក្នុងផែនការសកម្មភាពគណនេយ្យភាពរួមគ្នា (JAAP) ចំនួន៧ និងបានដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំឆ្នាំ២០២០ និងបញ្ហាឆ្លើយតបមួយចំនួននឹងអនុវត្តនៅក្នុងឆ្នាំ២០២១ ។

៩.៤ **គោលការណ៍ណែនាំសម្រាប់ប្រតិបត្តិគណនេយ្យភាពសង្គម (I-SAF) ដំណាក់កាលទី២ ត្រូវបានកែសម្រួល និងដាក់បញ្ចូលក្នុងបញ្ហារបស់ជនមានពិការភាព** ក្រោមការផ្តល់ជំនួយបច្ចេកទេសពីវិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ និងអង្គការទស្សនៈពិភពលោក។ មានការកំណត់ស្តង់ដារគុណភាពអប្បបរមាច្បាស់លាស់ដែលដៃគូអនុវត្តពាក់ព័ន្ធទាំងអស់នៅក្នុងក្របខណ្ឌគណនេយ្យភាពសង្គមI-SAFនឹងអនុវត្តតាម។ ក្រៅពីស្តង់ដារអប្បបរមាទាំងនេះ គោលការណ៍ណែនាំបានចង្អុលបង្ហាញពីវិធីសាស្ត្រ និងសកម្មភាព ដែលឆ្លើយតបទៅនឹងការអនុវត្តល្អ និងការរៀនសូត្រល្អៗដែលទទួលបានពីអង្គការផ្សេងៗ។ គណនេយ្យភាពសង្គម I-SAF ត្រូវបានដាក់បញ្ចូលក្នុងគោលការណ៍ណែនាំនេះផងដែរ។ កិច្ចពិភាក្សាគោលនយោបាយស្តីពីការដាក់បញ្ចូលបញ្ហាសង្គមត្រូវបានធ្វើឡើងដោយមានអ្នកចូលរួមចំនួន ២៥ នាក់ដែលមានតំណាងពីដៃគូពាក់ព័ន្ធផ្នែកគោលនយោបាយគណនេយ្យភាពសង្គម I-SAF អ្នកអនុវត្តគម្រោង និងតំណាងក្រុមគោលដៅដែលងាយរងគ្រោះ ដើម្បីពង្រឹងដល់ដំណើរការដាក់បញ្ចូល គណនេយ្យភាពសង្គម I-SAF។ NCDD-S មានការពេញចិត្តយ៉ាងខ្លាំង និងទទួលយកនូវគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិគណនេយ្យភាពសង្គម I-SAF ថ្មីនេះដើម្បីធានាឱ្យមានការចូលរួមប្រកបដោយគុណភាពនិងភាពចម្រុះនៅក្នុងដំណើរការអភិវឌ្ឍន៍មូលដ្ឋាន។



៩.៥ **បានចងក្រងឯកសារ និងធ្វើរបាយការណ៍មេរៀនឆ្លុះបញ្ចាំង ដែលឆ្លើយតបទៅនឹងសំណួរទាំង៦ ដែលបានទុកជាមេរៀនសម្រាប់រៀនសូត្រ។** គម្រោងនេះបានដោះស្រាយនូវបញ្ហារបស់អ្នកចូលរួមគម្រោងក្នុងដំណើរការគម្រោងផ្តល់សេវាដល់ជនមានពិការភាពមានកម្រិតទាប និងអ្នកផ្តល់សេវា និងអ្នកធ្វើសេចក្តីសម្រេចចិត្តថ្នាក់មូលដ្ឋានមិនទាន់បានគិតគូរដល់បញ្ហារបស់ជនមានពិការភាព។ លើសពីនេះទៀត យើងឃើញថាការប្រើប្រាស់សិល្បៈដែលមានភាពច្នៃប្រឌិតដើម្បីបង្កើនការយល់ដឹងអំពីបញ្ហាពិការភាព និងការកសាងទំនុកចិត្តរបស់ជនមានពិការភាពនៅតាមខេត្តគោលដៅគឺទទួលជោគជ័យ។ អ្នកឆ្លើយសំណួរភាគច្រើន (៨៥%)ក្នុងចំណោម៤៩នាក់ មាន២០នាក់ទាមទារការផ្តល់សេវា និង២៩នាក់ទៀតមានការចាប់អារម្មណ៍ក្នុងការ ចូលរួមក្នុងដំណើរការគណនេយ្យភាពសង្គម (I-SAF)។ ភាគីផ្តល់សេវាបានបង្ហាញថាពួកគាត់បានយល់ដឹងពីបញ្ហាពិការភាពប្រសើរជាងមុននៅក្នុងការងាររបស់ពួកគេប៉ុន្តែក្នុងដំណាក់កាលនេះពួកគាត់មិនទាន់បានយកអនុវត្តជាក់ស្តែងក្នុងការងារផ្តល់សេវារបស់ពួកគេនៅឡើយទេ។ មានការផ្តល់យោបល់ទៅលើបញ្ហាពិការភាពគឺជាចំណុចសំខាន់ដែលត្រូវធ្វើអោយប្រាកដថាការផ្លាស់ប្តូរនៅតែបន្តក្នុងសហគមន៍និងអង្គការស្តីពីការរៀបបញ្ចូលបញ្ហាជនមានពិការភាព និងការបង្កើតអោយមានការគោលការណ៍ណែនាំដើម្បីដោះស្រាយនូវឧបសគ្គទាំងឡាយដែលជនមានពិការភាពកំពុងជួបប្រទះ។

**ការអនុវត្តល្អៗរបស់គម្រោងស្តីពីការដាក់បញ្ចូលជនមានពិការភាពនៅក្នុងគណនេយ្យភាពសង្គម (I-SAF) បានចែករំលែកទៅដល់អ្នកតំណាងចំនួន ២៤០នាក់ (ស្រី១០៦នាក់) មកពីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល និងដៃគូរអង្គការសង្គមស៊ីវិល។** ពួកគេបានចូលរួមចំណែកយ៉ាងពេញលេញក្នុងការកែលំអគោលការណ៍ណែនាំសម្រាប់ប្រតិបត្តិគណនេយ្យភាពសង្គម (I-SAF) ដោយដាក់បញ្ចូលបញ្ហាសង្គម និងពិការភាពទៅក្នុងគោលការណ៍ណែនាំនៅកំឡុងពេលធ្វើសិក្ខាសាលាជាតិស្តីពី "ថវិកាសម្រាប់ការអភិវឌ្ឍគណនេយ្យភាពសង្គមពេញលេញប្រកបដោយប្រសិទ្ធភាព និងសមធម៌" នៅថ្ងៃទី ២៨ ខែតុលាឆ្នាំ ២០២០។ គម្រោងក៏បានចូលរួមពង្រឹងនិងពង្រីកទំនាក់ទំនង និងភាពជាដៃគូររវាងអ្នកស្មគ្រចិត្តគណនេយ្យភាពសហគមន៍ CAFs អង្គការសង្គម ស៊ីវិល និងក្រសួងពាក់ព័ន្ធផងដែរ។ វាក៏ជាឱកាសមួយសម្រាប់ពួកគេក្នុងការចែករំលែកនូវវឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍នានាដើម្បីស្វែងរកយុទ្ធសាស្រ្ត អនុវត្តរួមគ្នារបស់គណនេយ្យភាពសង្គម (I-SAF) នៅដំណាក់កាលទី២ ។ សិក្ខាសាលានេះធ្វើឡើងក្រោមកិច្ចសហការរបស់វិទ្យាស្ថាន API, Star Kampuchea, CDPP, CARE, NCDD, FHI360, World Vision Cambodia ដោយមានការគាំទ្រថវិកាពី Oxfam (Voice programme)។

យើងបានចងក្រងជាឯកសារនិងចែករំលែកករណីសិក្សាចំនួន៣នៃគម្រោងនេះទៅក្នុងបណ្តាញ Linking and Learning (L&L) ដើម្បីចុះផ្សាយនៅ Oxfam Global ។ ករណីសិក្សាទាំងនោះគឺ៖ ១) បុរសដែលមានពិការភាពមួយរូបដែលប្រកបមុខរបរកសិកម្មនិងចិញ្ចឹមសត្វសម្រាប់គ្រួសាររបស់ពួកគេ បានទាមទារសិទ្ធិក្នុងការទទួលបានសេវាសង្គមនៅក្នុងដំណើរការអាយសាសហ្វ(I-SAF)។ ២) លទ្ធផលនៃការអនុវត្តអាយសាសហ្វ (I-SAF) ផ្តល់អត្ថប្រយោជន៍ដល់កុមារដែលមានពិការតាមរយៈការកសាងជំរាលនិងបង្គន់ដាច់ដោយឡែកនៅសាលាបឋមសិក្សាមង្គលធំ ក្នុងឃុំញៀងញ៉ង។ ករណីសិក្សាទី ៣) តម្រូវការការពារសង្គម និងការលើកកម្ពស់អភិបាលកិច្ចល្អតាមរយៈការអនុវត្តគម្រោងគណនេយ្យភាពសង្គម (I-SAF) សម្រាប់អ្នកជំនួញជាស្រ្តីពិការក្នុងកំឡុងពេលនៃការរីករាលដាលកូវីដ-១៩ ។



៩.៦ ការវាយតម្លៃផ្ទៃក្នុងបានរកឃើញថា៖ គម្រោងអាចបង្កើនសំឡេងរបស់ជនដែលមានពិការភាព និងលើកកង្វល់របស់ពួកគេក្នុងរបៀបវារៈរបស់អាជ្ញាធរមូលដ្ឋាន។ ជាពិសេស គម្រោងនេះបានកសាងនូវទំនុកចិត្ត និង ពង្រឹងភាពម្ចាស់ការដល់ជនមានពិការភាពដើម្បីឱ្យពួកគេយល់ថាពួកគេមានតម្លៃនៅក្នុងសង្គម និងអាចចូលរួមចំណែកយ៉ាងត្រឹមត្រូវដល់សង្គមតាមរយៈសកម្មភាពរបស់គណនេយ្យភាពសង្គម (I-SAF)។

៩.៧ គុណភាពនៃសំណើរគម្រោងដាក់បញ្ចូលពិការភាពគឺខ្ពស់ សំណើរសំខាន់របស់គម្រោង គឺការប្រើប្រាស់សកម្មភាពរបស់គណនេយ្យភាពសង្គម (I-SAF) ដែលយកជនមានពិការភាពជាគោលដៅពិសេស និងការលុបបំបាត់ឧបសគ្គនានាដើម្បីឱ្យជនមានពិការភាពអាចចូលរួមក្នុងសកម្មភាពរបស់គណនេយ្យភាពសង្គម (I-SAF)។ សំណូមពរទាំងនេះបាននាំមកនូវវិធីសាស្ត្រដែលមានរយៈពេលយូរពីរក្នុងការដាក់បញ្ចូលពិការភាពទី៖ ទី១ តាមរយៈការបង្កើតកន្លែងមានសុវត្ថិភាពសម្រាប់ជនមានពិការភាពក្នុងការលើកបញ្ហារបស់ពួកគេ ទី២ ដោះស្រាយបញ្ហា ដែលជាឧបសគ្គដល់ជនដែលមានពិការភាពក្នុងការលើកបញ្ហារបស់ពួកគេ។

៩.៨ គម្រោងនេះបានជួយដល់ជនមានពិការភាពក្នុងការដាក់បញ្ចូលបញ្ហាពិការភាពតាមរយៈការប្រើប្រាស់កិច្ចប្រជុំជាក់លាក់តាមអ៊ិនធឺណែត និងការប្រជុំពីផែនការសកម្មភាពគណនេយ្យភាពចូលរួម (JAAP) សម្រាប់ជនមានពិការភាព។ ជាពិសេសគម្រោងនេះបានប្រើប្រាស់គំរូដែលមានប្រសិទ្ធភាពមួយដែលប្រើប្រាស់ផែនការសកម្មភាពគណនេយ្យភាពចូលរួម (JAAP) ចំនួនពីរគឺមួយសម្រាប់មនុស្សទូទៅ និងមួយទៀតសម្រាប់ជនមានពិការភាព។ គំរូនេះមិនទាន់ត្រូវបានអនុវត្ត/បញ្ចូលក្នុងគោលនយោបាយឬ ក្របខណ្ឌគោលនយោបាយអាយសាសហ្វ (I-SAF) ទេ ដូច្នេះ អត្ថប្រយោជន៍វិជ្ជមាននៃវិធានការណ៍ ដាក់បញ្ចូលពិការភាពទាំងនេះត្រូវបានធ្វើមូលដ្ឋានីយកម្មដល់ឃុំគោលដៅ។

៩.៩ ការចូលរួមចំណែកសំខាន់របស់គម្រោងចំពោះការផ្លាស់ប្តូរកម្រិតគោលនយោបាយ គឺសំណើររបស់គម្រោងដោយដោះស្រាយឧបសគ្គរបស់ជនមានពិការភាពដើម្បីអាចទទួលផលពីនូវសកម្មភាពរបស់ គណនេយ្យភាពសង្គម (I-SAF) ។ គួរកត់សម្គាល់ផងដែរថាគម្រោងដើមរបស់ គណនេយ្យភាពសង្គម (I-SAF) គឺមិនមែនបង្កើតឡើងដើម្បីគិតគូរពីជនមានពិការភាព និងមិនមានធាតុនៃការដាក់បញ្ចូលភាពពិការទេ។ ដូច្នេះនៅក្នុងគម្រោងនេះ វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយបានធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការទស្សនៈពិភពលោក អង្គការឃែរ អង្គការ FHI 360 និងគណៈកម្មាធិការជាតិដើម្បីការអភិវឌ្ឍប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ដើម្បីកែសម្រួល "គោលការណ៍ណែនាំប្រតិបត្តិអាយសាសហ្វ (I-SAF) សម្រាប់ដៃគូអង្គការមិនមែនរដ្ឋាភិបាល" និង "កម្មវិធីបណ្តុះបណ្តាល អាយសាសហ្វ (I-SAF)" ដើម្បីឱ្យគេដាក់បញ្ចូលទស្សនវិស័យរបស់ជនមានពិការភាព។

៩.១០ ការធ្វើឱ្យប្រសើរឡើងនៅក្នុងគណនេយ្យភាពសង្គម (I-SAF) គឺត្រូវការចាំបាច់ រួមមានការរួមបញ្ចូលនូវស្តង់ដាគុណភាពអប្បបរមាសម្រាប់ការបញ្ចូលពិការភាព។ ការកែសម្រួលឡើងវិញបានផ្តល់យោបល់ថាចំពោះគោលការណ៍ណែនាំប្រតិបត្តិគណនេយ្យភាពសង្គម (I-SAF)សម្រាប់ដៃគូអង្គការមិនមែនរដ្ឋាភិបាល គឺមានគោលបំណងលុបបំបាត់ឧបសគ្គទាក់ទងនឹងអាកប្បកិរិយា (ប្រឈមនឹងការរើសអើង ការមិនអើពើ ឬការយល់ច្រឡំទៅលើជនមានពិការភាព) ឧបសគ្គទាក់ទងនឹងរូបវន្ត (កង្វះ ខាត ទីជំរាល រទេះសម្រាប់



ជនមានពិការភាព ឧបករណ៍ជំនួយសំឡេងនិងចក្ខុវិស័យ ការប្រើភាសាបច្ចេកទេសហួសហេតុ) និងឧបសគ្គទាក់ទងនឹងការធ្វើដំណើរ (មិនអាចទទួលបានសេវាកម្ម ដោយសារហេដ្ឋារចនាសម្ព័ន្ធសម្រាប់ជនមានពិការភាពក្នុងការធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយទៀត)។

៩.១១ នៅក្នុងស្រុកត្រាំកក់ តាមរយៈគម្រោងនេះ ជនមានពិការភាព មានឱកាសច្រើនជាងមុនក្នុងការចូលរួមក្នុងសកម្មភាពគណនេយ្យភាពសង្គម (I-SAF) (ការប្រជុំ / ព្រឹត្តិការណ៍ផ្សេងៗតាមអ៊ីនធឺណែត) និងបានគិតគូរដល់បញ្ហា និងយោបល់របស់ពួកគេ។ នេះផ្ទុយពីតំបន់គណនេយ្យភាពសង្គម (I-SAF) ផ្សេងទៀតដែលគេមិនបានយកជនមានពិការភាពជាក្រុមគោលដៅជាពិសេសមិនបានអញ្ជើញ និងមិនបានផ្តល់សិទ្ធិអំណាចឱ្យចូលរួមក្នុងសកម្មភាព ទាំងនេះ ផ្ទុយទៅវិញពួកគេត្រូវបានគេរើសអើងនិងមិនបានយកចិត្តទុកដាក់។ ការងាររបស់គម្រោងនៅស្រុកត្រាំកក់ គឺជាគំរូមួយសម្រាប់សកម្មភាពរបស់គណនេយ្យភាពសង្គម (I-SAF) នៅស្រុកផ្សេងទៀត។

៩.១២ សិល្បៈគឺជាឧបករណ៍ដ៏មានឥទ្ធិពលបំផុតសម្រាប់ការកសាងទំនុកចិត្តនិងផ្តល់អំណាចដល់ជនមានពិការភាពដើម្បីឱ្យពួកគាត់យល់ថាពួកគាត់មានតម្លៃនៅក្នុងសង្គម និងអាចចូលរួមចំណែកយ៉ាងត្រឹមត្រូវដល់សង្គម។ ភាពជោគជ័យដែលទទួលបានតាមរយៈសិក្ខាសាលា និងការសម្តែងសិល្បៈ អេពិក អាត(Epic Arts) ជាច្រើនបានផ្តល់ជាគំរូ និងភាពវិជ្ជមាននិងតាក់តាងថាជនមានពិការភាពអាចធ្វើបានសម្រេច និងរួមចំណែកក្នុងការងារសហគមន៍របស់ពួកគេ។ សិក្ខាសាលា និងការសម្តែងសិល្បៈអេពិក អាត(Epic Arts) បានក្លាយគឺជាឧបករណ៍ដ៏ល្អសម្រាប់ការបញ្ចុះបញ្ចូល ពង្រឹងអំណាច និងលើក កម្ពស់ការយល់ដឹង។

៩.១៣ ចំពោះអេពិក អាត (Epic Arts) គេសង្កេតឃើញសិល្បករជាជនមានពិការភាព ដូច្នេះពួកគេសំដែងដើម្បីបង្ហាញពីបញ្ហា និងបទពិសោធន៍ផ្ទាល់ខ្លួនដែលពួកគេមាន។ រាល់ពេលដែលគេបង្ហាញពីរឿង រាវពិត និងរឿងផ្ទាល់ខ្លួន នោះវាធ្វើឱ្យមានការដាក់អារម្មណ៍បានល្អ ធ្វើឱ្យប៉ះចំបេះដូងអ្នកទស្សនា ដែលនាំឱ្យការសម្តែងរបស់គេមានប្រសិទ្ធភាព។ សិល្បៈជួយឱ្យយើងរីករាយ និងអាចយល់បានកាន់តែស៊ីជម្រៅអំពីបញ្ហាសង្គមជុំវិញពិការភាព។ សិល្បៈគឺជាផ្នែកមួយនៃជីវិតរបស់យើង។ ជាទូទៅ យើងរស់នៅជាមួយសិល្បៈរាល់ថ្ងៃដែលជាប្រភពនៃការច្នៃប្រឌិត។ សម្រាប់មនុស្សមួយចំនួន ពួកគេចាត់ទុកថាសិល្បៈគ្រាន់តែជាឧបករណ៍កំសាន្តប៉ុណ្ណោះ ប៉ុន្តែនៅពេលដែលគិតឱ្យស៊ីជម្រៅ ពួកគេនឹងយល់ហើយចងចាំថាសិល្បៈក៏មានមុខងារជាឧបករណ៍តស៊ូមតិទន់ភ្លន់មួយដែលមិនត្រឹមតែសម្រាប់ការកំសាន្តប៉ុណ្ណោះទេ។

៩.១៤ ការវាយតម្លៃផ្ទៃក្នុងបានផ្តល់នូវអនុសាសន៍ដូចខាងក្រោម៖ នីតិវិធីសម្រាប់ការវាយតម្លៃភាពជាដៃគូរបស់គម្រោងការចូលរួមរបស់អាជ្ញាធរថ្នាក់ស្រុក វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយនៅបន្តធ្វើលើការដាក់បញ្ចូលពិការភាព បន្តប្រើការតស៊ូមតិផ្អែកលើសិល្បៈ ការចូលរួមសមស្របដោយអ្នកស្ម័គ្រចិត្តសហគមន៍ បន្តប្រើប្រាស់អ្នកស្ម័គ្រចិត្តសហគមន៍ជាជនមានពិការភាពដែលមានស្រាប់ ការលើកកម្ពស់ ការចែករំលែកព័ត៌មាន និងបណ្តាញជនមានពិការភាព បន្តផ្សព្វផ្សាយវីដេអូខ្លីៗរបស់អង្គការអេពិកអាត (Epic Arts)។



## ការរៀនសូត្រ៖

៩.១៥ ឧបករណ៍ដាក់ពិន្ទុថ្មីសម្រាប់ជនមានពិការភាពមានទម្រង់ផ្សេងៗគ្នាអាស្រ័យលើស្ថានភាពពិការរបស់ពួកគេ បើមិនដូច្នេះទេពួកគេនឹងមានការលំបាកក្នុងដំណើរការវាយតម្លៃសេវាកម្មសាធារណៈ។ លើសពីនេះទៀត ជនមានពិការភាពមួយចំនួនត្រូវការជំនួយដើម្បីជួយពួកគេក្នុងការវាយតម្លៃជាពិសេសក្រុមអ្នកដែលបាត់បង់ដៃនិងពិការភ្នែក។

៩.១៦ ទាំងបុគ្គលិក និងអ្នកស្ម័គ្រចិត្តគណនេយ្យភាពសហគមន៍ CAFs បានផ្លាស់ប្តូរបញ្ហានៃការរីករាលដាលនៃកូវីដ-១៩ ទៅជាការពង្រឹងមុខងារបច្ចេកវិទ្យា។ វាមានសារៈប្រយោជន៍ខ្លាំងណាស់ក្នុងការទាក់ទងជាមួយមនុស្សចំណាយថវិកាតិច និងចំណេញពេលវេលាសម្រាប់ការធ្វើដំណើរ។

## បញ្ហាប្រឈម៖

៩.១៧ កូវីដ-១៩ ក្នុងអំឡុងពេលសរសេររបាយការណ៍នៅតែជាបញ្ហាធំមួយ អាជ្ញាធរមូលដ្ឋានមិន បានអនុញ្ញាតឱ្យមានការប្រជុំសាធារណៈណាមួយឡើយ។

៩.១៨ ត្រូវការការគាំទ្រដល់ជនមានពិការភាពដើម្បីឱ្យពួកគេអាចចូលរួមពេញលេញនៅក្នុងសកម្មភាពសង្គមដូចជាការអមដំណើរមនុស្សអ្នកបកប្រែភាសា និងមធ្យោបាយងាយស្រួលផ្សេងៗ។ ល។ ជនមានពិការភាពមួយចំនួនមានផលលំបាកក្នុងការចូលរួមក្នុងដំណើរការគណនេយ្យភាពសង្គម (I-SAF) ដោយសារពួកគេមានចំណេះដឹងតិចតួចពេក។

៩.១៩ យើងត្រូវការពេលវេលាបន្ថែមទៀតដើម្បីអប់រំអាជ្ញាធរសាធារណៈអំពីពិការភាពនិងដើម្បីបញ្ចូលបញ្ហាពិការភាពនៅក្នុងផែនការអភិវឌ្ឍមូលដ្ឋាន។

៩.២០ ជនមានពិការភាពភាគច្រើនមិនមានស្មាតហ្វូនទេ ដូច្នេះយើងនឹងចំណាយពេលច្រើនក្នុងការប្រើប្រាស់ឧបករណ៍តាមអ៊ិនធឺណែតជាមួយពួកគេ។

៩.២១ តម្រូវការឱ្យជូនដំណឹងដល់មន្ត្រីប៉ូលីសជាមុន អំពីការប្រមូលផ្តុំឬការប្រជុំក្នុងកំឡុងពេលនៃការផ្ទុះឡើងកូវីដ-១៩។

## ផែនការឆ្ពោះទៅមុខ៖

៩.២២ ការផ្សព្វផ្សាយជាផ្លូវការ និងការដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំប្រតិបត្តិគណនេយ្យភាពសង្គមដែលបានធ្វើឱ្យប្រសើរថ្មីដល់អ្នកពាក់ព័ន្ធគណនេយ្យភាពសង្គម និងអង្គការដៃគូរអនុវត្តគម្រោងទាំងអស់ ។

៩.២៣ រៀបចំការបណ្តុះបណ្តាលពីការបញ្ចូលជនមានពិការភាពដល់បុគ្គលិករបស់វិទ្យាស្ថានឥស្សរមតិ និងគោលនយោបាយទាំងអស់។

៩.២៤ ការវាយតម្លៃផ្ទៃក្នុងរបស់គម្រោងមានគោលបំណងដើម្បី (ក) វាយតម្លៃប្រសិទ្ធភាពរបស់គម្រោង ដែលឆ្លើយតបទៅនឹងសំណួរណែនាំដែលបានលើកឡើងនៅក្នុងគម្រោង (ខ) ឆ្លើយតបទៅ នឹងសំណួរមេរៀនឆ្លុះបញ្ចាំងរបស់គម្រោងស្តីពី "ច្នៃប្រឌិត និង រៀន" (គ) ទាញយកអនុសាសន៍ សម្រាប់ការងារអនាគតរបស់ API និង EPIC ARTS ក្នុងវិស័យការងារគណនេយ្យភាពសង្គម (I-SAF) អភិបាលកិច្ចមូលដ្ឋានដែលមានលក្ខណៈគិតគូរដល់បញ្ហាទាំងអស់ និង/ ឬកម្មវិធីដាក់បញ្ចូលពិការភាព ។



## គម្រោងទី១០៖ សំឡេងរបស់ពលរដ្ឋក្នុងក្របខណ្ឌគនេយ្យភាពសង្គម (២០១៩-២០២១)

### គោលបំណង៖

**គោលបំណងជាក់លាក់ទី១៖**

ពង្រឹងសមត្ថភាព និងសកម្មភាពរបស់តំណាងពលរដ្ឋ និងអ្នកផ្តល់សេវាក្នុងការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គមសម្រាប់រាជធានីភ្នំពេញដើម្បីលើកកម្ពស់សេវាអប់រំ សុខភាព រដ្ឋបាល និងសេវាគាំពារសង្គមក្នុងខណ្ឌសែនសុខ។

**គោលបំណងជាក់លាក់ទី ២៖**

ការរួមបញ្ចូលសង្គមទៅក្រុមដែលងាយរងគ្រោះដោយត្រូវបានធ្វើឱ្យប្រសើរឡើងនៅក្នុងការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម ជំហានទី ២ ដោយផ្អែកលើការតស៊ូមតិរួមគ្នាជាមួយក្រុមគោលដៅ។

**គោលបំណងជាក់លាក់ទី ៣៖**

បង្កើនការចូលរួមរបស់ពលរដ្ឋតាមរយៈការប្រើប្រាស់បណ្តាញព័ត៌មានឌីជីថលសម្រាប់ពលរដ្ឋ និងមធ្យោបាយឌីជីថលដើម្បីផ្តល់ជាមតិយោបល់លើការផ្តល់សេវាសាធារណៈ។

### ថវិកាគម្រោង៖

សរុបចំនួន ៥១,០១៧ ដុល្លាអាមេរិច

### ដៃគូអនុវត្ត៖

អង្គការ អេពិកអាត ( Epic Arts )

### តំបន់គោលដៅ៖

ខណ្ឌសែនសុខ រាជធានីភ្នំពេញ





## សកម្មភាព និងលទ្ធផល៖

១០.១ ប្រហែលជា ៨៥% នៃសកម្មភាពប្រចាំឆ្នាំដែលបានគ្រោងទុកត្រូវបានអនុវត្ត។ យើងសង្កេតឃើញមានការផ្លាស់ប្តូរជាវិជ្ជមានបន្ទាប់ពីការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គមនៅខណ្ឌសែនសុខ ទាំងហេដ្ឋារចនាសម្ព័ន្ធ សេវាសាធារណៈ ដែលផ្តល់ដោយមណ្ឌលសុខភាព សាលាបឋមសិក្សា និងសង្កាត់។ ទាំងអស់នេះគឺជាលទ្ធផលនៃការអនុវត្តសកម្មភាពគម្រោង។

១០.២ ការធ្វើផែនទីសេវាសហគមន៍ត្រូវបានបង្កើតឡើងដោយមានការចូលរួមពីអ្នកចូលរួម ៧៣ នាក់ (ស្រី ២៥នាក់) ដើម្បីកំណត់អត្តសញ្ញាណគ្រួសារងាយរងគ្រោះនិងគូរផែនទីសហគមន៍ ភូមិក្នុងសង្កាត់គោលដៅទាំង ៣ គឺ សង្កាត់គោកឃ្លាង សង្កាត់ឃ្មួញ និងសង្កាត់ទឹកថ្លា។ សកម្មភាពសំខាន់ពីរដែលបានបញ្ចប់នៅក្នុងការធ្វើផែនទីសហគមន៍គឺការប្រមូលចំនួនគ្រួសារយោងទៅតាមសូចនាករនីមួយៗដែលធ្វើឡើងដោយគណៈកម្មការស្ត្រី និងកុមារ ព្រមទាំងមេភូមិ ហើយការគូរផែនទីសហគមន៍ ឬផែនទីភូមិដែលអនុវត្តដោយមេភូមិ។ សូចនាករដែលត្រូវបានប្រើនៅក្នុងដំណើរការធ្វើផែនទីសហគមន៍ត្រូវបានបង្កើតឡើងដោយក្រសួងមហាផ្ទៃ សម្រាប់ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ។ សូចនាករទាំងនេះត្រូវបានប្រើប្រាស់ដោយឃុំ/សង្កាត់ទូទាំងប្រទេស។

១០.៣ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ចំនួន១០នាក់ (ស្ត្រី០៨នាក់) ដែលមានសមត្ថភាពអនុវត្តគម្រោងក្របខណ្ឌគណនេយ្យភាពសង្គម បន្ទាប់ពីទទួលបានការគាំទ្រនិងពង្រឹងសមត្ថភាព។ ពួកគេមានសមត្ថភាពពន្យល់ពីព័ត៌មាននៃក្របខណ្ឌគណនេយ្យភាពសង្គម រួមមានសិទ្ធិរបស់ប្រជាពលរដ្ឋ តាមរយៈយុទ្ធនាការនៃការចុះផ្សព្វផ្សាយតាមផ្ទះ ដោយបានចែកសៀវភៅកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋចំនួន ២,៦០០ក្បាល ជូនដល់ពលរដ្ឋ ជាពិសេសពលរដ្ឋក្រីក្រ។ ពួកគេក៏បានចែករំលែកព័ត៌មាន និងបទពិសោធន៍ទៅដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគន៍ក្រុងតាខ្មៅ ជាពិសេសការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋ តាមរយៈការប្រជុំផ្សព្វផ្សាយផ្ទាល់ និងតាមម៉ូតូកង់បីចល័ត។ យ៉ាងហោចណាស់មានជនដែលមានពិការភាពចំនួន១៧% (៧៥នាក់) ស្ត្រីងាយរងគ្រោះ១៣% (៥៦នាក់) ក្នុងចំនោមអ្នកចូលរួមសរុបចំនួន ៤៤៦នាក់ ដែលបានទទួលចំណេះដឹងពីការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋ តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយផ្ទាល់ពីកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍។

១០.៤ មានតំណាងប្រជាពលរដ្ឋសរុបចំនួន ៣០៦ នាក់ (ស្ត្រី២០០នាក់ ស្មើ៦៥%) សកម្មចូលរួមក្នុងដំណើរការកិច្ចប្រជុំដាក់ពិន្ទុចំនួន០៨លើក ហើយពួកគេអាចកំណត់សូចនាករសម្រាប់វាយតម្លៃអ្នកផ្តល់សេវាកម្ម។ អ្នកផ្តល់សេវាកម្មចំនួន ៣២២នាក់ (ស្ត្រី១៦៤ នាក់ ស្មើ៥១%) មកពីសាលាបឋមសិក្សាចំនួន០៧ មណ្ឌលសុខភាពចំនួន០៤ សង្កាត់ចំនួន០៣ និងខណ្ឌសែនសុខ បានចូលរួមស្វ័យដាក់ពិន្ទុក្នុងកិច្ចប្រជុំ១៥លើក។ ពួកគេបានទទួលស្គាល់ថាការដាក់ពិន្ទុធ្វើឱ្យប្រសើរឡើងនូវសេវាកម្មសាធារណៈ។ លើសពីនេះទៅទៀត តំណាងប្រជាពលរដ្ឋ និងអ្នកផ្តល់សេវាចំនួន៨៥នាក់ (ស្ត្រី៤៣នាក់ ស្មើ៥១%) បានចូលរួមយ៉ាងសកម្មក្នុងកិច្ចប្រជុំរួម០៤ផ្សេងគ្នា។ គណៈកម្មការផែនការសកម្មភាពរួមគណនេយ្យភាពសង្គមចំនួន០៤ ត្រូវបានបង្កើតឡើង ដោយមានតួនាទីក្នុងការអនុវត្តផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមឆ្នាំ២០២១។



១០.៥ យើងបានរកឃើញតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមឆ្នាំ ២០១៩ តាមរយៈកិច្ចប្រជុំត្រួតពិនិត្យផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម ដូចជា៖ ការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរដ្ឋាភិបាល ការអប់រំប្រជាពលរដ្ឋអំពីការគ្រប់គ្រងសំរាម ការពង្រឹងសន្តិសុខភូមិ និងសង្កាត់ ការស្ថាបនាផ្លូវថ្នល់ និងជំរាលសម្រាប់ជនមានពិការភាពនៅមណ្ឌលសុខភាព ការមិនមានការបង់ប្រាក់ក្រៅផ្លូវការនៅសាលាបឋមសិក្សា តម្រូវការបន្ថែមគ្រូ និងជួសជុលបន្ទប់ទឹកជាដើម។ ផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម សង្កាត់ទឹកថ្លា សង្កាត់គោកឃ្លាង និងខណ្ឌសែនសុខបានអនុវត្ត១០០% ហើយផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គមសង្កាត់ឃ្មួញដោះស្រាយបាន៩៦% ខណៈដែលផែនការសកម្មភាពរួមដែលនៅសល់ត្រូវបានស្នើឡើងទៅថ្នាក់លើរបស់ពួកគេឱ្យជួយដោះស្រាយបន្ត។

១០.៦ មានអ្នកចូលរួមសរុបចំនួន ២៤០នាក់ (ស្ត្រី១០៦នាក់) តំណាងមកពីអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ ក្រសួងអប់រំ យុវជននិងកីឡា ក្រសួងសុខាភិបាល អាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអង្គការដៃគូសង្គមស៊ីវិល ដែលបានចូលរួមចំណែកយ៉ាងពេញលេញក្នុងការកែរលំអរគោលការណ៍ណែនាំស្តីពីការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម ដោយបញ្ចូលនូវបរិយាប័ន្នសង្គម និងពិការភាពក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពីថវិកាដើម្បីការអភិវឌ្ឍន៍ គណនេយ្យភាពសង្គម ប្រកបដោយប្រសិទ្ធិភាព បរិយាប័ន្ន និងសមធម៌ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០។ វាក៏រួមចំណែកក្នុងការពង្រឹងទំនាក់ទំនងរវាងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍/អ្នកសម្របសម្រួលសហគមន៍ អង្គការសង្គមស៊ីវិល និងក្រសួងពាក់ព័ន្ធនានា។ វាក៏ជាឱកាសមួយរបស់ពួកគេក្នុងការចែករំលែក វឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍នានា ដើម្បីស្វែងរកយុទ្ធសាស្ត្ររួមគ្នាក្នុងការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២។

១០.៧ តំណាងពលរដ្ឋងាយរងគ្រោះសរុប ១០២នាក់ (ស្ត្រី៣៦នាក់) មកពីសង្កាត់ទឹកថ្លា សង្កាត់គោកឃ្លាង និងសង្កាត់ឃ្មួញ បានចូលរួមសម្ភាសន៍ដោយអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ តាមរយៈការផ្តល់យោបល់លើសេវាកម្ម/ការស្ទង់មតិពិន្ទុជាមួយក្រុមដែលងាយរងគ្រោះ៖ ប្រជាពលរដ្ឋដែលមានបណ្ណក្រីក្រ ជនមានពិការភាព និងកុមារបោះបង់ចោលការសិក្សា។ ជាលទ្ធផល ពលរដ្ឋងាយរងគ្រោះមានឱកាសនិងរីករាយក្នុងការលើកឡើងនូវកង្វល់ តម្រូវការ និងសំណូមពររបស់ពួកគេទៅកាន់អ្នកផ្តល់សេវានៅក្នុងតំបន់គោលដៅរបស់ពួកគេ។

១០.៨ ទិដ្ឋភាពបច្ចេកទេសនៃបរិយាប័ន្ន ត្រូវបានដាក់បញ្ចូលទៅក្នុងម៉ូឌុលនៃវគ្គបណ្តុះបណ្តាល។ បរិយាប័ន្នយេនឌ័រ និងផែនទីសេវាកម្មត្រូវបានកំណត់ជាម៉ូឌុលនៃវគ្គបណ្តុះបណ្តាល។ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍បានដឹងពីទិដ្ឋភាពការកៀរគរសម្រាប់បរិយាប័ន្ន ទស្សនៈស្តីពីវិធីដើម្បីជួយសម្រួលដល់ពលរដ្ឋងាយរងគ្រោះ។ លើសពីនេះទៅទៀត ពួកគេដឹងថាការដាក់ពិន្ទុដោយពលរដ្ឋ និងស្វ័យវាយតម្លៃគឺជាសកម្មភាពដែលឆ្លើយតបទៅនឹងបរិយាបន្ន័។



១០.៩ ការទំនាក់ទំនងល្អរវាង អង្គការAPI រដ្ឋបាលខណ្ឌសែនសុខ មណ្ឌលសុខភាព សាលាបឋមសិក្សា និងសាលាសង្កាត់ទាំង៣ ជាមូលហេតុចំបងដែលធ្វើឱ្យការអនុវត្តគណនេយ្យភាពសង្គមនៅខណ្ឌសែនសុខទទួលបានជោគជ័យ។ មិនត្រឹមតែការចូលរួមសកម្មភាពអនុវត្តគម្រោងប៉ុណ្ណោះទេ រដ្ឋបាលខណ្ឌសែនសុខក៏បានបង្ហាញផែនការសកម្មភាពរួមស្តីពីគណនេយ្យភាពសង្គម នៅក្នុងសិក្ខាសាលាសមាហរណកម្មថ្នាក់ខណ្ឌ។

១០.១០ អ្នកទទួលផលនៅតាមតំបន់គោលដៅបានដឹងអំពីការអនុវត្តគម្រោងដោយបង្ហាញពីភាពមើលឃើញរបស់អ្នកអនុវត្តគម្រោង និងម្ចាស់ជំនួយនៅគ្រប់សកម្មភាពផ្សព្វផ្សាយ រួមមានការបោះពុម្ពផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋចំនួន ២៦០០ក្បាល អាវ១៨ និងឯកសារបោះពុម្ពផ្សេងៗទៀត ព្រមទាំងបណ្តាញអ៊ីនធឺណិតដូចជាការផលិតវីដេអូជីវចលចំនួន០៤ វីដេអូរឯកសារគម្រោង០១និងទំព័រហ្វេសប៊ុករបស់ API។

បន្ថែមពីនេះទៅទៀត នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២០ តំណាងប្រជាពលរដ្ឋក្រីក្រចំនួន១៥០គ្រួសាររស់នៅក្នុងសង្កាត់ទាំង៣ ក្នុងខណ្ឌសែនសុខ បានទទួលជំនួយសង្គ្រោះបន្ទាន់ រួមមានថវិកា៩,៧៥០ដុល្លារអាមេរិកពីមូលនិធិWild Ganzen ប្រទេសហូឡង់ និងអង្ករ៣តោន មី១៥០កេះ ត្រីខកំប៉ុង១៥០យួរ ទឹកស៊ីអ៊ីវ១៥០យួរពីរដ្ឋបាលខណ្ឌសែនសុខ និងសប្បុរសជននៅមូលដ្ឋាន។ គ្រួសារនីមួយៗទទួលបានថវិកាចំនួន ៦៥ដុល្លារអាមេរិក អង្ករ២៥គ.ក មី០១កេះ ត្រីខ១២កំប៉ុង ទឹកស៊ីអ៊ីវ០៦ដប។

## មេរៀនបទពិសោធន៍៖

១០.១១ នីតិវិធីនៃរដ្ឋបាលនៃស្ថាប័នសាធារណៈ រួមមានខណ្ឌសែនសុខ ដើម្បីធ្វើសកម្មភាពណាមួយ តែងតែមានលិខិតផ្លូវការ និងចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នា។

១០.១២ ការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម គឺជាគម្រោងថ្នាក់ជាតិមួយដែលបានបង្ហាញនូវកិច្ចសហប្រតិបត្តិការជាផ្លូវការទាំងផ្នែកផ្គត់ផ្គង់ (រដ្ឋាភិបាល និងផ្នែកតម្រូវការ (សង្គមស៊ីវិល)។ ការជួយជ្រោមជ្រែងរបស់ គ.ជ.អ.ប គឺជា គន្លឹះនៃការអនុវត្តគម្រោងប្រកបដោយជោគជ័យ និងមានផ្លែផ្កា។ បច្ចុប្បន្នខណ្ឌបានទទួលការផ្ទេរមុខងាររួចហើយទាក់ទងនឹងតួនាទី និងធនធានដូច្នេះពួកគេអាចចូលរួម និងគាំទ្រដល់ដំណើរការនៃការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម។

១០.១៣ យើងត្រូវទាក់ទងជាមួយមន្ត្រីសាធារណៈខណ្ឌ និងសង្កាត់ជាមុន ដើម្បីកំណត់ពេលវេលាសមស្របមុនពេលដាក់លិខិតផ្លូវការជូនពួកគេ។

១០.១៤ ឥរិយាបថរបស់មន្ត្រីសាធារណៈមានការផ្លាស់ប្តូរជាវិជ្ជមានក្នុងពេលអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម ជាពិសេសប្រជាពលរដ្ឋបានដឹងពីសិទ្ធិរបស់ពួកគេក្នុងការទទួលបាននូវសេវាសាធារណៈ។



១០.១៥ ប័ណ្ណពិន្ទុឌីជីថលៈ មន្ត្រីខណ្ឌ និងសង្កាត់បានសម្តែងការសាទរចំពោះប័ណ្ណពិន្ទុឌីជីថល នៅពេលដែលពួកគេបានទទួលស្គាល់អំពីបញ្ហាប្រឈម ការប្រើប្រាស់ពេលវេលាយ៉ាងច្រើនក្នុងការរៀបចំ និងសម្រួលដល់ប័ណ្ណពិន្ទុ។ ពួកគេស្នើថា ប័ណ្ណពិន្ទុឌីជីថល អាចជួយឱ្យមានការវាយតម្លៃ និងដាក់ពិន្ទុ កាន់តែច្រើនពីពលរដ្ឋ។ ពួកគេចង់ឱ្យមានមនុស្សកាន់តែច្រើនចូលរួមក្នុងដំណើរការត្រួតពិនិត្យដោយពលរដ្ឋ ហើយពួកគេជឿជាក់ថា ប័ណ្ណពិន្ទុឌីជីថលប្រហែលជាដំណោះស្រាយមួយដ៏ល្អ។

១០.១៦ ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ពលរដ្ឋ តាមប្រព័ន្ធផ្សព្វផ្សាយសង្គម បានបង្កើនការយល់ដឹងពីការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គមពីសាធារណៈជនយ៉ាងទូលំទូលាយ។ នាពេលបច្ចុប្បន្ននេះ ពលរដ្ឋភាគច្រើនដែលរស់នៅក្នុងទីក្រុង មានទូរស័ព្ទស្មាតហ្វូន ដែលអាចចូលប្រើអ៊ីនធឺណិតបានគ្រប់ពេល ហើយវាជាបណ្តាញដ៏មានប្រសិទ្ធភាពក្នុងការចែករំលែក និងទទួលបាននូវព័ត៌មានណាមួយ។

១០.១៧ អង្គការ API ទទួលបានបទពិសោធន៍ថ្មី ក្នុងការផលិតវីដេអូជីវចលជាពិសេសក្នុងការបង្កើត អត្ថបទ និងស្វែងរកដៃគូ ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដល់ផលិតកម្ម។

## បញ្ហាប្រឈម៖

១០.១៦ ជំងឺកូវីដ១៩ នៅតែជាបញ្ហាធំមួយដែលមិនអនុញ្ញាតឱ្យមានការប្រជុំជាសាធារណៈនៅតំបន់មួយចំនួនឡើយ។ ដំណោះស្រាយ៖ សកម្មភាពគម្រោងអនុវត្តដោយការរក្សាគម្លាត ការពាក់ម៉ាស់ ប្រើប្រាស់អាល់កុល និងការរក្សាអនាម័យ។ ការប្រើប្រាស់ឧបករណ៍ទំនាក់ទំនងតាមអ៊ីនធឺណិត ដើម្បីផ្សព្វផ្សាយការយល់ដឹងកញ្ចប់ព័ត៌មានប្រជាពលរដ្ឋ។ កំណត់អ្នកចូលរួមតិចប្រមាណ ១៥នាក់ទៅ៣០នាក់នូវរាល់កិច្ចប្រជុំនីមួយៗ។

១០.១៧ មុខងាររបស់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ គឺជាការងារស្ម័គ្រចិត្ត ហើយវាពិបាកក្នុងការទាក់ទាញយុវជន ឬសាធារណៈជនឱ្យដាក់ពាក្យជាអ្នកស្ម័គ្រចិត្ត។ ដូចគ្នានេះផងដែរ វាត្រូវចំណាយពេលច្រើនក្នុងការកសាងសមត្ថភាពអ្នកស្មគ្រ័ចិត្តថ្មីដែលត្រូវបានជ្រើសរើស។

ខណ្ឌសែនសុខ ព្យាយាមកៀរគរវិស័យឯកជន និងក្រុមអ្នកលក់ដូរ ម្ចាស់ហាងនានា ក្រុមហ៊ុននិងសមាគមផ្សេងៗ ប៉ុន្តែមានការចូលរួមតិចតួចក្នុងចំណោមពួកគេ។ ក្រុមហ៊ុនជាច្រើនបានបញ្ជូនតំណាងរបស់ពួកគេឱ្យចូលរួមដែលតំណាងទាំងនោះមិនអាចធ្វើសេចក្តីសម្រេចចិត្ត ឬផ្តល់មតិយោបល់លើបញ្ហាដែលបានលើកឡើងឡើយ។




**គម្រោងទី១១៖** **គម្រោងគាំទ្រការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយអត្ថន័យតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពសង្គម (ខែធ្នូ ២០១៩-២០២៣)**

### គោលបំណងរួម៖

ដើម្បីបង្កើននូវប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាពរបស់អង្គភាពគ្រប់កម្រិត និងធានាបាននូវលទ្ធភាពទទួលបានព័ត៌មាន និងសេរីភាពជាមូលដ្ឋាន (SDG 16)

### គោលបំណងជាក់លាក់៖

ដើម្បីផ្តល់នូវសិទ្ធិអំណាចដល់យុវជនជនជាតិដើមភាគតិចធ្វើឱ្យការគ្រប់គ្រងមានការចូលរួម តម្លាភាព ការឆ្លើយតប និងគណនេយ្យភាព ដោយការប្រើនូវឥទ្ធិពលនៃបច្ចេកវិទ្យាឌីជីថល។

### ថវិកាគម្រោង៖

៣៨,១៣៣.៣៥ ដុល្លាអាមេរិចនៃថវិកាសរុប២.៥លានអឺរ៉ូ ពីសហភាពអឺរ៉ុប រួមគ្នាដល់អង្គការ API, CARE and INSTEDD

### ដៃគូអនុវត្ត៖

API CARE and INSTEDD និងអង្គការដៃគូក្នុងស្រុកចំនួន១៣

### តំបន់គោលដៅ៖

ខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និងកោះកុង





## សកម្មភាព និងលទ្ធផលៈ

១១.១ ការអនុវត្តនូវក្របខ័ណ្ឌគណនេយ្យភាពសង្គមនៅក្នុងសម័យបច្ចេកវិទ្យាតាមរយៈគម្រោង គាំទ្រឱ្យមានការចូលរួមពីប្រជាពលរដ្ឋដ៏មានអត្ថន័យនេះបានទទួលស្គាល់និងចុះអនុសារណៈជាមួយគណម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប្បតេយ្យនៅថ្នាក់ក្រោមជាតិ។

១១.២ មន្ត្រីគម្រោងតាមតំបន់គោលដៅនៅមូលដ្ឋានមានទំនុកចិត្តក្នុងការអនុវត្តគម្រោងប្រកបដោយជោគជ័យបន្ទាប់ពីទទួលបានវគ្គតម្រង់ទិសនិងជំនាញពាក់ពន្ធ័។ក្រុមមន្ត្រីគម្រោងបានពិនិត្យមើលនិងកែលំអនូវឯកសារបណ្តុះបណ្តាល បង្កើតនូវវគ្គបណ្តុះបណ្តាលតាមអនឡាញ និងផ្តល់ការបណ្តុះបណ្តាលតាមអនឡាញដល់មន្ត្រីគម្រោងរបស់អង្គការ API, CARE Cambodia and InSTEED។ ក្រុមមន្ត្រីគម្រោងបានចូលរួមប្រជុំប្រចាំខែ ដើម្បីសហការសម្របសម្រួល និង លើការងារបច្ចេកទេសទាំងតាមអ៊ីនទើណែតនិង ប្រជុំផ្ទាល់មុខជាមួយនឹង ក្រុមអនុវត្តផែនការគណនេយ្យភាពសង្គម ផ្នែកតម្រូវការ និងបានបង្កើនសមត្ថភាពមន្ត្រីគម្រោងចំនួន៣៣រូប លើជំនាញបច្ចេកទេសក្នុងការអនុវត្ត ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម។

១១.៣ វេទិការៀនតាមអ៊ិនធឺណែតត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs) ដើម្បីអនុវត្ត។ ខ្លឹមសារនៃវេទិកាតាមអ៊ិនធឺណែតនេះរួមបញ្ចូលគ្រប់ជំហាននៃការអនុវត្ត ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម(I-SAF) នៅមូលដ្ឋាន ជាពិសេសគោលការណ៍ណែនាំជាក់លាក់នៃសកម្មភាពនីមួយៗ។

១១.៤ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs) ដែលមានបទពិសោធន៍ក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (I-SAF) ក្នុងដំណាក់កាលទី ១ បានបង្កើននូវសមត្ថភាពនិងយល់ដឹងច្បាស់អំពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (I-SAF) នៅដំណាក់កាលទី ២ ។ CAFs មានបទពិសោធន៍ចំនួន ១១៧ នាក់ក្នុងនោះមានស្រី ៧៧ នាក់ (ក្នុងចំណោម CAFs ចំនួន៤៨៨ នាក់ក្នុងខេត្តចំនួន ៥) បានបង្កើនចំណេះដឹងអំពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (I-SAF) ដំណាក់កាលទី ២ តាមរយៈវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ចំនួន ៤ វគ្គនៅតាមខេត្តគោលដៅ ទាំង៥ ។

១១.៥ CAFs ថ្មីសរុបចំនួន ៦៨ (ស្រី ៣៩) នៅក្នុងស្រុកចំនួន ៥ នៃខេត្តរតនគិរីបានបង្កើនសមត្ថភាពនិងការយល់ដឹងច្បាស់អំពីការអនុវត្តផែនការ I-SAF នៅដំណាក់កាលទី ២។ លទ្ធផលនៃការបណ្តុះបណ្តាលបានបង្ហាញថាមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងរវាងការធ្វើតេស្តមុនដែលក្នុងនោះ ៧៦% នៃអ្នកចូលរួមទទួលបានពិន្ទុក្រោមមធ្យម ប៉ុន្តែការប្រលងក្រោយវគ្គមានត្រឹមតែ ៦ នាក់ប៉ុណ្ណោះដែលត្រូវការពេលវេលាបន្ថែមទៀតក្នុងការកសាងសមត្ថភាព និងCAFs ផ្សេងទៀតទទួលបានពិន្ទុបង្គួរ និងល្អ ។



១១.៦ លើសពីនេះទៀតមានការបង្កើនសមត្ថភាពដល់អ្នកចូលរួម ២៩៧ នាក់ (ស្រី ៦៨ នាក់) ដែលជាតំណាងមកពីសាលាក្រុង ស្រុក ឃុំ សង្កាត់ មណ្ឌលសុខភាព និងសាលាបឋមសិក្សាក្នុងខេត្តគោលដៅចំនួន ៤ (ខេត្តក្រចេះ ស្ទឹងត្រែង រតនគីរី និងមណ្ឌលគីរី) ស្តីពី **ការអនុវត្ត ផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម** (I-SAF) នៅដំណាក់កាលទី ២ ដោយកិច្ចសហការជាមួយ មន្ត្រីបច្ចេកទេស គ. ជ. អ. ប. និង អង្គការ API និងរដ្ឋបាលខេត្តទាំងបួន ។ ទំនាក់ទំនងដ៏ប្រសើរ រវាងអង្គការក្រៅរដ្ឋាភិបាលដៃគូក្នុងស្រុក មន្ត្រីបង្គោល I-SAF នៅគ្រប់កំរិតទាំងថ្នាក់ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងមន្ត្រីអង្គការដៃគូនៅតាមខេត្ត ធ្វើឱ្យយើងរំពឹងយ៉ាងមុតមាំថាការអនុវត្តគម្រោងនេះនឹងនាំទៅរកភាពជោគជ័យ ។

១១.៧ អ្នកតំណាងសរុបចំនួន ២៤០ នាក់ (ស្រី ១០៦ នាក់) ជាអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAF) ក្រសួងអប់រំ ក្រសួងសុខាភិបាល រដ្ឋបាលជាតិនិងថ្នាក់ក្រោមជាតិ និងដៃគូបានចូលរួមចំណែកយ៉ាងពេញលេញក្នុងការកែលម្អគោលការណ៍ណែនាំ I-SAF ដោយបញ្ចូលបរិយាប័ន្នសង្គមនិងពិការភាព នៅក្នុងសិក្ខាសាលាថ្នាក់ជាតិស្តីពី "ថវិកាសម្រាប់ការអភិវឌ្ឍគណនេយ្យភាពសង្គមប្រកបដោយប្រសិទ្ធភាព មានបរិយាប័ន្ន និងប្រកបដោយសមធម៌" នៅក្នុងខែតុលាឆ្នាំ ២០២០។ ជាការចូលរួមចំណែកពង្រឹង និងពង្រីកទំនាក់ទំនងរវាងអង្គការ និងក្រសួងពាក់ព័ន្ធ។ ក៏ជាឱកាសមួយសម្រាប់ពួកគេបានចែករំលែក វឌ្ឍនភាព បញ្ហាប្រឈម និងអនុសាសន៍នានាដើម្បីស្វែងរកយុទ្ធសាស្ត្រដើម្បីរួមគ្នាអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម (I-SAF)នៅដំណាក់កាលទី ២ ។ សិក្ខាសាលានេះធ្វើឡើងក្រោមកិច្ចសហការរបស់ API ស្តារកម្ពុជា CDPP CARE FHI360 World vision Cambodia Oxfam និងNCDD។

## មេរៀនជាបទពិសោធន៍៖

១១.៨ យ៉ាងហោចណាស់ អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs ) ប្រហែល ៨៥% មានស្មាតហ្វូនហើយអាចចូលប្រើអ៊ីនធឺរណែតបានដូច្នេះយើងអាចធ្វើវីដេអូអំពីរបៀបតំឡើងនិងបង្កើតគណនីជីម៉ែលនិងថ្នាក់រៀនតាមហ្គូហ្គល ដោយមានអង្គការដៃគូបានជួយក្នុងម៉ោងសិក្សា។ អ្នកជំនាញផ្នែក ព័ត៌មានវិទ្យារបស់គម្រោងបានផ្តល់ការគាំទ្រផ្នែកព័ត៌មានវិទ្យាដល់អ្នកដែលមានបញ្ហាទាក់ទងនឹងការបង្កើតគណនីហ្គូហ្គល និងថ្នាក់រៀនហ្គូហ្គល។ ដើម្បីផ្តល់ការគាំទ្រនិងទំនាក់ទំនងបន្ថែមទៀត ក្រុមការងារគម្រោងបានបង្កើតក្រុមតេឡេក្រាមសម្រាប់ក្រុមគោលដៅនីមួយៗ។ អ្នកបណ្តុះបណ្តាលបាននាំយកថេប្លេត (tablets) មួយចំនួនដើម្បីគាំទ្រដល់អ្នកចូលរួមមួយចំនួនដែលគ្មានស្មាតហ្វូនឬពួកគេមិនអាចចូលប្រើអ៊ីនធឺណិតបាន។ ការភ្ជាប់អ៊ិនធឺរណែតមាននៅក្នុងបន្ទប់បណ្តុះបណ្តាលតាមការប្រើឧបករណ៍ចល័តឥតខ្សែ (wireless mobile routers) ចំនួន ៣ ដែលអាចឱ្យសិក្ខាកាមប្រើប្រាស់អ៊ិនទើណែតបាន។

១១.៩ ការប្រើប្រាស់ភាសាសាមញ្ញងាយយល់ និងជៀសវាងពាក្យបច្ចេកទេស និងអក្សរកាត់ច្រើនពេកក្នុងពេលបណ្តុះបណ្តាល ដោយសរសេរពាក្យទាំងនោះនៅលើក្រដាសផ្ទាំងធំ រួចបិទជាប់នឹងជញ្ជាំងថ្នាក់រៀន ដែលអាចឱ្យសិក្ខាកាមជា CAFs ងាយស្រួលចងចាំ ។



១១.១០ ទាំងបុគ្គលិក និងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ (CAFs) បានប្តូរបាំងនៃការរីករាលដាលកូវីដ-១៩ ទៅជាការពង្រឹងមុខងារបច្ចេកវិទ្យា។ វាមានសារប្រយោជន៍ខ្លាំងណាស់ក្នុងការទាក់ទងមនុស្សដោយចំណាយថវិកាតិច និងចំណេញពេលវេលាសម្រាប់ធ្វើដំណើរ។

## បញ្ហាប្រឈម៖

១១.១១ ការកើនឡើងចំនួនឃុំគោលដៅនិងអ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍តាមស្រុកនីមួយៗនាំឱ្យមានការបង្កើនចំនួនការបណ្តុះបណ្តាល ថវិកា និងធនធានមនុស្ស ។ យើងនឹងទាក់ទងតំណាងអង្គការដៃគូដែលមានសក្តានុពលក្នុងអង្គការក្រៅរដ្ឋាភិបាលចូលរួមជាមួយអង្គការ API ក្នុងការបណ្តុះបណ្តាល។ អង្គការ CARE និង API បានសម្រេចចិត្តធ្វើការបែងចែកថវិកាឡើងវិញ ដោយយកថវិកាសម្រាប់បណ្តុះបណ្តាលដល់ផ្នែកផ្តត់ផ្គង់ សម្រាប់បណ្តុះបណ្តាលដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលបានជ្រើសរើសថ្មី។

១១.១២ ជាបញ្ហាធំកូវីដ-១៩ សកម្មភាពខ្លះត្រូវបានពន្យារពេលជាច្រើនដង មិនអនុញ្ញាតឱ្យមានការប្រជុំសាធារណៈណាមួយឡើយ។ សកម្មភាពគម្រោងបានរក្សាគម្លាតសង្គម មានម៉ាសសម្រាបពាក់ការពារ និងអាល់កុលសម្រាប់ សម្អាតដៃនៅពេលមានការប្រជុំ និងវគ្គសិក្ខាសាលា និងមិនអនុញ្ញាតឱ្យ មានអ្នកចូលរួមមិនលើសពី ៥០ នាក់នៅទីតាំងឯកជន ដូចជា កន្លែងបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ដែលធ្វើនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលការិយាល័យអង្គការការីតាស។ ឧបករណ៍ទំនាក់ទំនងតាមអ៊ិនធើណេតត្រូវបានប្រើសម្រាប់ផលិតវីដេអូគំនូជីវចល ស្តីពីកញ្ចប់ពត៌មានសម្រាប់ពលរដ្ឋ និងទំព័រហ្វេសប៊ុក សម្រាប់ជ្រើសរើសCAFs ដោយជំនួសការជួបផ្ទាល់មុខ នៅក្នុងការប្រជុំសាធារណៈ ។

## ផែនការឆ្ពោះទៅមុខ៖

១១.១៣ ពន្លឿនវគ្គបណ្តុះបណ្តាលដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្មី និងមន្ត្រីផ្នែកផ្តត់ផ្គង់សេវានៅតាមស្រុកនិងឃុំគោលដៅថ្មី។





## គម្រោងទី១២៖ គម្រោងការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា (I-SAC) (២០២០-២០២៣)

### គោលដៅរបស់គម្រោង៖

គឺគាំទ្រដល់ប្រជាពលរដ្ឋក្នុងការបង្កើនសមត្ថភាពរបស់ពួកគេទទួលបាននូវកញ្ចប់ព័ត៌មាន និងពង្រឹងបណ្តាញសកម្មភាព ជួយគាំទ្រពួកគេក្នុងការកសាងតម្រូវការសាធារណៈ និងបង្កើតដំណោះស្រាយដើម្បីលើកយកបញ្ហាអាទិភាពរបស់សហគមន៍។

### ថវិកាគម្រោង៖

៣៨១,៥៩៨ ដុល្លាក្នុងឆ្នាំ២០២០ដល់២០២៣ ពីទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈអង្គការសុខភាពគ្រួសារអន្តរជាតិ (FHI 360)។

### តំបន់គោលដៅ៖

១០សង្កាត់ក្នុងក្រុងតាខ្មៅ ខេត្តកណ្តាល ប្រទេសកម្ពុជា





## សកម្មភាព និងលទ្ធផល៖

១២.១ គម្រោងការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅប្រទេសកម្ពុជា (I-SAC) បានចាប់ផ្តើមអនុវត្តទូទាំង ១០សង្កាត់ ក្នុងតាខ្មៅ។ សកម្មភាពសំខាន់ដែលសម្រេចបានមានដូចជា៖ ប្រជាពលរដ្ឋទទួលបានភាពងាយស្រួលនូវសិទ្ធិរបស់ពួកគេក្នុងសេវាទាំង៣ ដែលមានសាលាបឋមសិក្សា មណ្ឌលសុខភាព និង សេវារដ្ឋបាលសង្កាត់ តាមរយៈការផ្សព្វផ្សាយតាមឃោសនសព្ទចំនួន២០ដង អំពីកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ កិច្ចសន្ទនាផ្សាយផ្ទាល់រួមគ្នាតាមរយៈស្ថានីយផ្សាយរបស់វិទ្យុសំឡេងប្រជាធិបតេយ្យ VOD និងបណ្តាញសង្គមរបស់វិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយ ។

១២.២ កសាងសមត្ថភាពដល់អ្នកស្ម័គ្រចិត្តចំនួន៤៣នាក់ពីគណនេយ្យភាពសង្គម។ គម្រោងបានធ្វើការជ្រើសរើស និងកសាងសមត្ថភាពចំនួន៤៣រូប ស្រី២៦នាក់ ក្របខ័ណ្ឌគណនេយ្យភាពសង្គមរយៈពេល៤ថ្ងៃ និងជំនាញសម្របសម្រួលកិច្ចប្រជុំផ្សព្វផ្សាយ កញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ ការបើកចំហរព័ត៌មានថវិកា និង សុវត្ថិភាពឌីជីថលចំនួន៤ថ្ងៃទៀត។

១២.៣ បណ្តាញទំនាក់ទំនងសម្រាប់អ្នកសម្របសម្រួលគណនេយ្យភាពសង្គមក្រុមបណ្តាញសង្គមតេឡេក្រាម Telegram មួយត្រូវបានបង្កើតឡើងសម្រាប់ទំនាក់ទំនងជាមួយអ្នកសម្របសម្រួលដែលមានសមាជិកភាព ៤៣នាក់ ស្រី២៦នាក់។ បណ្តាញសង្គមនេះត្រូវបានបង្កើតឡើងដោយ និងបានប្រើប្រាស់យ៉ាងទូលំទូលាយជាមួយអ្នកសម្របម្រួលនៅក្នុងតាខ្មៅ ដូចជា៖ សម្រាប់ផ្តល់សម្ភារៈបណ្តុះបណ្តាល ការចាត់ចែងផ្សេងៗ ក៏ដូចជាការកំណត់នូវការរៀបចំប្រជុំ។

## មេរៀនបទពិសោធន៍៖

១២.៤ មិនសូវមានចំនួនមនុស្សវ័យក្មេងដាក់ពាក្យឱ្យបានច្រើនជាអ្នកសម្របសម្រួលគណនេយ្យភាពសង្គម មកពី១០ សង្កាត់ក្នុងក្រុងតាខ្មៅ។ ៦នាក់(ស្រី៥នាក់) អ្នកសម្របសម្រួលគណនេយ្យភាព សហគមន៍បានបញ្ចប់ការងារស្ម័គ្រចិត្តរបស់ពួកគេជាមួយគម្រោង ដូច្នេះវិទ្យាស្ថានតស៊ូមតិនិងគោលនយោបាយបានរៀបចំយុទ្ធសាស្ត្រសម្រាប់ផ្ទេរចំណេះដឹង និងផ្តល់ព័ត៌មានទៅដល់អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍ថ្មី ដើម្បីបណ្តុះបណ្តាលនិងអនុវត្តសកម្មភាពគម្រោង។

១២.៥ ខេត្តកណ្តាលគឺជាតំបន់គោលដៅថ្មីសម្រាប់ API ដែលមានតម្រូវការជាច្រើនសម្រាប់ការកសាងទំនុកចិត្ត និង ការកសាងភាពជាអ្នកដឹកនាំតាមលំដាប់ក្នុងការគាំទ្រទាំងថ្នាក់គោលនយោបាយនិងរដ្ឋបាល។ ក៏មានតម្រូវការជំនួយផ្នែកបច្ចេកទេសផងដែរ ហើយការពង្រឹងសម្ថតភាពផងដែរទៅដល់រូបវន្តបុគ្គលដែលជាអ្នកអនុវត្តផ្ទាល់។ សម្រាប់ដោះស្រាយបញ្ហាប្រឈមទាំងនេះ គម្រោងផែនការអនុវត្តគណនេយ្យភាពសង្គម វាគឺជាទស្សនទានដ៏ថ្មីស្រឡាងមួយសម្រាប់អាជ្ញាធរមូលដ្ឋានផងដែរ។ ក្រៅពីនោះក៏បានជួបប្រទះនូវបញ្ហាទឹកជំនន់ បញ្ហាជម្ងឺកូវីដ-១៩។



## បញ្ហាប្រឈម៖

ការតែងតាំងក្រុមការងារ ISAF ជាផ្លូវការ រួមមានថ្នាក់ដឹកនាំរដ្ឋបាលខេត្ត ក្រុង និងអង្គការសង្គមស៊ីវិលយឺតយ៉ាវ និងមិនទាន់បានកសាងសមត្ថភាពស្តីពី ISAF ដល់សមាជិកក្រុមការងារនិងថ្នាក់ដឹកនាំ ក៏ការពន្យាពេលការចាប់ផ្តើមជាផ្លូវការនៃក្រុម ISAF នៅខេត្តកណ្តាល និងក្រុមការងារ ISAC នៅក្រុងតាខ្មៅបានពន្យាការអនុវត្តសកម្មភាពគម្រោងដែលបានគ្រោងទុកនៅឆ្នាំ ២០២០។

## ផែនការឆ្ពោះទៅមុខ៖

១២.៦ បណ្តុះបណ្តាលទៅដល់មន្ត្រីបង្គោលគណនេយ្យភាពសង្គមខេត្ត និងក្រុងតាខ្មៅ ដើម្បីប្រមូលទិន្នន័យថវិកា ការបញ្ចូលនិងបង្ហាញប្រព័ន្ធទិន្នន័យតាមរយៈគេហទំព័រ ផ.អ.គ.ស

១២.៧ បណ្តុះបណ្តាលវគ្គទី៣ ដាក់ពិន្ទុសហគមន៍ គម្រោងការច្នៃប្រឌិតថ្មីសម្រាប់គណនេយ្យភាពសង្គមនៅប្រទេសកម្ពុជាទៅដល់អ្នកសម្របសម្រួលសហគមន៍ចំនួន៤០នាក់ដែលអាចជួយពួកគេឱ្យសម្របសម្រួលទាំងកិច្ចប្រជុំដាក់ពិន្ទុសហគមន៍ជាមួយតំណាងប្រជាពលរដ្ឋ និងវាយតម្លៃខ្លួនឯងជាមួយអ្នកផ្តល់សេវាពាក់ព័ន្ធ។

១២.៨ ការផ្សព្វផ្សាយកញ្ចប់ព័ត៌មានសម្រាប់ប្រជាពលរដ្ឋ តាមភូមិ ថ្នាក់សង្កាត់ កិច្ចប្រជុំផ្សព្វផ្សាយកញ្ចប់ព័ត៌មានប្រជាពលរដ្ឋតាមរយៈឃោសនសព្ទ កិច្ចប្រជុំតាមភូមិជាដើម។

១២.៩ កិច្ចប្រជុំណែនាំទូទាំងឃុំ និង កិច្ចប្រជុំពិភាក្សានិងកិច្ចប្រជុំដាក់ពិន្ទុសហគមន៍ ដោយប្រជាពលរដ្ឋនិងអ្នកផ្តល់សេវា

១២.១០ កិច្ចប្រជុំឆ្លុះបញ្ចាំងថ្នាក់ក្រុង





## គម្រោងទី១៣៖ សំឡេង និងសកម្មភាពរបស់ស្ត្រីដឹកនាំវ័យក្មេង និងសហគ្រិន (២០២០-២០២១)

### គោលបំណង៖
ដើម្បីពង្រីកសមត្ថភាព និងបង្កើតបរិយាកាសដល់ការចូលរួមពីយុវជន និងអ្នកដឹកនាំស្ត្រីវ័យក្មេង និងសហគ្រិនខ្នាតតូចក្នុងការផ្តល់ឱកាសអោយពួកគាត់ចូលរួមក្នុងជំនាញសហគ្រិនភាព និងសកម្មភាពតស៊ូមតិដែលទាក់ទងនឹងទាក់ទងនឹងការធ្វើពាណិជ្ជកម្ម និងកិច្ចសន្ទនាផ្សេងៗជាមួយអាជាធរនានា។ ការណ៍នេះ គឺជាផ្នែកមួយក្នុងការចូលរួមចំណែកដើម្បីពង្រឹងភាពម្ចាស់ការក្នុងការទទួលបាននូវឱកាសស្មើភាពគ្នា ក៏ដូចជាការពង្រឹងនូវសិទ្ធិរបស់ពួកគាត់ ដើម្បីសេដ្ឋកិច្ច-សង្គម។

### ថវិកាគម្រោង៖
៣៥ ៣៥៨ ដុល្លា គាំទ្រដោយ USAID តាមរយៈអង្គការ Pact កម្ពុជា

### ដៃគូរអនុវត្តគម្រោង៖
សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)។

### តំបន់គោលដៅ៖
ទូទាំងខណ្ឌក្នុងរាជធានីភ្នំពេញ





## សកម្មភាព និងលទ្ធផល៖

១៣.១ គម្រោងនេះផ្តោតលើការកសាងសមត្ថភាពតំណាងសហគ្រិនស្រ្តីវ័យក្មេងចំនួន ៤១ នាក់នៅក្នុងរាជធានីភ្នំពេញ។ ពួកគាត់ទទួលបានការបណ្តុះបណ្តាលរយៈពេល៣ថ្ងៃទៅលើការតស៊ូមតិជាមួយអ្នកធ្វើការសម្រេចចិត្តសំខាន់ៗ។ ផែនការសកម្មភាពតស៊ូមតិតាមខណ្ឌនីមួយៗត្រូវបានបង្កើត និងចងក្រងជាឯកសារដោយតំណាងសហគ្រិនស្រ្តីវ័យក្មេង ដើម្បីអនុវត្តនៅក្នុងផែនការឆ្នាំ២០២១។ លើសពីនេះទៀត ឯកសារគោល នយោបាយត្រូវបានដាក់ជូនអ្នកមានសេចក្តីសម្រេចចិត្តសំខាន់ៗដើម្បីស្វែងរកដំណោះស្រាយ និងមានឥទ្ធិពលលើការផ្លាស់ប្តូរគោលនយោបាយយោងទៅតាមបញ្ហាដែលលើកឡើងដោយតំណាងសហគ្រិនស្ត្រីវ័យក្មេង ក្នុងអំឡុងពេលបណ្តុះបណ្តាលនិងការផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារសង្គមនិងប្រកាសលេខ៤០៤ ស្តីពីប័ណ្ណសមធម៌របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

១៣.២ បញ្ហាប្រឈមសំខាន់ៗដែលបានជួបប្រទះ និងសំណូមពររបស់អាជីវករស្រ្តីលក់ដូរតាមដងផ្លូវក្នុងរាជធានីភ្នំពេញត្រូវបានចងក្រងជាឯកសារ និងដាក់បញ្ចូលទៅក្នុងផែនការតស៊ូមតិ។ គម្រោងនេះបានកំណត់និងផ្តល់អាទិភាពដល់បញ្ហាចំនួន២៣ជាក់លាក់ដែលស្ត្រីអ្នកលក់ដូរតាមដងផ្លូវបានជួបប្រទះ តាមរយៈការស្ទង់មតិតាមអ៊ិនធើណេត និងការសម្ភាសន៍ផ្ទាល់ជាមួយស្ត្រីចំនួន១៣១នាក់ និងបានធ្វើការបណ្តុះបណ្តាលទៅស្ត្រីចំនួន៤១នាក់។ ដោយផ្អែកលើបញ្ហាអាទិភាពទាំងនេះ គម្រោងនេះបានបង្កើតឯកសារគោលនយោបាយចំនួន១២ ដោយមានអនុសាសន៍សំខាន់ៗ ក្នុងការដាក់ទៅអាជ្ញាធរមូលដ្ឋាននៅក្នុងរាជធានីភ្នំពេញនៅក្នុងកម្រិតខណ្ឌ និងរាជធានីភ្នំពេញ។ ផ្អែកលើបញ្ហាអាទិភាពទាំងនេះ គម្រោងបានធ្វើការគាំទ្រដល់អ្នកតស៊ូមតិជាស្ត្រីក្នុងការបង្កើតផែនការតស៊ូមតិចំនួន៩ ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពី “ស្ត្រីដឹកនាំវ័យក្មេង និងការតស៊ូមតិ”។ បញ្ហារបស់អ្នកលក់តាមផ្លូវនឹងត្រូវបានផ្សព្វផ្សាយទូលំទូលាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានដូចជា៖ វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិ និងវិទ្យុសំឡេងប្រជាធិបតេយ្យ វីអូឌី។ លទ្ធផលទី១ ដែលចេញពីការតស៊ូមតិ គឺរដ្ឋបាលខណ្ឌដូនពេញបានបញ្ជាក់ថាលោកនឹងធ្វើការផ្តល់កន្លែងលក់ត្រឹមត្រូវសម្រាប់អាជីវករលក់ដូរតាមដងផ្លូវនិងអ្នកលក់ផ្សេងទៀតដោយរៀបចំជាថ្មីនូវផ្លូវលេខ៩៨ ដែលជាផ្សារទេសចរណ៍ឈ្មោះថា “ផ្សាររាត្រី២៤ម៉ោង”។ អ្នកលក់ដូរតាមចិញ្ចើមផ្លូវជាស្ត្រីនឹងត្រូវបានអនុញ្ញាតឱ្យបើកអាជីវកម្មរបស់ពួកគេ ហើយរដ្ឋាភិបាលនឹងស្នើសុំឱ្យអ្នកលក់ដូរតាមចិញ្ចើមផ្លូវត្រូវតែលក់អាហារសុខភាព និងមានសុវត្ថិភាពទៅដល់អ្នកទទួលទាន និងរក្សាឱ្យបាននូវបរិស្ថានស្អាតនិងអនាម័យល្អ។

